00613451

F10

នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 13 / 10 / 2010
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

## បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រម
## របស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្ដីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច

---

**អ្នកដាក់ឯកសារ:**
ការិយាល័យសហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉េត ចរិយា
លោក William SMITH
លោក សេង ប៊ុនឃាង
លោក Anees AHMED

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Motoo NOCGHUCHI
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម A.KLONOWIECKA-MILART
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម C. N. JAYASIINGHE
ចៅក្រម យ៉ា ណារិន

មេធាវីជនជាប់ចោទ/ចុងបណ្ដឹងសាទុក្ខ
កាំង ហ្គេកអ៊ាវ ហៅ ឌុច:
លោក ការ សាវុត្ថ
លោក កង ឫទ្ធារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**

| | |
|---|---|
| លោក គង់ ពិសី | លោកស្រី ទី ស្រ៊ីនណា |
| លោក ហុង គឹមសួន | លោក Pierre-Olivier SUR |
| លោក យុង ផានិត | លោក Alain WERNER |
| លោក គឹម ម៉េងឃី | លោក Brianne McGONIGLE |
| កញ្ញា ម៉ុច សុវណ្ណារី | លោកស្រី Annie DELAHAIE |
| កញ្ញា Silke STUDZINSKY | លោកស្រី Elizabeth ABESANDRATANA |
| លោកស្រី Martine JACQUIN | លោក Karim KHAN |
| លោក Philippe CANONNE | លោកស្រី Fabienne TRUSSES-NAPROUS |

# មាតិកា

ក. សេចក្ដីផ្ដើម ........ 7

ខ. សេចក្ដីសន្និដ្ឋានបឋម ........ 12

ខ១. អង្គជំនុំជម្រះគួរធ្វើសវនាការផ្ទាល់មាត់ជាសាធារណៈមួយលើបណ្ដឹងសាទុក្ខនេះ ........ 12

គ. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្ដឹងសាទុក្ខ ........ 15

គ១. លក្ខណៈទូទៅ ........ 15

គ២. បទដ្ឋាននៃការពិនិត្យឡើងវិញនៅក្នុងការផ្ដន្ទាទោស ........ 17

ឃ. ទឡ្ហីករណ៍ទី១៖ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវការភាន់ច្រឡំមួយ ដែលអាចវិនិច្ឆ័យបាន នៅក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិនៃការផ្ដន្ទាទោសរបស់ខ្លួន ដោយបានដាក់ការផ្ដន្ទាទោសមួយដែលស្ដែងចេញមកពុំគ្រប់គ្រាន់ ........ 18

ឃ១. សេចក្ដីសង្ខេប ........ 18

ឃ២. អង្គជំនុំជម្រះបានដាក់ទម្ងន់មិនគ្រប់គ្រាន់ចំពោះកាលៈទេសៈពាក់ព័ន្ធនានា ........ 20

ឃ.២.១ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ........ 20

ឃ.២.១.១ ច្បាប់ ........ 20

ឃ.២.១.២ លទ្ធផលរកឃើញ ........ 24

ឃ.២.១.៣ ការភាន់ច្រឡំ ........ 25

ឃ.២.២ កាលៈទេសៈនីមួយៗរបស់ចុងបណ្ដឹងសាទុក្ខ ........ 27

ឃ.២.២.១ ច្បាប់ ........ 27

ឃ.២.២.២ លទ្ធផលរកឃើញ ........ 30

ឃ.២.២.៣ ការភាន់ច្រឡំ ........ 32

ឃ. ២.៣ ស្ថានទម្ងន់ ........ 33

ឃ. ២.៣.១ ច្បាប់ ........ 33

ឃ. ២.៣.២ លទ្ធផលរកឃើញ ........ 34

ឃ.២.៣.៣ ការភាន់ច្រឡំ ........ 36

ឃ.២.៣.៣.១ ការបំពានអំណាច ........ 36

ឃ.២.៣.៣.២ ភាពគ្មានធម៌មេត្តាចំពោះជនរងគ្រោះ ........ 37

ឃ.២.៣.៣.៣ ភាពងាយរងគ្រោះ និងភាពគ្មានទីពឹងរបស់ជនរងគ្រោះ ........ 38

ឃ.២.៣.៣.៤ ការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយមានចេតនារើសអើង ........ 39

ឃ.៣ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ស្ថានសម្រាលទោសហួសហេតុ ........ 40

ឃ.៣.១ អង្គច្បាប់....................................................................................40

ឃ.៣.២ លទ្ធផលរកឃើញ.............................................................................41

ឃ.៣.៣ ការភាន់ច្រឡំ..................................................................................43

ឃ.៣.៣.១ ទូទៅ........................................................................................ 43

ឃ.៣.៣.២ "បរិយាកាសបង្ខិតបង្ខំ" ............................................................... 44

ឃ.៣.៣.៣ កិច្ចសហការជាមួយនឹងតុលាការ .................................................... 45

ឃ.៣.៣.៤ ការទទួលយកនូវការទទួលខុសត្រូវ និងវិប្បដិសារី ................................... 48

ឃ.៣.៣.៥ ការផ្សះផ្សាជាតិ ........................................................................ 52

ឃ.៣.៣.៦ ការស្តារនីតិសម្បទា និងការចូលរួមរស់នៅក្នុងសង្គមឡើងវិញ.......................... 54

ឃ.៣.៤ សេចក្តីសន្និដ្ឋាន..............................................................................56

ឃ.៤ ការដាក់ទោសធ្វើឡើងតាមអំពើចិត្ត និងមិនគ្រប់គ្រាន់យ៉ាងច្បាស់....................................... 57

ឃ.៤.១ ទិដ្ឋភាពរួម.......................................................................................57

ឃ.៤.២ ការខកខានមិនបានពិចារណាលើច្បាប់ជាធរមាន........................................... 59

ឃ.៤.២.១ ទូទៅ........................................................................................ 59

ឃ.៤.២.២ សាលក្រមមិនអើពើចំពោះយុត្តិសាស្ត្រពាក់ព័ន្ធដែលសហព្រះរាជអាជ្ញាបានលើកយោង....................................................................................................60

ឃ.៤.២.៣ ករណីនេះជាផ្នែក "ដ៏អាក្រក់បំផុត" នៃករណីរឿងក្តីនានា................................ 65

ឃ.៤.២.៤ អង្គជំនុំជម្រះសាលាឧទ្ធរណ៍អន្តរជាតិបានបង្កើនការកាត់ទោសលើបណ្តឹងឧទ្ធរណ៍. 71

ឃ.៤.៣ ការខកខានមិនបានពិចារណាអំពីគោលបំណងនៃការកាត់ទោស ............................ 76

ឃ.៤.៣.១ ទូទៅ........................................................................................ 77

ឃ.៤.៣.២ គោលបំណងនៃការកាត់ទោស ........................................................... 77

ឃ.៤.៣.៣ សេចក្តីសន្និដ្ឋាន ........................................................................ 80

ឃ.៤.៤ ចុងបណ្តឹងសាទុក្ខគ្មានសិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌទេ ................. 81

ឃ.៤.៥ សេចក្តីសន្និដ្ឋាន.............................................................................86

ង. ទឡ្ហីករណ៍ទី២៖ ចុងបណ្តឹងសាទុក្ខគួរត្រូវបានកាត់ឲ្យជាប់ទោសពីបទឧក្រិដ្ឋកម្មទាំងអស់ដែលបានរកឃើញថាគាត់គឺជាអ្នកត្រូវទទួលខុសត្រូវ ........................................................ 87

ង១. សេចក្តីសង្ខេប................................................................................. 87

ង២. អង្គជំនុំជម្រះសាលាដំបូង បានស្រូបបញ្ចូលដោយមិនត្រឹមត្រូវនូវបទឧក្រិដ្ឋដទៃទៀតនៃការធ្វើទុក្ខបុកម្នេញ ក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ................................................ 88

00613455



ង.២.១ សេចក្តីផ្តើម ....................................................................................88

ង.២.២ គ្រប់បទឧក្រិដ្ឋនីមួយៗដែលបានចោទប្រកាន់សុទ្ធតែមានធាតុផ្សំខុសៗគ្នាយ៉ាង ពិតប្រាកដ ....................................................................................89

ង.២.២.១ ឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ .................................................................................... 90

ង.២.២.២ ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ ....................................................................................92

ង.២.២.៣ ឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ .................................................................................... 93

ង.២.២.៤ ឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ .................................................................................... 94

ង.២.២.៥ ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ ....................................................................................95

ង.២.២.៦ ឧក្រិដ្ឋកម្មនៃការរំលោភសេពសន្ថវៈ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ .................................................................................... 96

ង.២.២.៧ ឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ .................................................................................... 97

ង.២.៣ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានបំពេញគ្រប់ តាមគោលបំណងនៃការ កាត់ទោសត្រួត ....................................................................................98

ង.២.៤ សន្និទានភាពនៃការមិនអនុញ្ញាតឱ្យមានទោសត្រួត គឺមិនអាចយកមកអនុវត្ត នៅទីនេះបានទេ ....................................................................................100

ង.២.៤.១ សិទ្ធិត្រូវបានទទួលការដោះលែងតាំងពីដំបូង គឺមិនមែនជាការព្រួយបារម្ភ ដែលមានសុពលភាពនោះទេ .................................................................................... 100

ង.២.៤.២ ការអនុវត្តនូវច្បាប់ "ស្តីពីជនល្មើសដែលប្រព្រឹត្តបទល្មើសជាទម្លាប់" គឺមិនមែន ជាការព្រួយបារម្ភនោះទេ .................................................................................... 101

ង.២.៥ អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានបានពិចារណាពីផលប្រយោជន៍សង្គមក្នុងការ ឱ្យផ្តន្ទាទោសត្រួត .................................................................................... 102

ង.២.៥.១ ទិដ្ឋភាពរួម .................................................................................... 102

ង.២.៥.២ សាលក្រមគួរតែបានរៀបរាប់ឱ្យឃើញសព្វគ្រប់ទាំងអស់អំពីឧក្រិដ្ឋភាព

របស់ចុងបណ្តឹងសាទុក្ខ....................................................................................... 103

ង.២.៥.៣ ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នីមួយៗសុទ្ធតែការពារនូវតម្លៃជាមូលដ្ឋាន

ណាមួយ ...............................................................................................103

ង.២.៦ សេចក្តីសន្និដ្ឋាន...........................................................................108

ង.៣ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ប្រភេទបទល្មើសដោយមិនត្រឹមត្រូវចំពោះបទរំលោភសេពសន្ថវៈ ថាជាអំពើទារុណកម្ម ដែលមានក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ.................109

ង.៣.១ សេចក្តីផ្តើម.......................................................................................109

ង.៣.២ ការរំលោភសេពសន្ថវៈ ថាជាការធ្វើទារុណកម្ម ........................................... 109

ង.៣.៣ ការរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មដាច់ដោយឡែកពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ.........................................................................................111

ង.៣.៤ សេចក្តីសន្និដ្ឋាន............................................................................115

ច. ទឡ្ហីករណ៍ទី៣៖ ចុងបណ្តឹងសាទុក្ខគួរតែត្រូវបានផ្តន្ទាទោសពីបទការធ្វើឱ្យទៅជាទាសករលើអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១.................................................................. 116

ច.១ ទិដ្ឋភាពរួម................................................................................116

ច.២ អង្គជំនុំជម្រះសាលាដំបូង បានកំណត់ដោយខុសឆ្គងថា ពលកម្មដោយបង្ខំគឺជាធាតុផ្សំដ៏សំខាន់នៅក្នុងឧក្រិដ្ឋកម្មស្តីពីការធ្វើឱ្យទៅជាទាសករ.............................................116

ច.៣ សេចក្តីសន្និដ្ឋាន...........................................................................121

ឆ. សេចក្តីសន្និដ្ឋានចុងក្រោយ ............................................................ 122

ជ. ដំណោះស្រាយដែលស្នើសុំ ............................................................... 125

## ក. សេចក្ដីផ្ដើម

១- តាមរយៈសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ភាគីចុងបណ្ដឹងសាទុក្ខ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច មានពិរុទ្ធចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងបានកាត់ទោសរូប គាត់ឱ្យជាប់ពន្ធនាគាររយៈពេលសាមសិបប្រាំឆ្នាំ[1]។ អង្គជំនុំជម្រះសាលាដំបូង បានកំណត់ថា ភាគីចុងបណ្ដឹងសាទុក្ខក្នុងរយៈពេលជាងបីឆ្នាំ ក្នុងនាមជាអនុប្រធាន និងបន្ទាប់មកជាប្រធានមន្ទីរសន្តិសុខ ស-២១ នៅភ្នំពេញ បានគ្រប់គ្រង និងកែសម្រួលប្រព័ន្ធនៃឧក្រិដ្ឋភាពមួយ ដែលបណ្ដាលឱ្យមាន ការកាប់សម្លាប់ជនរងគ្រោះយ៉ាងហោចណាស់ ១២២៧២នាក់ ដែលភាគច្រើនបំផុតនៃជនរងគ្រោះ ទាំងនេះ ត្រូវបានគេធ្វើទារុណកម្មជាប្រព័ន្ធផងដែរ[2]។ ជនរងគ្រោះដែលមិនបានស្លាប់ដោយសារ ការសម្លាប់ក៏ត្រូវស្លាប់ដោយសារលក្ខខណ្ឌផ្សេងៗនៃការដាក់ក្នុងមន្ទីរឃុំឃាំង ដែលបង្កឱ្យមាន ការរីករាលដាលនៃជម្ងឺ កង្វះអាហារ និងការឈឺចាប់ខាងរូបរាងកាយ និងផ្លូវចិត្ត រួមទាំងសេចក្ដី ភិតភ័យហួសហេតុ[3]។ មានអ្នកជាប់ឃុំនៅមន្ទីរស-២១ ដ៏តិចតួចប៉ុណ្ណោះដែលនៅរស់រានមាន ជីវិត[4]។ អ្នករស់រានមានជីវិតទាំងនេះ បានផ្ដល់សក្ខីកម្មអំពីការប៉ះទង្គិចដ៏ខ្លាំងក្លាលើរូបរាងកាយ និងផ្លូវចិត្ត ដែលមានជាប់ជាដរាបរៀងមក អំពីពិសោធន៍ដ៏អាក្រក់របស់ពួកគេ[5]។ សាច់ញាតិរបស់

---

[1] សាលក្រម ក្នុងសំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ កក្កដា ២០១០ E188 (“សាលក្រម”) កថាខណ្ឌទី ៦៧៧ ៦៧៩-៦៨០ ។

[2] សាលក្រម កថាខណ្ឌទី ៥៩៧ ។

[3] សាលក្រម កថាខណ្ឌទី ៥៩៧ ។

[4] សាលក្រម កថាខណ្ឌទី ៥៩៨ ។

[5] សាលក្រម កថាខណ្ឌទី ៥៩៨ ។

អ្នកជាប់ឃុំនៅមន្ទីរស-២១ បានផ្ដល់សក្ខីកម្មអំពីផលវិបាកដ៏ហិនហោចនានានៃឧក្រិដ្ឋកម្មរបស់ភាគីចុងបណ្ដឹងសាទុក្ខ ទៅលើគ្រួសាររបស់ជនជាប់ឃុំទាំងនេះ[6] ។

២- អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា ចុងបណ្ដឹងសាទុក្ខបានធ្វើការដោយមិនចេះនឿយហត់ ដោយមិនអើពើនឹងភាពមនុស្សធម៌របស់អ្នកជាប់ឃុំក្នុងបន្ទុករបស់ខ្លួន។ ចុងបណ្ដឹងសាទុក្ខចង់ធានាថា ស-២១ ធ្វើការងារប្រកបដោយប្រសិទ្ធភាពបំផុតដែលអាចធ្វើទៅបាន។ ចុងបណ្ដឹងសាទុក្ខមានភាពស្មោះត្រង់ចំពោះថ្នាក់លើរបស់ខ្លួន និងមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ("បកក") មិនអាចប្រកែកបាន[7]។ ក្រោមការត្រួតត្រារបស់គាត់ ស-២១ បានក្លាយជាឧបករណ៍ប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត នៃការធ្វើទុក្ខបុកម្នេញក្នុងការលើកតម្កើងគោលនយោបាយឧក្រិដ្ឋដែលមានហេតុផលនយោបាយ របស់បក្សនៃការរើសអើង[8]។

៣- ចំពោះអំពើទាំងនេះ ដែលត្រូវបានកំណត់ថា "ធ្ងន់ធ្ងរជាទីបំផុត"[9] នោះ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា ចុងបណ្ដឹងសាទុក្ខ មានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដោយផ្ទាល់ខ្លួនស្ទើរតែទាំងស្រុងចំពោះបទចោទប្រកាន់លើរូបគាត់[10]៖ ឃាតកម្ម ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ទារុណកម្ម (ក្នុងនោះរួមមាន ការរំលោភសេពសន្ថវៈផង) ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត ដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹង

---

[6] សាលក្រម កថាខណ្ឌទី ៥៩៨ ។

[7] សាលក្រម កថាខណ្ឌ ៥៩៧ ។

[8] សាលក្រម កថាខណ្ឌ ៥៩៧ ។

[9] សាលក្រម កថាខណ្ឌ ៦០០ ។

[10] សេចក្ដីសំរេចលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយចោទប្រកាន់ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច, សំណុំរឿងលេខ 001/18-07-2007-ECCC-OCIJ (PTC 02) អង្គបុរេជំនុំជម្រះ ថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០០៨ D99/3/42 ("ដីកាដំណោះស្រាយកែសម្រួល")។ បទចោទប្រកាន់ អំពីឧក្រិដ្ឋកម្មជាតិ មិនពាក់ព័ន្ធនឹងការខ្វះសម្លេងភាគច្រើនលើសលប់ ក្នុងចំណោមចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទេ (*សូមមើល* សាលក្រម កថាខណ្ឌ ៦៧៨) ។

00613459



មនុស្សជាតិ និងការធ្វើមនុស្សឃាតដោយចេតនា ទារុណកម្ម និងការប្រព្រឹត្តិបែបអមនុស្សធម៌ ការធ្វើឱ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរដោយចេតនា ឬធ្វើឱ្យមានរបួសយ៉ាងធ្ងន់ធ្ងរលើរូបរាងកាយ និងសុខភាព ការដកដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយត្រឹមត្រូវ និងដោយប្រក្រតី ព្រមទាំងការដាក់ឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ ដែលជាការរំលោភយ៉ាងធ្ងន់ធ្ងរចំពោះអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩[11] ។

៤- ដោយបានរកឃើញថា គាត់មានពិរុទ្ធភាពចំពោះ"ឧក្រិដ្ឋកម្មនានាដែលមានលក្ខណៈធ្វើឱ្យតក់ស្លុត និងគួរឱ្យស្អប់ខ្ពើម"[12] អង្គជំនុំជម្រះសាលាដំបូង បានផ្តន្ទាទោសចុងបណ្តឹងសាទុក្ខត្រឹមតែឱ្យជាប់ពន្ធនាគារដែលមានរយៈពេលចំនួនសាមសិបប្រាំ(៣៥)ឆ្នាំ[13] តែមួយមុខគត់។ ការផ្តន្ទាទោសនេះត្រូវបានកាត់បន្ថយមកនៅត្រឹមចំនួនដប់ប្រាំបួន(១៩)ឆ្នាំ ដោយសារគាត់បានអនុវត្តទោសមួយរយៈកន្លងមក និងតម្លៃតបស្នងសម្រាប់ការជាប់ឃុំឃាំងដោយខុសនីតិវិធីច្បាប់ពីមុនមក[14] ។

៥- សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការផ្តន្ទាទោសចំនួនសាមសិបប្រាំ(៣៥)ឆ្នាំ ចំពោះឧក្រិដ្ឋកម្មទំហំបែបនេះគឺជាភាពអយុត្តិធម៌។ វាជាការប៉ះពាល់ចំពោះភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់គាត់ និងអាចសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដោយត្រឹមត្រូវទេ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមប្តឹងជំទាស់ចំពោះសាលក្រមនេះ[15] ។

---

[11] សាលក្រម កថាខណ្ឌ ៥៦៧ ។

[12] សាលក្រម កថាខណ្ឌ ៥៩៧ ។

[13] សាលក្រម កថាខណ្ឌ ៦៣១ ។

[14] សាលក្រម កថាខណ្ឌ ៦៣២-៦៣៣ ។

[15] សហព្រះរាជអាជ្ញា ដាក់បណ្តឹងឧទ្ធរណ៍នេះ ដោយអនុលោមតាមវិធានផ្ទៃក្នុង វិសោធនកម្មលើកទី ៥ ចុះថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១០ ("វិធាន") វិធាន ១០៥(១)(ក) ១១០(៤) ។

៦- សាលក្រមនេះ ក៏មានការខកខានផងដែរនៅក្នុងការឆ្លុះបញ្ចាំងពីវិសាលភាពទាំងស្រុងនៃឧក្រិដ្ឋភាពរបស់ចុងបណ្ដឹងសាទុក្ខ ដោយពុំបានធ្វើការផ្ដន្ទាទោសគាត់ចំពោះ៖ ទី១) ឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានគេរកឃើញថាគាត់ត្រូវទទួលខុសត្រូវ និងដោយការស្រូបឧក្រិដ្ឋកម្មភាគច្រើនទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្ដីពីការធ្វើទុក្ខបុកម្នេញ និងទី២) ដោយពុំបានធ្វើការផ្ដន្ទាទោសគាត់ចំពោះឧក្រិដ្ឋកម្ម ស្ដីពីការធ្វើឲ្យទៅជាទាសករទៅលើពួកអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១ តាមរយៈការអនុវត្តនូវនិយមន័យខុសពីឧក្រិដ្ឋកម្មនោះ។

៧- សហព្រះរាជអាជ្ញាបានរកឃើញថា សាលក្រមនេះ មានកំហុសសំខាន់ៗខាងផ្លូវច្បាប់ចំនួនបីយ៉ាងដែលត្រូវបានយកមកធ្វើជាទឡ្ហីករណ៍ក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន[16]។

៨- *ទឡ្ហីករណ៍ទី ១:* សហព្រះរាជអាជ្ញារក្សាមតិថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងផ្លូវច្បាប់ដោយមិនបានផ្ដល់ទម្ងន់សមស្របដល់ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់ចុងបណ្ដឹងសាទុក្ខ និងតួនាទីដឹកនាំរបស់គាត់ ព្រមទាំងឆន្ទៈចូលរួមរបស់គាត់ក្នុងឧក្រិដ្ឋកម្មទាំងនោះ។ អង្គជំនុំជម្រះក៏បានធ្វើការថ្លឹងថ្លែងមិនសមស្របទៅលើស្ថានភាពសម្រាលទោសដល់ចុងបណ្ដឹងសាទុក្ខផងដែរ។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាជំទាស់ថា រយៈពេលនៃការផ្ដន្ទាទោសចំនួនសាមសិបប្រាំ(៣៥)ឆ្នាំគឺត្រូវបានកំណត់ដោយបំពាន ដោយមិនបានពិចារណាទៅលើករណីយុត្តិសាស្ត្រអន្តរជាតិដែលត្រូវអនុវត្ត[17]។ ការផ្ដន្ទាទោសនេះជាក់ស្ដែងណាស់ គឺវាមិនសមល្មមទេ ចំពោះភាពអមនុស្សធម៌ដែលបានកើតចេញមកពីខ្សែសង្វាក់នៃទារុណកម្ម និងការស្លាប់នេះ ដែលចុងបណ្ដឹងសាទុក្ខបានបង្កើតនិងបានដឹកនាំធ្វើពេញមួយរយៈពេលជាងបីឆ្នាំនោះ។ ចុងបណ្ដឹងសាទុក្ខ គឺជាមជ្ឈមណ្ឌលនៃ

---

[16] សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១០ ប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះសំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច សំណុំរឿងលេខ 001/18-07-2007-ECCC-TC E188 ("សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍")។

[17] សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣-៤ ។

ឧក្រិដ្ឋកម្មដ៏អាក្រក់ជួរជាតិជាទីបំផុត ដែលបានប្រព្រឹត្តឡើងក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ។ ការផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង មិនបានឆ្លុះបញ្ចាំងដោយសមស្របអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ឬតួនាទីរបស់ចុងបណ្តឹងសាទុក្ខ ចំពោះឧក្រិដ្ឋកម្មទាំងនោះទេ[18]។

៩- *ទឡ្ហីករណ៍ទី ២:* សហព្រះរាជអាជ្ញា រក្សាមតិថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសខាងផ្លូវច្បាប់ក្នុងការខកខានមិនបានឆ្លុះបញ្ចាំងនូវវិសាលភាពទាំងស្រុងនៃឧក្រិដ្ឋភាព របស់ចុងបណ្តឹងសាទុក្ខដោយមិនបានបំបែកចេញពីគ្នាក្នុងការផ្តន្ទាទោសរួបគាត់ចំពោះ ការសម្លាប់រង្គាល ឃាតកម្ម ការធ្វើឲ្យក្លាយជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ទារុណកម្ម ការរំលោភសេពសន្ថវៈ និងអំពើអមនុស្សធម៌ដទៃទៀត នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ សហព្រះរាជអាជ្ញា ជំទាស់ថាឧក្រិដ្ឋកម្មទាំងនេះមិនត្រូវដាក់បញ្ចូលគ្នាដូចដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើ ក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញនោះទេ។ ដូចគ្នានេះដែរ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការរំលោភសេពសន្ថវៈ មិនត្រូវយកមកបញ្ចូលក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការធ្វើទារុណកម្មទេ[19]។

១០- *ទឡ្ហីករណ៍ទី៣:* សហព្រះរាជអាជ្ញាប្រកាន់ជំហរដដែលថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំផ្នែកអង្គច្បាប់ដោយសារមិនបានសម្រេចសេចក្តី ឲ្យចុងបណ្តឹងសាទុក្ខមានទោសពីបទធ្វើឲ្យអ្នកជាប់ឃុំឃាំងទាំងអស់នៃមន្ទីរស-២១ ក្លាយទៅជាទាសករ។ អង្គជំនុំជម្រះសាលាដំបូង បានដាក់លក្ខខណ្ឌមិនត្រឹមត្រូវថាដើម្បីឲ្យមានទោសពីបទនេះ ជនរងគ្រោះដោយសារការធ្វើឲ្យទៅជាទាសករទាំងនោះ គួរតែត្រូវបានគេដាក់ឲ្យទទួលរងនូវការធ្វើពលកម្មដោយបង្ខំ។ តាមច្បាប់អន្តរជាតិ គឺមិនមានលក្ខខណ្ឌតម្រូវបែបនេះឡើយ[20] ។

---

[18] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣-៤ ។

[19] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥-៦ ។

[20] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ កថាខណ្ឌទី៧។

១១- ដោយផ្អែកលើទឡ្ហីករណ៍ទាំងនេះ សហព្រះរាជអាជ្ញា សូមស្នើដល់អង្គជំនុំជម្រះតុលាការកំពូលៈ ទី១) ស្នើឱ្យបង្កើនការផ្តន្ទាទោសចុងបណ្តឹងសាទុក្ខរហូតដល់ទោសជាប់ពន្ធនាគារអស់មួយជីវិតដូចដែលសហព្រះរាជអាជ្ញា បានស្នើនៅក្នុងពេលធ្វើដីកាសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលរបស់ខ្លួន ទី២) ស្នើឱ្យបញ្ចូលការផ្តន្ទាទោសដាច់ដោយឡែកពីគ្នាទៅតាមបទចោទប្រកាន់ទាំងឡាយដែលត្រូវបានបង្ហាញភស្តុតាងប្រឆាំងនឹងចុងបណ្តឹងសាទុក្ខ និងទី៣) ស្នើឱ្យបញ្ចូលការផ្តន្ទាទោសដោយទទួលស្គាល់ចំពោះបទធ្វើឱ្យទៅជាទាសករនូវអ្នកជាប់ឃុំឃាំងភាគច្រើននៅក្នុងមន្ទីរស-២១។

## ខ. សេចក្តីសន្និដ្ឋានបឋម

### ខ១. អង្គជំនុំជម្រះគួរធ្វើសវនាការផ្ទាល់មាត់ជាសាធារណៈមួយលើបណ្តឹងសាទុក្ខនេះ

១២- ស្ទើរតែគ្រប់ដំណើរការនីតិវិធីទាំងអស់នៃករណីរឿងនេះសុទ្ធតែបានធ្វើឡើងជាសាធារណៈ៖ ទី១) សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយមួយជាសាធារណៈ[21] ទី២) អង្គបុរេជំនុំជម្រះបានចេញសាលដីកាសម្រេចជាសាធារណៈមួយ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[22] ទី៣) សវនាការអង្គសេចក្តីទាំងស្រុងត្រូវបានធ្វើឡើងជាសាធារណៈ[23] និងទី៤) អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមមួយជាសាធារណៈ[24]។ មានប្រជាជនកម្ពុជា និងជនដទៃ

---

[21]ដីកាដំណោះស្រាយបញ្ជូន កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ទៅជំនុំជម្រះ, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក-កសចស របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៨ សីហា ២០០៨ ឯកសារលេខ D99 ("ដីកាដំណោះស្រាយ") ។

[22] *សូមអាន* ដីកាដំណោះស្រាយដែលបានធ្វើការកែប្រែ។

[23] ភាគច្រើននៃសវនាការអង្គសេចក្តីត្រូវបានធ្វើឡើងជាសាធារណៈ ហើយប្រតិចារឹកអាចរកបាននៅក្នុងគេហទំព័រតាមអាសយដ្ឋាននៃគេហទំព័ររបស់ អវតក ត្រង់អាសយដ្ឋាន http://www.eccc.gov.kh/english/caseinfo001.aspx ។ ក៏ប៉ុន្តែកិច្ចប្រជុំត្រៀមរៀបចំសវនាការបឋម ត្រូវបានធ្វើឡើងនៅក្នុងអង្គប្រជុំជាសម្ងាត់"។ *សូមអាន* សាលក្រម ឧបសម្ព័ន្ធទី១ : ប្រវត្តិនៃនីតិវិធី, កថាខណ្ឌទី១៣ (ដែលរៀបរាប់ថា កិច្ចប្រជុំទាំងនេះបានជួយដល់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងសវនាការជំនុំជម្រះក្តីជាច្រើនពាក់ព័ន្ធនឹងបញ្ហានីតិវិធី)។

[24] *សូមអាន* ដីកាសម្រេចស្តីពីថ្ងៃកំណត់ថ្ងៃបើកសវនាការ ដើម្បីប្រកាសសាលក្រម (ពេលវេលា) សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣០ មិថុនា ២០១០, ឯកសារលេខ E184 ។

00613463



ទៀតជាងពីរម៉ឺនប្រាំបីពាន់ (២៨០០០) នាក់ បានមកចូលរួមក្នុងពេលដំណើរការជំនុំជម្រះក្តី និងប្រជាជនរាប់លាននាក់ផ្សេងទៀត បានតាមដានដំណើរការនេះតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាអេឡិចត្រូនិកនានា[25]។ សាលក្រម និងខ្លឹមសារក្នុងនេះ បានដាស់ស្មារតីធ្វើឱ្យមានការពិភាក្សាដេញដោលជាសាធារណៈ មួយនៅក្នុងប្រទេសកម្ពុជា និងនៅតាមទីកន្លែងដទៃទៀត[26]។ លើសពីនេះ តុលាការនេះ គឺជាតុលាការដំបូងគេបង្អស់នៃតុលាការប្រភេទនេះដែលផ្តល់សិទ្ធិធ្វើជាភាគីដល់ជនរងគ្រោះទាំងឡាយនៃឧក្រិដ្ឋកម្ម និងបានសង្កត់ធ្ងន់អំពីការចូលរួមរបស់ជនរងគ្រោះនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី។ មានជនរងគ្រោះរាប់ពាន់នាក់ ក្នុងឋានៈជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ធ្វើជាដើមបណ្តឹង និងម្យ៉ាងទៀតថែមទាំងបានតាមដានលើដំណើរការនីតិវិធីសវនាការយ៉ាងជិតដល់។ អាស្រ័យហេតុដូចច្នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថាសវនាការផ្ទាល់មាត់ជាសាធារណៈ មួយលើបណ្តឹងសាទុក្ខនេះ នឹងជួយជម្រុញនូវការអនុវត្តដែលត្រូវបានបង្កើតឡើង និងបំរើដល់ផលប្រយោជន៍នៃយុត្តិធម៌ ព្រមទាំងជម្រុញគោលដៅនានានៃការបង្កើតតុលាការនេះ។

១៣- បន្ថែមលើនេះ វិធានផ្ទៃក្នុង (វិធាន) របស់តុលាការនេះបានគ្រោងទុកជាមុនអំពីសវនាការផ្ទាល់មាត់នៃរាល់បណ្តឹងសាទុក្ខទាំងអស់ប្រឆាំងនឹងសាលក្រមចុងក្រោយ របស់អង្គជំនុំជម្រះសាលាដំបូង[27]

---

[25] សេចក្តីប្រកាសព័ត៌មាននៃ អវតក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ដែលអាចរកបានតាមគេហទំព័ររបស់ អវតក នៅអាសយដ្ឋាន "http://www.eccc.gov.kh/english/cabinet/press/162/20100726_Press_Release_Case_001_ENG.pdf" (ដែលរៀបរាប់ថា មានអ្នកចូលរួមចំនួន ២៨០០០នាក់ ដែលបានអញ្ជើញតាមដានដំណើការសវនាការដែលផ្សាយចេញពីសាលសំរាប់សាធារណជន)។ *សូមអានផងដែរនូវ* ការវិវឌ្ឍន៍ថ្មីៗនៅឯអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា របាយការណ៍របស់កម្មវិធីតាមដានតុលាការរបស់អង្គការ Open Society Justice Initiative (OSJI) ទីក្រុងញូវយ៉ក, ដែលអាចរកបានតាមគេហទំព័រ៖ "http://www. soros.org/initiatives/justice/focus/international_justice/articles_publications/cambodia_reports-20019002" (" របាយការណ៍ OSJI ខែកញ្ញា ២០១០") (ដែលនិយាយនៅត្រង់ទំព័រ៧ ថាមានប្រជាជនកម្ពុជាចំនួនរាប់លាននាក់បានមើលដំណើការនៃដំណើការជំនុំជម្រះក្តីដែលផ្សព្វផ្សាយតាមទូរទស្សន៍)។

[26] របាយការណ៍ OSJI ខែកញ្ញា ២០១០, ទំព័រ៤។

[27] *សូមអាន* វិធាន១០៩ នៃវិធានផ្ទៃក្នុង។

នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ មានតែ "បណ្តឹងសាទុក្ខភ្លាមៗ[ឬលើបញ្ហាបន្ទាន់បង្ហំ]" តែប៉ុណ្ណោះ ដែលអាចត្រូវបានធ្វើសេចក្តីសម្រេចនៅលើដីកាសន្និដ្ឋានជាលាយលក្ខណ៍អក្សរ[28]។

១៤- វិធានបានបង្កើតនូវការសន្មតមួយ ដែលគាំទ្រដល់ការធ្វើសវនាការផ្ទាល់មាត់ទាំងនោះជាសាធារណៈ។ ដំណើរការនីតិវិធីអាចនឹងត្រូវបានធ្វើឡើងមួយផ្នែក ឬទាំងមូល *ជាអសាធារណៈ* បើអង្គជំនុំជម្រះតុលាការកំពូល កំណត់ថា ការធ្វើជាសាធារណៈនោះនឹងធ្វើឲ្យខូចដល់សណ្តាប់ធ្នាប់សាធារណៈ ឬក៏ដើម្បីហេតុផលការពារដល់ជនរងគ្រោះ និងសាក្សី[29]។

១៥- គ្មានការខូចខាតនឹងត្រូវបានបង្កឡើងដល់សណ្តាប់ធ្នាប់សាធារណៈនោះទេ បើសិនជាបណ្តឹងសាទុក្ខនោះត្រូវបានបើកសវនាការជាសាធារណៈ។ ការការពារសាក្សី ឬជនរងគ្រោះ ដែលជាយថាហេតុមានលក្ខណៈដាច់ខាតត្រូវតែធ្វើដោយខានមិនបាន អាចនឹងត្រូវបានដោះស្រាយដោយការបើកសវនាការផ្នែកខ្លះ *ជាអសាធារណៈ* ដែលពាក់ព័ន្ធយ៉ាងជាក់លាក់ជាមួយជនទាំងនោះ។ ដោយសារតែនេះគឺជាសវនាការដំបូងបង្អស់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនោះ អង្គបុរេជំនុំជម្រះបានសម្រេចធ្វើសវនាការផ្ទាល់មាត់ជាសាធារណៈជាច្រើនលើករួចមកហើយ ដោយមានផ្នែកខ្លះដែលតាមតម្រូវការចាំបាច់ គឺបានធ្វើឡើង*ជាអសាធារណៈ*[30] ។

១៦- អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា ស្នើដល់អង្គជំនុំជម្រះតុលាការកំពូលសុំឲ្យបើកធ្វើសវនាការលើបណ្តឹងសាទុក្ខនេះជាសាធារណៈ។

---

[28] វិធាន១០៩.១ នៃវិធានផ្ទៃក្នុង។

[29] វិធាន១០៩.១ - ១០៩.៣ នៃវិធានផ្ទៃក្នុង។

[30] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការឃុំខ្លួន អៀងធីរិទ្ធ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ០២) អង្គជំនុំបុរេជម្រះ ចុះថ្ងៃទី៩ កក្កដា ២០០៨ ឯកសារលេខ C20/I/27 កថាខណ្ឌទី៦។

## គ. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ

### គ១. លក្ខណៈទូទៅ

១៧- វិធាន ១០៤.១ នៃវិធានផ្ទៃក្នុង ផ្តល់យុត្តាធិការដល់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការធ្វើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ដោយផ្អែកលើមូលដ្ឋានដូចតទៅ៖ ទី១) កំហុសលើបញ្ហាអង្គច្បាប់ដែលនាំឱ្យមោឃៈសាលក្រម ឬសេចក្តីសម្រេចនោះ ឬទី២) កំហុសនៃអង្គហេតុដែលនាំឱ្យសាលក្រមនោះមានភាពអយុត្តិធម៌។

១៨- នេះគឺជាបណ្តឹងសាទុក្ខលើកដំបូងអំពីសាលក្រម នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដោយផ្អែកតាមវិធាន ១០៤.១ នៃវិធានផ្ទៃក្នុង។ មិនមានសេចក្តីសម្រេចរបស់តុលាការណាដែលជាករណីយុត្តិសាស្ត្រសម្រាប់ឱ្យតុលាការនេះធ្វើការបកស្រាយលើបញ្ញត្តិច្បាប់នេះទេ។ ក៏ប៉ុន្តែវិធាន ១០៤.១ នៃវិធានផ្ទៃក្នុងឆ្លុះបញ្ចាំងឱ្យឃើញពីមាត្រា ២៥.១ នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY" និង "ច្បាប់លក្ខន្តិកៈតុលាការ ICTY" នីមួយៗរៀងៗខ្លួន)[31]។ វិធាន ១០៤.១ នៃវិធានផ្ទៃក្នុង ពីដំបូងបានចែងយ៉ាងទូលំទូលាយអំពីសិទ្ធិក្នុងការប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ដែលស្របគ្នាជាមួយនឹងការអនុវត្តរបស់កម្ពុជាដែលតាមរយៈនេះបណ្តឹងសាទុក្ខសឹងតែជាការធ្វើសវនាការ*សារជាថ្មីឡើងវិញ*។ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ វិធាន ១០៤.១ នៃវិធានផ្ទៃក្នុង ត្រូវបានធ្វើវិសោធនកម្មនៅក្នុងកិច្ចប្រជុំពេញអង្គ ដើម្បីអនុញ្ញាតនូវទឡ្ហីករណ៍នានា សម្រាប់ការធ្វើបណ្តឹងសាទុក្ខ ដែលមានលក្ខណៈស្រដៀងគ្នានឹងបញ្ញត្តិដែលចែង

[31] លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("លក្ខន្តិកៈតុលាការ ICTY") មាត្រា២៥.១។

នៅក្នុងច្បាប់លក្ខន្តិកៈតុលាការ ICTY ដែរ[32]។ ហេតុដូចនេះ វិធាន១០៤.១ នៃវិធានផ្ទៃក្នុងគឺតំណាងឱ្យការសម្របខ្លួននៃនីតិវិធីរបស់កម្ពុជាឱ្យស្របតាមបទដ្ឋានអន្តរជាតិនានា ដោយសារតែលក្ខណៈពិសេសនៃករណីរឿង ដែលត្រូវបានជំនុំជម្រះដោយតុលាការនេះ។ ហេតុដូចនេះទើបបានជាយុត្តិសាស្ត្រអន្តរជាតិដែលមកពីតុលាការ ICTY និងតុលាការដទៃៗទៀត អាចជួយដល់ការបកស្រាយលើវិធាន ១០៤.១ នេះ។

១៩- ដោយសារតែបណ្តឹងសាទុក្ខនេះ បានលើកឡើងតែកំហុសនានាផ្នែកច្បាប់ ដែលធ្វើឱ្យសាលក្រមអស់សុពលភាព សហព្រះរាជអាជ្ញា គ្រាន់តែធ្វើការពិនិត្យអំពីយុត្តិសាស្ត្រពាក់ព័ន្ធទៅនឹងបទដ្ឋាននៃការពិនិត្យសាលក្រមឡើងវិញ នៅលើទឡ្ហីករណ៍នានាស្តីពីកំហុសអង្គច្បាប់។ យោងតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ភាគីមួយដែលបានលើកឡើងនូវការចោទប្រកាន់ពីកំហុសមួយនៅក្នុងអង្គច្បាប់ ត្រូវតែកំណត់អត្តសញ្ញាណអំពីកំហុសដែលបានលើកឡើងចោទប្រកាន់នោះ ដាក់បង្ហាញពីសំអាងច្បាប់នានាដែលគាំទ្រនូវការលើកឡើងអំពីការចោទប្រកាន់របស់ខ្លួន ហើយនិងធ្វើការពន្យល់ថាតើកំហុសនោះបានធ្វើឱ្យសាលក្រមអស់សុពលភាពយ៉ាងដូចម្តេច[33]។ ការលើកឡើងអំពីការចោទប្រកាន់អំពីកំហុសមួយនៃអង្គច្បាប់ ដែលពុំមានលទ្ធភាពនៅក្នុងការផ្លាស់ប្តូរលទ្ធផលនៃសាលក្រមមួយទេនោះ អាចនឹងត្រូវបានច្រានចោលដោយឈរលើទឡ្ហីករណ៍នោះ[34]។ បន្ថែមលើនេះ សូម្បីតែសំអាងច្បាប់នានារបស់ដើមបណ្តឹងសាទុក្ខ មិនគ្រប់គ្រាន់នៅក្នុងការគាំទ្រ

---

[32] នៅមុនពេលធ្វើវិសោធនកម្មកាលពីថ្ងៃទី៥ កញ្ញា ២០០៨, វិធាន១០៤.១ នៃវិធានផ្ទៃក្នុងមានខ្លឹមសារដូចតទៅៈ " អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើបញ្ហាអង្គហេតុ និងអង្គច្បាប់"។

[33] *រដ្ឋអាជ្ញា ទល់នឹង Galić* សាលដីកា IT-98-29-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ថ្ងៃទី៣០ វិច្ឆិកា ២០០៦ (សាលដីកាលើករណីរបស់ *Galić*) កថាខណ្ឌទី ៧ ។

[34] សាលដីកាលើករណីរបស់ *Galić* កថាខណ្ឌទី ៧ ។

ដល់បញ្ហាវិវាទអំពីកំហុសមួយនៃអង្គច្បាប់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាឧទ្ធរណ៍នេះ អាចនឹងសន្និដ្ឋានបានថាវាមានកំហុសមួយខាងអង្គច្បាប់ ចំពោះហេតុផលផ្សេងៗទៀតបានដែរ[35]។

## គ២. បទដ្ឋាននៃការពិនិត្យឡើងវិញនៅក្នុងការផ្ដន្ទាទោស

២០- បណ្ដឹងសាទុក្ខលើការផ្ដន្ទាទោស គឺដូចគ្នានឹងបណ្ដឹងសាទុក្ខនានាដែលជំទាស់នឹងសាលក្រមផ្សេងៗរបស់អង្គជំនុំជម្រះសាលាដំបូងដែរ គឺជាបណ្ដឹងសាទុក្ខ *ក្នុងន័យហ្មត់ចត់ដាច់ខាត (stricto sensu)* បណ្ដឹងសាទុក្ខទាំងនោះ មានលក្ខណៈជាការកែតម្រូវ និងពុំមែនជាការជំនុំជម្រះ*សារជាថ្មី (de novo) ទេ*[36]។ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយ ក្នុងការកំណត់រកនូវការផ្ដន្ទាទោសមួយដ៏ត្រឹមត្រូវ ក៏ព្រោះតែពួកគាត់ មានកាតព្វកិច្ចដើម្បីធ្វើអត្តបុគ្គលកម្ម (to individualise) លើទោសទាំងឡាយឲ្យសមស្របទៅនឹងកាលៈទេសៈរបស់ជនជាប់ចោទ និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មរបស់ខ្លួន[37]។ ហេតុដូច្នេះ តាមវិធានទូទៅ តុលាការជាន់ខ្ពស់ នឹងមិនពិនិត្យមើលអំពីការផ្ដន្ទាទោសសារជាថ្មីឡើងវិញទេ លើកលែងតែអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវ "កំហុសមួយដែលអាចវិនិច្ឆ័យបាន" នៅក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ឬខកខានពុំបានអនុវត្តតាមច្បាប់ដែលនៅជាធរមាន[38]។

២១- ដើម្បីបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវកំហុសមួយដែលអាចវិនិច្ឆ័យបាន នៅក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ដើមបណ្ដឹងសាទុក្ខចាំបាច់ត្រូវតែពន្យល់បំភ្លឺថា ឬមួយអង្គជំនុំជម្រះ

---

[35] សាលដីកាលើករណីរបស់ *Galić* កថាខណ្ឌទី ៧ ។

[36] សាលដីកាលើករណីរបស់ *Galić* កថាខណ្ឌទី ៣៩៣ ។

[37] សាលដីកាលើករណីរបស់ *Galić* កថាខណ្ឌទី ៣៩៣ ។

[38] សាលដីកាលើករណីរបស់ *Galić* កថាខណ្ឌទី ៣៩៣ (លើកឡើងពី *រដ្ឋអាជ្ញា ទល់នឹង Miodrag Jokić* សាលដីកាលើបណ្ដឹងសាទុក្ខស្ដីពីការផ្ដន្ទាទោស IT-01-42/I-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ថ្ងៃទី៣០ សីហា ២០០៥ កថាខណ្ឌទី ៨) ។

សាលាដំបូងបានផ្តល់ទម្ងន់ទៅលើការពិចារណាទាំងឡាយដែលមិនសំខាន់ និងដែលពុំមានការពាក់ព័ន្ធ ដោយខកខានពុំបានផ្តល់ទម្ងន់អ្វីសោះ ឬខកខានមិនបានផ្តល់ទម្ងន់គ្រប់គ្រាន់ទៅលើការពិចារណាទាំងឡាយដែលមានការពាក់ព័ន្ធ ឬបានធ្វើនូវកំហុសមួយដ៏ច្បាស់លាស់អំពីអង្គហេតុដែលខ្លួនបានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ឬមួយក៏ថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផលសោះ ឬក៏ពុំត្រឹមត្រូវ រហូតដល់អង្គជំនុំជម្រះតុលាការកំពូល អាចនឹងមានលទ្ធភាពនៅក្នុងការទាញសេចក្តីសន្និដ្ឋានបានថា អង្គជំនុំជម្រះសាលាដំបូងប្រាកដជាខកខានពុំបានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យបានត្រឹមត្រូវទេ[39]។

## ឃ. ឧបសគ្គករណ៍ទី១៖ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវការវាយតម្លៃមួយ ដែលអាចទិនិច្ឆ័យបាន នៅក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិនៃការផ្តន្ទាទោសរបស់ខ្លួនដោយបានដាក់ការផ្តន្ទាទោសមួយដែលស្តែងចេញមកពុំគ្រប់គ្រាន់

### ឃ១. សេចក្តីសង្ខេប

២២- បន្ទាប់ពីបានរកឃើញយ៉ាងត្រឹមត្រូវថា ចុងបណ្តឹងសាទុក្ខត្រូវទទួលខុសត្រូវចំពោះ "ឧក្រិដ្ឋកម្មជាក់ស្តែងនានាដែលមានលក្ខណៈដ៏គួរឲ្យរន្ធត់ និងសាហាវយង់ឃ្នង"[40] អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវកំហុសមួយខាងអង្គច្បាប់ដែលបានធ្វើឲ្យសាលក្រមអស់សុពលភាព ដោយសារមិនបានផ្តល់ទម្ងន់ឲ្យបានគ្រប់គ្រាន់ទៅលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្មនានានៅមន្ទីរ ស-២១ តួនាទីសំខាន់របស់ចុងបណ្តឹងសាទុក្ខ និងការចូលរួមប្រព្រឹត្តដោយស្ម័គ្រចិត្តនៅក្នុងឧក្រិដ្ឋកម្មទាំងនោះ ហើយនិង

---

[39] សាលដីកាលើករណីរបស់ *Galić* កថាខណ្ឌទី ៣៩៤ (លើកឡើងពី *រដ្ឋអាជ្ញា ទល់នឹង Babić* សាលដីកាលើបណ្តឹងសាទុក្ខស្តីពីការផ្តន្ទាទោស IT-03-72-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ថ្ងៃទី១៨ កក្កដា ២០០៥ កថាខណ្ឌទី ៤៤ ។

[40] សាលក្រម, កថាខណ្ឌទី ៥៩៧ ។

កាលៈទេសៈធ្ងន់ធ្ងរបន្ថែមផ្សេងៗទៀត ដែលបានភ្ជាប់ទៅនឹងស្ថានភាពរបស់គាត់។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូង បានដាក់ទម្ងន់ជ្រុលហួសទៅលើអ្វីដែលអង្គជំនុំជម្រះយល់ឃើញថាជា "ស្ថានសម្រាលដ៏សំខាន់" ដែលទៅតាមសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាពុំបានបង្ហាញនៅក្នុងករណីនេះទេ។ សំខាន់បំផុតនោះ គឺបន្ទាប់ពីសំណើរបស់ចុងបណ្ដឹងសាទុក្ខនៅពេលចុងបញ្ចប់នៃសវនាការដែលស្នើសុំឲ្យមានការលើកលែងការចោទប្រកាន់ នោះការភ្ញាក់ខ្លួន និងវិប្បដិសារីរបស់គាត់ គឺត្រូវតែបានដាក់ឲ្យស្ថិតនៅក្នុងក្ដីមន្ទិលសង្ស័យយ៉ាងខ្លាំង ។

២៣- អង្គជំនុំជម្រះសាលាដំបូង ក៏បានប្រព្រឹត្តនូវកំហុសឆ្គង ដោយការមិនពឹងផ្អែកទៅលើយុត្តិសាស្ត្រអន្តរជាតិដែលបានសំអាង និងដែលបានពឹងផ្អែកដោយសហព្រះរាជអាជ្ញា ឬដែលតាមពិត *មានយ៉ាងប្រត្យក្ស (ex facie)* នៅក្នុងយុត្តិសាស្ត្រ ឬការអនុវត្តដែលពាក់ព័ន្ធ តាមរយៈការដាក់ពន្ធនាគារសរុបចំនួនសាមសិបប្រាំ(៣៥)ឆ្នាំ[41]។ សាលក្រមពុំបានបញ្ជាក់ថា តើអង្គជំនុំជម្រះសាលាដំបូងបានឈានដល់តួលេខនេះយ៉ាងដូចម្ដេចនោះទេ ឬថាតើសាលក្រមបានពឹងផ្អែកលើការវាយតម្លៃណាមួយដែលការផ្ដន្ទាទោសស្រដៀងគ្នានេះ ត្រូវបានគេប្រើប្រាស់នៅក្នុងករណីនានាដែលមានទំហំ និងភាពធ្ងន់ធ្ងរស្រដៀងគ្នា នៅចំពោះមុខតុលាការព្រហ្មទណ្ឌទាំងឡាយដែលធ្វើការកាត់សេចក្ដីលើករណីស្រដៀងគ្នានេះ។ តួលេខដែលបានកំណត់ដោយឯកឯងនេះ ទោះបីជាបានឈានដល់តាមរបៀបណាក៏ដោយ ក៏វាបានកើតឡើងដោយពុំគ្រប់គ្រាន់សម្រាប់ ឧក្រិដ្ឋកម្មនានាដែលត្រូវបានបង្ហាញសក្ខីកម្ម និងត្រូវបានចុងបណ្ដឹងសាទុក្ខទទួលសារភាព ដែលតួលេខនេះបានធ្លាក់ចូលទៅក្នុងប្រភេទដ៏អាក្រក់បំផុតនៅចំពោះមុខតុលាការដែលមានចរិតលក្ខណៈបែបដូច្នេះ។

[41] សេចក្ដីសន្និដ្ឋានបញ្ចប់សវនាការដេញដោលរបស់សហព្រះរាជអាជ្ញា ដោយមានឧបសម្ព័ន្ធទី១-៥ សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/ អជសដ ថ្ងៃទី១១ វិច្ឆិកា ២០០៩ E159/9 ("សេចក្ដីសន្និដ្ឋានបញ្ចប់សវនាការដេញដោល") កថាខណ្ឌទី ៣៥៧-៤៧២ ។

00613470



២៤- ដូចដែលធ្លាប់បានធ្វើនៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់សវនាការដេញដោលរួចមក សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការផ្ដន្ទាទោសដ៏ត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលាដំបូង ដែលជាចំណុចចាប់ផ្ដើមត្រូវតែជាប់ពន្ធនាគារអស់មួយជីវិត។ គឺមានតែបន្ទាប់ពីការពិចារណាអំពីរយៈពេលនៃការជាប់ពន្ធនាគារតែប៉ុណ្ណោះ ដែលអង្គជំនុំជម្រះសាលាដំបូងមានសក្ដានុពលនឹងធ្វើការពិចារណានៅក្នុងករណីសមស្របឱ្យមានការកាត់បន្ថយណាមួយដែលបណ្ដាលមកពីស្ថានសម្រាល។ អាស្រ័យហេតុដូច្នេះជាខ្លឹមសារ អង្គជំនុំជម្រះសាលាដំបូង បានចាប់យកការផ្ដន្ទាទោសចំនួនសាមសិបប្រាំ (៣៥)ឆ្នាំ "ចេញពីធ្នើរមួយដែលខុស"[42] ។

២៥- សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល ស្វែងរកថាតើ អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តនូវកំហុសមួយដែលអាចវិនិច្ឆ័យបាននៅក្នុងការឈានទៅដល់ការផ្ដន្ទាទោសមួយដែលមានចំនួនសាមសិបប្រាំ(៣៥)ឆ្នាំ ហើយនិងថាបើយ៉ាងដូច្នោះមែន សូមស្នើឱ្យធ្វើការជំនួសវាដោយការផ្ដន្ទាទោសមួយដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត ដោយមានស្ថានសម្រាលទោសដែលមានកំរិត ដូចដែលសហព្រះរាជអាជ្ញាបានដាក់ជាសេចក្ដីសន្និដ្ឋានរួចមកហើយនៅពេលសវនាការនិងដូចដែលត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងកថាខណ្ឌនានាដូចខាងក្រោមនេះ ។

## ឃ២. អង្គជំនុំជម្រះបានដាក់ទម្ងន់មិនគ្រប់គ្រាន់ចំពោះកាលៈទេសៈពាក់ព័ន្ធនានា

### ឃ.២.១ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ

#### ឃ.២.១.១ ច្បាប់

[42] សាលដីកាលើករណីរបស់ *Galić* កថាខណ្ឌទី ៤៥៥ ។

00613471



២៦- នៅពេលធ្វើការផ្តន្ទាទោស ជាដំបូងតុលាការអន្តរជាតិនានា បានពិនិត្យមើលទៅលើភាពធ្ងន់ធ្ងរនៃបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្ត[43]។ កត្តានេះគឺជា "លក្ខណៈវិនិច្ឆ័យផ្អែកលើលទ្ធផលនៃការសាកល្បងជាក់ស្តែង" (litmus test) នៅពេលធ្វើការវាយតម្លៃអំពីការផ្តន្ទាទោសដ៏ត្រឹមត្រូវ[44]។ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ត្រូវបានកំណត់តាមរយៈការពិនិត្យទៅលើលក្ខណៈនៃបទឧក្រិដ្ឋ និងតួនាទីរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មទាំងនោះ។ នៅក្នុងរឿងក្តី *Momir Nikolic* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានបំបែក "ភាពធ្ងន់ធ្ងរនៃបទល្មើស" ឲ្យទៅជាការវាយតម្លៃអំពីវិសាលភាព និងផលប៉ះពាល់នៃសកម្មភាពឧក្រិដ្ឋ (រួមមាន ចំនួនប្រជាជនដែលទទួលរងដោយឧក្រិដ្ឋកម្ម និងព្យសនកម្មដែលបង្កមកលើពួកគេ) ព្រមទាំងតួនាទីរបស់ជនជាប់ចោទនៅក្នុងការប្រព្រឹត្តិសកម្មភាពឧក្រិដ្ឋ (រួមមាន តួនាទីផ្លូវការរបស់គាត់ ព្រមទាំងចរិតលក្ខណៈ និងកាលៈទេសៈដែលតួនាទីនោះត្រូវបានបំពេញ)[45]។

២៧- នៅពេលវាយតម្លៃអំពីលក្ខណៈ និងវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តុលាការអន្តរជាតិ យល់ឃើញថា ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម ការប្រហារជីវិត និងការធ្វើទុក្ខបុកម្នេញមានលក្ខណៈសាហាវយង់ឃ្នង ហើយសមនឹងទទួលបាននូវការផ្តន្ទាទោសកម្រិតខ្ពស់។ ឧទាហរណ៍ក្នុងការសម្រេចផ្តន្ទាទោសកម្រិតខ្ពស់នៅក្នុងរឿងក្តី *Nikolic* តុលាការ ICTY បានដាក់ទម្ងន់គ្រប់គ្រាន់ទៅលើវិសាលភាពនៃអំពើរបស់ *Momir Nikolic* រួមមាន ការទទួលខុសត្រូវឧក្រិដ្ឋកម្មរួម

---

[43] លក្ខន្តិកៈតុលាការ ICTY មាត្រា ២៤(២)។ លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វ៉ាន់ដា ("លក្ខន្តិកៈតុលាការ ICTR") មាត្រា ២៣(២)។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ("លក្ខន្តិកៈតុលាការ SCSL") មាត្រា ១៩(២)។ លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៧៨។

[44] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Dragan Nikolić* សាលក្រមផ្តន្ទាទោស IT-94-2-S របស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ ("សាលក្រមផ្តន្ទាទោស *Dragan Nikolić*") កថាខណ្ឌ ១៤៤។

[45] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Momir Nikolić* សាលក្រមផ្តន្ទាទោស IT-02-60/1-S របស់អង្គជំនុំជម្រះ សាលាដំបូងនៃតុលាការ ICTY ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៣ ("សាលក្រមផ្តន្ទាទោស *Momir Nikolić*") កថាខណ្ឌ ១០៣។

ចំពោះការធ្វើទារុណកម្ម និងការប្រហារជីវិតជនជាតិបូស្នៀកាន់សាសនាអ៊ីស្លាមចំនួនប្រាំពីរពាន់នាក់[46]។ តុលាការបានដាក់ទម្ងន់បន្ថែមទៀតទៅលើអង្គហេតុដែលថាបទឧក្រិដ្ឋរបស់ Momir Nikolic រួមទាំងការធ្វើទុក្ខបុកម្នេញ ដែលតុលាការយល់ឃើញថាជាបទឧក្រិដ្ឋធ្ងន់ធ្ងរយ៉ាងខ្លាំង[47]។ តុលាការ ICTY បានធ្វើសេចក្តីសន្និដ្ឋានស្រដៀងគ្នាមួយនៅក្នុងរឿងក្តី *Dragan Nikolic* ដែលធ្វើយុត្តិកម្មអំពីការផ្តន្ទាទោសកម្រិតខ្ពស់មួយ ដោយសារមានចំនួនជនរងគ្រោះយ៉ាងច្រើន និងអំពើឧក្រិដ្ឋដ៏ច្រើនដែលត្រូវបានប្រព្រឹត្តឡើង[48]។ នៅក្នុងករណីនោះ ជនជាប់ចោទ បានសារភាពថាបានចូលរួមក្នុង ឬទទួលខុសត្រូវចំពោះ អំពើធ្វើទុក្ខបុកម្នេញ មនុស្សឃាត ការរំលោភសេពសន្ថវៈ និងការធ្វើទារុណកម្មលើអ្នកជាប់ឃុំឃាំងជនជាតិបូស្នៀ នៅជំរំឃុំឃាំងដែលស្ថិតនៅក្រោមអំណាចរបស់គាត់[49]។

២៨- នៅក្នុងរឿងក្តី *Bisengimana* តុលាការ ICTR យល់ឃើញថាឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល និងមនុស្សឃាត មានលក្ខណៈសាហាវយង់ឃ្នង ដែលសមនឹងទទួលបានការផ្តន្ទាទោសរយៈពេលយូរ[50]។ តុលាការនេះ បានដាក់ទម្ងន់គ្រប់គ្រាន់ទៅលើសំអាងហេតុមួយ ដែលវិសាលភាពនៃបទឧក្រិដ្ឋបានដាក់បញ្ចូលនូវការប្រហារជីវិតជនស៊ីវិលជាច្រើនពាន់នាក់[51]។ ចុងក្រោយ តុលាការបានកត់សម្គាល់ថា វិសាលភាព និងផលប៉ះពាល់នៃបទឧក្រិដ្ឋមិនត្រូវកំណត់ត្រឹមតែការប្រហារជីវិតប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងការធ្វើទារុណកម្មផ្លូវកាយ និងផ្លូវចិត្ត ដែលជនរងគ្រោះនៃសកម្មភាពឧក្រិដ្ឋបានទទួលរង[52]។

---

[46] សាលក្រមផ្តន្ទាទោស *Momir Nikolić* កថាខណ្ឌ ១២១។

[47] សាលក្រមផ្តន្ទាទោស *Momir Nikolić* កថាខណ្ឌ ១០៥។

[48] សាលក្រមផ្តន្ទាទោស *Dragan Nikolić* កថាខណ្ឌ ២១៣។

[49] សាលក្រមផ្តន្ទាទោស *Dragan Nikolić* កថាខណ្ឌ ៦៥-១០៥។

[50] សាលក្រមលើរឿងក្តី *Bisengimana* កថាខណ្ឌ ១១២។

[51] សាលក្រមលើរឿងក្តី *Bisengimana* កថាខណ្ឌ ១១២។

[52] សាលក្រមលើរឿងក្តី *Bisengimana* កថាខណ្ឌ ១១៨។

00613473



២៩- នៅពេលដែលបទឧក្រិដ្ឋទាំងឡាយដែលត្រូវបានប្រព្រឹត្ត មានលក្ខណៈធ្ងន់ធ្ងរជាពិសេស ដូចនៅក្នុងករណីរបស់ចុងបណ្តឹងសាទុក្ខនោះ តុលាការឧក្រិដ្ឋកម្មអន្តរជាតិប្រកាសផ្តន្ទាទោសធ្ងន់ធ្ងរបំផុតឲ្យសមទៅនឹងបទឧក្រិដ្ឋទាំងនោះ។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតលើ Stanislav Galic ដែលត្រូវបានផ្តន្ទាទោសចំពោះអំពើហិង្សាតាមរយៈការអនុវត្តនូវយុទ្ធនាការវាយប្រហារបាញ់ផ្លោងដោយកាំភ្លើងធំ និងពួនស្នាក់បាញ់ប្រហារដែលបណ្តាលឲ្យមានការសម្លាប់ជនស៊ីវិលរាប់រយនាក់ និងបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៤០ឆ្នាំ លើ Milomir Stakic ដែលត្រូវបានរកឃើញថាទទួលខុសត្រូវចំពោះអំពើមនុស្សឃាត និងការប្រហារជីវិតប្រជាជនជាង ១៧០០ នាក់[53]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំនួនបួន លើឈ្មោះ Clément Kayishema ដែលត្រូវបានរកឃើញថាមានពិរុទ្ធចំពោះអំពើប្រល័យពូជសាសន៍ និងផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំនួនបីទៀតលើឈ្មោះ Mikaeli Muhimana ដែលត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ រំលោភសេពសន្ថវៈ និងមនុស្សឃាត ដែលបណ្តាលឲ្យបាត់បង់អាយុជីវិតជនជាតិទុតស៊ី(Tutsis) រាប់រយនាក់[54]។ តុលាការ SCSL បានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៥២ឆ្នាំ លើឈ្មោះ Issa Hassan Sesay ជាមេដឹកនាំស្តីទីនៃរណសិរ្សបង្រួបបង្រួមបដិវត្តសេរ៉ាឡេអូន ដែលត្រូវបានរកឃើញថាមានពិរុទ្ធចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមផ្សេងៗទៀត និងបានផ្តន្ទាទោសដាក់ពន្ធនាគារ ៥០ឆ្នាំ លើឈ្មោះ Alex Tamba Brima ជាទាហាននៅក្នុងក្រុមប្រឹក្សាបដិវត្តន៍កងកម្លាំងប្រដាប់អាវុធ ដែលត្រូវបានរកឃើញថា

---

[53] សាលដីកាលើរឿងក្តី *Galic* ។ សាលដីកាលើរឿងក្តី *Staki□* ។

[54] សាលដីកាលើរឿងក្តី *Kayishema* ។ សាលដីកាលើរឿងក្តី *Muhimana* ។

មានពិរុទ្ធចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមផ្សេងៗទៀត រួមទាំងឧក្រិដ្ឋកម្មនៃការប្រើប្រាស់ទាហានដែលជាកុមារ[55]។

### ឃ.២.១.២ លទ្ធផលរកឃើញ

៣០- អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្ដីនេះ បានយល់ស្របជាមួយសហព្រះរាជអាជ្ញាថា នៅក្នុងការថ្លឹងថ្លែងអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម អង្គជំនុំជម្រះគួរពិចារណាអំពីតួនាទីរបស់ចុងបណ្ដឹងសាទុក្ខក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ផលវិបាកនៃបទឧក្រិដ្ឋចំពោះជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ និងកាលៈទេសៈជាឯកត្តបុគ្គលរបស់ចុងបណ្ដឹងសាទុក្ខ[56]។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ខ្លួនបានរកឃើញថា ចុងបណ្ដឹងសាទុក្ខ គឺជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះ "ឧក្រិដ្ឋកម្មនានា ដែលមានលក្ខណៈសាហាវយង់ឃ្នង និងគួរឱ្យភ័យខ្លាច"[57]។ អង្គជំនុំជម្រះបានរកឃើញថា ក្នុងឋានៈជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស-២១ ចុងបណ្ដឹងសាទុក្ខបានរៀបចំចាត់ចែង និងពង្រឹងប្រព័ន្ធគ្រប់គ្រងមួយអស់រយៈពេលជាងបីឆ្នាំ ដែលបណ្ដាលឱ្យមានការសម្លាប់ជីវិតមនុស្សមិនតិចជាង ១២២៧២ នាក់ ហើយភាគច្រើនក្នុងចំណោមជនរងគ្រោះទាំងនោះ ត្រូវបានគេធ្វើទារុណកម្មតាមលក្ខណៈជាប្រព័ន្ធផងដែរ[58]។ ជនរងគ្រោះទាំងឡាយដែលមិនត្រូវបានគេសម្លាប់ ក៏បានស្លាប់ដោយសារតែលក្ខខណ្ឌនៃការឃុំខ្លួន រួមមាន ការកើតជំងឺរាលដាលពាសពេញ កង្វះអាហារ និងការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្ត និងការភ័យខ្លាចហួសប្រមាណ[59]។ មានតែអ្នកជាប់ឃុំមួយចំនួនតូចតែប៉ុណ្ណោះដែលនៅរស់រានមានជីវិតពីមន្ទីរស-២១។ អ្នករស់រានមានជីវិតខ្លះក្នុងចំណោម

[55] សាលដីកាលើរឿងក្ដី *Sesay* ។ សាលដីកាលើរឿងក្ដី *Brima*។

[56] សាលក្រម កថាខណ្ឌ ៥៩៦។

[57] សាលក្រម កថាខណ្ឌ ៥៩៧។

[58] សាលក្រម កថាខណ្ឌ ៥៩៧។

[59] សាលក្រម កថាខណ្ឌ ៥៩៧។

00613475



អ្នករស់រានមានជីវិតពីមន្ទីរ ស-២១ទាំងនោះ បានផ្តល់សក្ខីកម្មផ្ទាល់នៅពេលសវនាការអំពីផលវិបាកនៃឧក្រិដ្ឋកម្មដែលធ្វើឲ្យមានការឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្ត[60]។ សាច់ញាតិ ក្រុមគ្រួសាររបស់អ្នកជាប់ឃុំដែលបានស្លាប់ ក៏បានផ្តល់សក្ខីកម្មអំពីទុក្ខវេទនានិរាសព្រាត់ប្រាស់ ដែលជាបច្ច័យនៃឧក្រិដ្ឋកម្ម របស់ចុងចោទបណ្តឹងសាទុក្ខមកលើក្រុមគ្រួសាររបស់ពួកគេ[61]។

៣១- អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ចុងចោទបណ្តឹងសាទុក្ខបានធ្វើការដោយមិនខ្លាចនឿយហត់ដើម្បីធានាថា មន្ទីរស-២១ ដំណើរការប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន ហើយគាត់បានធ្វើដូច្នេះដើម្បីបង្ហាញពីភក្តីភាពដ៏មោះមុតចំពោះថ្នាក់លើរបស់គាត់ និងមនោគមវិជ្ជាបក្ស ដោយមិនបានគិតអំពីអ្នកជាប់ឃុំទាំងឡាយដែលគាត់បានមើលការខុសត្រូវនោះឡើយ[62]។ ក្រោមការត្រួតត្រារបស់គាត់ ស-២១ បានក្លាយជាឧបករណ៍ប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត នៃការធ្វើទុក្ខបុកម្នេញក្នុងការលើកតម្កើងគោលនយោបាយឧក្រិដ្ឋ ដែលមានហេតុផលនយោបាយរបស់បក្សនៃការរើសអើង[63]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ចុងចោទបណ្តឹងសាទុក្ខគឺជាមនុស្សដែលមានប្រាជ្ញាឈ្លាសវៃ និងមានការអប់រំ ដែលបានយល់យ៉ាងច្បាស់អំពីចរិតលក្ខណៈនៃអំពើរបស់គាត់នៅពេលនោះ[64]។

### ឃ.២.១.៣ ការភាន់ច្រឡំ

៣២- ការពិពណ៌នារបស់អង្គជំនុំជម្រះសាលាដំបូង អំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្មរបស់ចុងចោទបណ្តឹងសាទុក្ខ ឆ្លុះបញ្ចាំងឲ្យឃើញថា ទាំងនេះគឺជាឧក្រិដ្ឋកម្មដែលស្ថិតនៅចំណុចកំពូលដ៏អាក្រក់បំផុត។ បទឧក្រិដ្ឋ

---

[60] សាលក្រម កថាខណ្ឌ ៥៩៨។
[61] សាលក្រម កថាខណ្ឌ ៥៩៨។
[62] សាលក្រម កថាខណ្ឌ ៥៩៧។
[63] សាលក្រម កថាខណ្ឌ ៥៩៧។
[64] សាលក្រម កថាខណ្ឌ ៥៩៩។

នានាត្រូវបានប្រព្រឹត្តឡើងអស់រយៈពេលជាងបីឆ្នាំ ពីសំណាក់មេបញ្ជាការជំរំដែលមានភាពវៃឆ្លាត មានការលះបង់ និងដោយស្ម័គ្រចិត្ត។ បុរស ស្ត្រី និងកុមាររាប់ពាន់នាក់ គឺជាជនរងគ្រោះរបស់គាត់។ ផ្អែកទៅលើការរកឃើញថា ឧក្រិដ្ឋកម្មរបស់ចុងបណ្តឹងសាទុក្ខ គឺមានលក្ខណៈធ្ងន់ធ្ងរណាស់[65] អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការមិនបានដាក់ទោសកម្រិតធ្ងន់បំផុតដែលអង្គជំនុំជម្រះអាចធ្វើបាន នៅក្រោមច្បាប់ អ.វ.ត.ក គឺទោសជាប់ពន្ធនាគារអស់មួយជីវិត។

៣៣- ការផ្តន្ទាទោស ត្រូវតែឆ្លុះបញ្ចាំងទាំងកាលៈទេសៈពិសេសនៃបទល្មើស និងតួនាទី ព្រមទាំងការទទួលខុសត្រូវរបស់ជនជាប់ចោទ[66]។ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានកត់សម្គាល់អំពីយុត្តិសាស្ត្រអន្តរជាតិ ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាថា ស្ថានទម្ងន់នៃបទល្មើសគឺជាកត្តាដ៏សំខាន់ក្នុងការសម្រេចផ្តន្ទាទោស[67]។ យុត្តិសាស្ត្រនេះបង្ហាញថា វាគឺជាកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការកំណត់ជាបឋមអំពីកម្រិតទោស ដោយផ្អែកទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងស្ថានទម្ងន់ទោសផ្សេងៗទៀត។ តុលាការ ICTY បានសម្រេចថា "ស្ថានសម្រាលទោសអាចនាំឲ្យមានការកែប្រែការផ្តន្ទាទោស ដែលនឹងត្រូវបានអនុវត្តទៅលើជនជាប់ចោទ"[68]។ ដូច្នេះ គឺមានតែបន្ទាប់ពីការសម្រេចផ្តន្ទាទោសតែប៉ុណ្ណោះ ដែលអង្គជំនុំជម្រះសាលាដំបូង អាចពិចារណាទៅលើស្ថានសម្រាលទោស ដែលអាចនាំឲ្យមានការកាត់បន្ថយទោស។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៣៥ឆ្នាំ ដោយមិនបានផ្តល់នូវការពន្យល់ណាមួយឡើយចំពោះចំណុចចាប់ផ្តើមរបស់ខ្លួន វិសាលភាពនៃការកាត់

---

[65] សាលក្រម កថាខណ្ឌ ៦០០។

[66] សាលដីកាលើរឿងក្តី *Galić* កថាខណ្ឌ ៤០៩។

[67] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៣៦៨-៣៨៦។

[68] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Bralo* សាលក្រមផ្តន្ទាទោស IT-95-17 របស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៥ កថាខណ្ឌ ៤២។

00613477



បន្ថយទោស និងស្ថានសម្រាលទោស ដែលអង្គជំនុំជម្រះបានយកមកពិចារណានៅក្នុងការធ្វើការកាត់បន្ថយនោះ។

៣៤- ក្រៅពីការសម្រេចដោយឯកឯងអំពីការផ្តន្ទាទោសចំនួន ៣៥ឆ្នាំ នោះ អង្គជំនុំជម្រះសាលាដំបូងមិនបានដាក់ទម្ងន់ទោសឱ្យបានគ្រប់គ្រាន់ទៅលើភាពធ្ងន់ធ្ងរជាសត្យានុម័តនៃឧក្រិដ្ឋកម្ម ចំពោះការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រមទាំងមនុស្សឃាតដោយចេតនា ទារុណកម្ម ឬការប្រព្រឹត្តិដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ និងសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសប្រកបដោយយុត្តិធម៌ និងប្រក្រតី និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ ឧក្រិដ្ឋកម្មទាំងនេះ តំណាងឱ្យមជ្ឈដ្ឋានទាំងមូលនៃឧក្រិដ្ឋកម្មនានាដែលចុងបណ្តឹងសាទុក្ខអាចត្រូវបានចោទប្រកាន់ក្រោមច្បាប់ អ.វ.ត.ក។ អង្គជំនុំជម្រះសាលាដំបូងធានាឱ្យមានការផ្តន្ទាទោសកម្រិតខ្ពស់បំផុត ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានដាក់ទោសកម្រិតនេះឡើយ។

### *ឃ.២.២ កាលៈទេសៈនីមួយៗរបស់ចុងបណ្តឹងសាទុក្ខ*

#### ឃ.២.២.១ ច្បាប់

៣៥- លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀត ចែងថា "នៅក្នុងការដាក់ទោស អង្គជំនុំជម្រះសាលាដំបូង គួរតែពិចារណាលើកត្តានានា ដូចជា [...] កាលៈទេសៈនីមួយៗរបស់ជនជាប់ចោទ"[69]។

---

[69] លក្ខន្តិកៈតុលាការ ICTY មាត្រា២៤(២)។ លក្ខន្តិកៈតុលាការ ICTR មាត្រា២៣(២)។ លក្ខន្តិកៈតុលាការSCSLមាត្រា ១៩(២)។

00613478



ដូច្នេះនៅពេលធ្វើការពិនិត្យទៅលើតួនាទីរបស់ជនជាប់ចោទ តុលាការពិនិត្យលើភាពអត្តនោម័តរបស់ជនជាប់ចោទ និងការរួមចំណែករបស់ពួកគេទៅនឹងឧក្រិដ្ឋកម្មនានា ដែលពួកគេត្រូវបានកាត់ទោស។

៣៦- តុលាការ ICTY បានបកស្រាយអំពីតួនាទីរបស់ជនជាប់ចោទថា មានសារៈសំខាន់ដែលពាក់ព័ន្ធនៅក្នុងការអនុវត្តសកម្មភាពឧក្រិដ្ឋ។ វាមិនចាំបាច់ឡើយដែលជនជាប់ចោទត្រូវបានចាត់ទុកថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ទាក់ទិននឹងសកម្មភាពឧក្រិដ្ឋចំពោះតួនាទីរបស់គាត់ ដើម្បីពិចារណាថាជាស្ថានទម្ងន់ទោសនៅក្នុងការផ្តន្ទាទោសនោះ។ តាមពិត នៅក្នុងករណីយុត្តិសាស្ត្រតុលាការ ICTY តួនាទីរបស់ជនជាប់ចោទ ដែលបានបំពេញការងារស្រដៀងគ្នាទៅនឹងតួនាទីរបស់ចុងបណ្តឹងសាទុក្ខ ពោលគឺជាប្រធានជំរំឃុំឃាំង ឬកាន់តួនាទីស៊ើបការណ៍សម្ងាត់ និងសន្តិសុខដ៏សំខាន់ត្រូវបានពិចារណាថាជាស្ថានទម្ងន់ នៅក្នុងការផ្តន្ទាទោសជនជាប់ចោទ។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Dragan Nikolic* តុលាការសម្រេចថា ការផ្តន្ទាទោសជនជាប់ចោទគួរតែត្រូវបានបន្ថែមទៀត ដោយសារតែអង្គហេតុដែលថាគាត់បានកាន់តួនាទីជាមេបញ្ជាការនៅជំរំឃុំឃាំង Sušica ដែលនៅទីនោះគាត់ទទួលបន្ទុកគ្រប់គ្រងបុគ្គលិក ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន ទារុណកម្ម និងមនុស្សឃាត[70]។ តុលាការបានរកឃើញថា បទល្មើសរបស់ Dragan Nikolic" មានលក្ខណៈធ្ងន់ធ្ងរជាង ពីព្រោះគាត់មិនត្រឹមតែអនុវត្តតាមបញ្ជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជួយជ្រោមជ្រែងយ៉ាងសកម្មដល់សកម្មភាពឧក្រិដ្ឋ តាមរយៈការរៀបចំ និងសម្របសម្រួលក្នុងការឃុំខ្លួន និងប្រហារជីវិតជនរងគ្រោះ និងដោយសារគាត់បានប្រព្រឹត្តបទឧក្រិដ្ឋ ប្រកបដោយប្រសិទ្ធភាពតាមវិធីសាស្ត្រ និងធ្វើឱ្យមានភាពភ័យខ្លាច ដែលបានបង្ហាញឱ្យឃើញនូវការមិនគោរពទាំងស្រុងចំពោះមនុស្ស

---

[70] សាលក្រមផ្តន្ទាទោស *Dragan Nikolic* កថាខណ្ឌ ១៧៩។

ជាតិ[71]។ នៅក្នុងរឿងក្តី *Momir Nikolic* តុលាការ ICTY បានសម្រេចថា នៅពេលដែលជនជាប់ចោទកំពុងអនុវត្តបញ្ជារបស់ថ្នាក់លើគាត់ តួនាទីរបស់គាត់ជាជំនួយការមេបញ្ជាការ និងជាប្រធានផ្នែកសន្តិសុខ និងស៊ើបការណ៍សម្ងាត់ បានដាក់ឲ្យគាត់ស្ថិតនៅក្នុងតួនាទីមួយដែលមានអំណាច ដូច្នេះហើយ គាត់បានបានដើរតួយ៉ាងសំខាន់មួយនៅក្នុងការអនុវត្ត "ប្រតិបត្តិការធ្វើមនុស្សឃាត"[72]។ ដូច្នេះ តុលាការបានរកឃើញថា អង្គហេតុនេះគឺជាស្ថានទម្ងន់នៅក្នុងការផ្តន្ទាទោស[73]។ នៅក្នុងរឿងក្តី *Jelisic* តុលាការ ICTY ក៏បានធ្វើយុត្តិកម្មផងដែរចំពោះទោសកម្រិតខ្ពស់ ដោយផ្អែកទៅលើការរកឃើញដែលថា "លក្ខណៈដ៏សាហាវបំផុតគ្មានមេត្តា ដែលការប្រហារជីវិតត្រូវបានធ្វើឡើងនោះ បានបង្ហាញ [ថាជនជាប់ចោទបាន] ប្រព្រឹត្តបទឧក្រិដ្ឋរបស់គាត់ដោយក្តីពេញចិត្ត"[74]។

៣៧- នៅក្នុងរឿងក្តី *Kambanda* តុលាការ ICTR យល់ឃើញថា តួនាទីជាអ្នកដឹកនាំរបស់ជនជាប់ចោទគឺជាស្ថានទម្ងន់មួយ[75]។ នៅក្នុងរឿងក្តី *Bisengimana* តុលាការ ICTR បានលើកឡើងនូវករណីមួយដែលជនជាប់ចោទ បានកាន់តួនាទីជាអ្នកដឹកនាំរបស់រដ្ឋាភិបាលក្នុងប្រទេសម្នាក់នៅក្នុងភូមិមួយ ដែលអ្នកប្រយុទ្ធហ៊ូទូដែលស្ថិតនៅក្រោមអំណាចរបស់គាត់ បានសម្លាប់រង្គាលជនស៊ីវិលទុតស៊ីមួយក្រុម[76]។ ទោះបីជាគាត់មិនបានចូលរួម ឬក៏បញ្ជាឲ្យមានឧក្រិដ្ឋកម្មទាំងនោះក៏ដោយ តុលាការនៅតែយល់ឃើញថា គាត់បានដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងការប្រហារជីវិត ពីព្រោះ

---

71 សាលក្រមផ្តន្ទាទោស *Dragan Nikolić* កថាខណ្ឌ ២១៣។

72 សាលក្រមផ្តន្ទាទោស *Momir Nikolić* កថាខណ្ឌ ១៣៥។

73 សាលក្រមផ្តន្ទាទោស *Momir Nikolić* កថាខណ្ឌ ១៣៥។

74 រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Jelisić* សាលក្រម IT-95-10-T របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ ("សាលក្រមលើរឿងក្តី *Jelisić*") កថាខណ្ឌ ១៣០-១៣១។

75 រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kambanda* សាលក្រមផ្តន្ទាទោស ICTR-97-23-S របស់តុលាការសាលាដំបូងនៃតុលាការ ICTR ចុះថ្ងៃទី៤ សីហា ឆ្នាំ១៩៩៨ ("សាលក្រមផ្តន្ទាទោស *Kambanda*") កថាខណ្ឌ ៦១-៦២។

76 សាលក្រមលើរឿងក្តី *Bisengimana* កថាខណ្ឌ ១២០។

ការខកខានរបស់គាត់មិនបានទប់ស្កាត់ពួកគេ បានរំលោភលើកាតព្វកិច្ចរបស់គាត់ក្នុងការការពារសមាសភាពជនជាតិទុតស៊ីរបស់គាត់ ហើយភាពស្ងៀមស្ងាត់របស់គាត់ បានលើកទឹកចិត្តដល់អ្នកប្រយុទ្ធហ៊ូទូ អោយអនុវត្តឧក្រិដ្ឋកម្មទាំងនោះ[77]។ ដូច្នេះ តុលាការបានរកឃើញថា តួនាទីរបស់ជនជាប់ចោទបានបង្ហាញយុត្តិកម្មចំពោះទោសកម្រិតខ្ពស់។

៣៨- ស្រដៀងគ្នានេះដែរ នៅក្នុងការសម្រេចអំពីកម្រិតនៃការផ្តន្ទាទោស តុលាការឧក្រិដ្ឋកម្មអន្តរជាតិពិចារណាទៅលើ "អាយុ ការអប់រំ ស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ពិរុទ្ធជន"[78]។ លើសពីនេះទៀត តុលាការអន្តរជាតិ បានរកឃើញថា ការអប់រំកម្រិតឧត្តមសិក្សារបស់ជនជាប់ចោទ គឺជាស្ថានទម្ងន់ នៅក្នុងការផ្តន្ទាទោស ពីព្រោះវាគួរតែអាចឲ្យគាត់យល់ដឹងអំពី "សេចក្តីថ្លៃថ្នូរ និងតម្លៃនៃជីវិតមនុស្ស និងដឹងអំពីតម្រូវការសម្រាប់ការរួមរស់នៅជាមួយគ្នាដោយសន្តិភាពរវាងសហគមន៍និងសហគមន៍"[79] ព្រមទាំងទទួលស្គាល់នូវ "សារៈសំខាន់ និងផលវិបាកនៃអំពើរបស់គាត់"[80]។

### ឃ.២.២.២ លទ្ធផលរកឃើញ

៣៩- អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ឌុចបណ្តឹងសាទុក្ខគឺជាមនុស្សដែលមានប្រាជ្ញាឈ្លាសវៃ និងមានការអប់រំ ដែលគាត់បម្រើការងារក្នុងតួនាទីជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស-២១ បានយល់យ៉ាងច្បាស់អំពីចរិតលក្ខណៈនៃអំពើរបស់គាត់ និងឧក្រិដ្ឋកម្មនានាដែលគាត់បាន

---

[77] សាលក្រមលើរឿងក្តី *Bisengimana* កថាខណ្ឌ ១២០។

[78] វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ("វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងនៃតុលាការ ICC") វិធាន ១៤៥(១)(គ)។ នៅក្នុងវិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងនៃតុលាការ ICTY, ICTR និង SCSL កត្តានេះមិនត្រូវបានបញ្ជាក់ឲ្យបានច្បាស់លាស់ទេ។

[79] សាលក្រមលើរឿងក្តី *Bisengimana* កថាខណ្ឌ ១២០។

[80] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Brđanin* សាលក្រម IT-99-36-T អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ ("សាលក្រមលើរឿងក្តី *Brđanin*") កថាខណ្ឌ ១១១៤។

00613481



ប្រព្រឹត្តនៅមន្ទីរ ស-២១[81]។ គាត់បានធ្វើការដោយមិនខ្លាចនឿយហត់ដើម្បីធានាថាមន្ទីរស-២១ ដំណើរការប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន ហើយគាត់បានធ្វើដូច្នេះ ដើម្បីបង្ហាញពីភក្តីភាពដ៏មោះមុតចំពោះថ្នាក់លើរបស់គាត់ និងមនោគមវិជ្ជារបស់បក្ស[82]។

៤០- អ្នកជំនាញផ្នែកចិត្តសាស្ត្របានរកឃើញថា ចុងបណ្តឹងសាទុក្ខ "ជាមនុស្សវៃឆ្លាត មានការចងចាំបានល្អ ព្រមទាំងមានការប្រយ័ត្នប្រយែង ម៉ឺងម៉ាត់ មានភាពល្អិតល្អន់ និងជាមនុស្សងប់ងល់នឹងការងារ"[83]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របជាមួយនឹងការវាយតម្លៃនេះ ដោយវាក៏បាន "បង្ហាញឱ្យអង្គជំនុំជម្រះបានឃើញនៅក្នុងអំឡុងពេលសវនាការ"[84] ផងដែរ។

៤១- អ្នកជំនាញផ្នែកចិត្តសាស្ត្រ បានពិពណ៌នា ហើយអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់យ៉ាងត្រឹមត្រូវថា ចុងបណ្តឹងសាទុក្ខ ជាបុគ្គល "គ្មានមនោសញ្ចេតនាចំពោះអ្នកដទៃ" ដែលអាច "បង្កើតនូវយន្តការការពារដ៏រឹងមាំដែលជួយទប់ទល់គាត់មិនឱ្យមានប្រតិកម្មផ្លូវអារម្មណ៍ និងការប៉ះទង្គិចខាងក្នុងខ្លួនដែលបណ្តាលមកពីតថភាពខាងក្រៅរបស់គាត់"[85]។ ពួកគាត់បានពិពណ៌នា យន្តការទាំងនេះថា ជាមូលដ្ឋានអាចឱ្យចុងបណ្តឹងសាទុក្ខអាចចិញ្ចឹមបីបាច់ក្រុមគ្រួសាររបស់គាត់ ដោយមិនមានការខ្វាយខ្វល់អំពីសេចក្តីស្លាប់របស់កុមារនៅមន្ទីរស-២១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់នោះទេ[86]។ លើសពីនេះទៀត ដោយបានស្ថិតនៅក្រោមការជាប់ពន្ធនាគារដោយសារមូលហេតុនយោបាយ[87] ចុងបណ្តឹងសារទុក្ខអាចយល់ដឹងអំពីអំពើអមនុស្សធម៌ និងខុសសីលធម៌នៃ

[81] សាលក្រម កថាខណ្ឌ ៥៩៩។
[82] សាលក្រម កថាខណ្ឌ ៥៩៧។
[83] សាលក្រម កថាខណ្ឌ ៦១៥។
[84] សាលក្រម កថាខណ្ឌ ៦១៥។
[85] សាលក្រម កថាខណ្ឌ ៦១៤។
[86] សាលក្រម កថាខណ្ឌ ៦១៤។
[87] សាលក្រម កថាខណ្ឌ ១១៣។

ការដាក់ក្នុងពន្ធនាគារ ការធ្វើទារុណកម្ម និងការប្រហារជីវិតក្រៅច្បាប់ទៅលើបុគ្គលដែលជាជនស្លូតត្រង់។ ប៉ុន្តែ គាត់មិនបានបង្ហាញពីភាពអាណិតអាសូរឡើយ ដោយអះអាងថា "ការងាររបស់ខ្ញុំផ្សេង ការងារគេផ្សេង"[88]។

៤២- សាវតាររបស់ចុងចោទកាំងហ្គេកអ៊ាវជាគ្រូបង្រៀនម្នាក់ ធ្វើឲ្យលក្ខណៈដ៏អាក្រក់នៃឧក្រិដ្ឋកម្មរបស់គាត់ខ្ពស់ឡើងទៀត និងបានបង្ហាញឲ្យឃើញថា គាត់បានក្បត់នូវសេចក្ដីទុកចិត្តដែលសហគមន៍របស់គាត់មានចំពោះគាត់។ គាត់បានយល់អំពីអានុភាពនៃការអប់រំ ជាពិសេសមានឥទ្ធិពលទៅលើយុវជនក្មេងៗ។ នៅពេលសវនាការ អ្នកជំនាញបានផ្ដល់សក្ខីកម្មថា ចុងចោទកាំងហ្គេកអ៊ាវ "បានទទួលនូវការបណ្ដុះបណ្ដាលអំពីចិត្តគរុវិជ្ជា ហើយដែលក្នុងនោះហើយ ដែលអាចធ្វើឲ្យគាត់យល់មួយចំណែកដែរ អំពីបញ្ហាចិត្តសាស្ត្ររបស់កុមារ កុមារវ័យជំទង់ និងមនុស្សពេញវ័យ"[89]។ បញ្ហានេះទាក់ទិនជាពិសេសនៅក្នុងបរិបទនៃការបំពាក់បំប៉នរបស់ចុងចោទកាំងហ្គេកអ៊ាវ ទៅលើកុមារ និងមនុស្សដែលមានវ័យក្មេង ដែលជាអ្នកយាម អ្នកសួរចម្លើយ អ្នកធ្វើទារុណកម្ម និងពេជ្ឈឃាតនៅមន្ទីរស-២១ ដែលជាទិដ្ឋភាពដ៏អសីលធម៌បំផុតមួយនៃអំពើរបស់គាត់។

### ឃ.២.២.៣ ការភាន់ច្រឡំ

៤៣- ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង មានវិការៈ ដោយការដាក់ទោសមិនបានត្រឹមត្រូវ និងមានលក្ខណៈស្រាល ទៅលើចុងចោទកាំងហ្គេកអ៊ាវ ដោយមិនពិចារណាអំពីកាលៈទេសៈជាក់លាក់របស់គាត់នៅក្នុងការសម្រេចផ្ដន្ទាទោសនោះ។ ដូចដែលបានគូសបញ្ជាក់ពីខាងលើ វាគឺជាកាតព្វកិច្ចរបស់អង្គជំនុំ

---

[88] សាលក្រម កថាខណ្ឌ ១២២។

[89] ប្រតិចារឹកសវនាការ Fran–oise Sironi-Guilbard និង កា ស៊ុនបូណាត ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ប្រតិចារឹក ៣៣។

ជម្រះសាលាដំបូង ដើម្បីធ្វើការកំណត់ជាបឋមអំពីចំនួនទោស ដោយផ្អែកតែទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ កាលៈទេសៈរបស់ចុងបណ្តឹងសាទុក្ខ និងស្ថានទម្ងន់ផ្សេងៗទៀតប៉ុណ្ណោះ។ គឺមានតែបន្ទាប់ពីការសម្រេចផ្តន្ទាទោសតែប៉ុណ្ណោះ ដែលអង្គជំនុំជម្រះសាលាដំបូងអាចពិចារណាទៅលើស្ថានសម្រាល។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយឯកឯងក្នុងការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល៣៥ឆ្នាំ ដោយមិនបានផ្តល់នូវការបង្ហាញណាមួយឡើយចំពោះចំណុចចាប់ផ្តើមរបស់ខ្លួន វិសាលភាពនៃការកាត់បន្ថយទោស និងស្ថានសម្រាល ដែលអង្គជំនុំជម្រះបានយកមកពិចារណានៅក្នុងការធ្វើការកាត់បន្ថយនោះ។

### ឃ. ២.៣ ស្ថានទម្ងន់

### ឃ. ២.៣.១ ច្បាប់

៤៤- ដោយហេតុថាវិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិចែងអំពីស្ថានទម្ងន់ជាច្រើន ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងយកមកពិចារណាក្នុងការផ្តន្ទាទោស[90] មានការចែងដ៏តិចតួចបំផុតនៅក្នុងវិធាននានារបស់តុលាការអន្តរជាតិផ្សេងៗទៀត[91]។ អង្គជំនុំជម្រះសាលាដំបូង ជាទូទៅ រក្សានូវឆន្ទានុសិទ្ធិដ៏ធំធេងនៅក្នុងការពិចារណាទៅលើកត្តាអ្វីខ្លះ និងទម្ងន់ដាក់ទៅលើកត្តាទាំងនោះ ចំពោះអង្គហេតុនៃករណីនីមួយៗ និងពិរុទ្ធភាពរបស់ជនជាប់ចោទ[92]។

---

[90] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៧៨។ ។ វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងនៃតុលាការ ICC មាត្រា ១៤៥(២)។

[91] លក្ខន្តិកៈតុលាការ ICTY មាត្រា ២៤។ លក្ខន្តិកៈតុលាការ ICTR មាត្រា ២៣។ លក្ខន្តិកៈតុលាការ SCSL មាត្រា ១៩។ វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងនៃតុលាការ ICTY") វិធាន ១០១។ វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាង តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា, ("វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងនៃតុលាការ ICTR") វិធាន ១០១។ វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ("វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងនៃតុលាការ SCSL") វិធាន ១០១។

[92] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Blaskic សាលក្រម* IT-95-14-A របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ចុះថ្ងៃ

### ឃ. ២.៣.២ លទ្ធផលរកឃើញ

៤៥- នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង បានយល់ស្របជាមួយសហព្រះរាជអាជ្ញាថា អង្គជំនុំជម្រះ អាចពិចារណាលើកត្តាមួយចំនួននៃស្ថានទម្ងន់ទោស ដូចខាងក្រោមនៅពេលសម្រេចអំពីទោសរបស់ចុងចោទ ៖ (១) ការបំពានលើសិទ្ធិអំណាច ឬមុខនាទីជាផ្លូវការរបស់ចុងចោទ (២) ភាពឃោរឃៅព្រៃផ្សៃនៃឧក្រិដ្ឋកម្មនានារបស់គាត់ (៣) ភាពគ្មានទីពឹងនៃជនរងគ្រោះ និង (៤) ចេតនារើសអើងដើម្បីប្រព្រឹត្តបទឧក្រិដ្ឋ[93]។

៤៦- អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ចុងចោទបានអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ដោយការបំពាក់បំប៉នមនោគមវិជ្ជា ការបង្រៀន និងការគ្រប់គ្រងទៅលើបុគ្គលិកក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកជាប់ឃុំនៅមន្ទីរស២១[94]។ អង្គជំនុំជម្រះបានរកឃើញទៀតថា បុគ្គលិកមន្ទីរស-២១ ជាច្រើនមានវ័យក្មេងៗ និងត្រូវបានបំពុលស្មារតីដោយការតម្រូវឲ្យក្មេងៗទាំងនោះប្រព្រឹត្តអំពើយ៉ាងសាហាវព្រៃផ្សៃបំផុតទៅលើអ្នកជាប់ឃុំ[95]។ អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថា ទោះបីជាអង្គជំនុំជម្រះបានផ្តន្ទាទោសចុងចោទ ដោយផ្អែកទៅលើទម្រង់នៃការទទួលខុសត្រូវដោយផ្ទាល់របស់គាត់ចំពោះបទល្មើសជាច្រើនក៏ដោយក៏តួនាទីជាថ្នាក់លើរបស់ចុងចោទទៅលើកម្មាភិបាលមន្ទីរស-២១ ដែលបង្កើតបានជាផ្នែកមួយនៃស្ថានទម្ងន់ទោសចំពោះបទឧក្រិដ្ឋទាំងនោះដែរ[96]។

---

ទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៦៨៥។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Jelisic* សាលក្រម IT-95-10-A របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០១ ("សាលដីកាលើរឿងក្តី *Jelisic*") កថាខណ្ឌ ១០០។

[93] សាលក្រម កថាខណ្ឌ ៦០១។

[94] សាលក្រម កថាខណ្ឌ ៦០២។

[95] សាលក្រម កថាខណ្ឌ ៦០២។

[96] សាលក្រម កថាខណ្ឌ ៦០២។

៤៧- អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា បទឧក្រិដ្ឋជាច្រើនដែលប្រព្រឹត្តនៅមន្ទីរស២១ ត្រូវបានប្រព្រឹត្តដោយមានលក្ខណៈឃោរឃៅ[97]។ អ្នកជាប់ឃុំគឺជាកម្មវត្ថុនៃការប្រើប្រាស់វិធីធ្វើទារុណកម្មដ៏ព្រៃផ្សៃ ហើយក្នុងករណីខ្លះត្រូវបានគេវាយរហូតដល់ស្លាប់[98]។ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញយ៉ាងត្រឹមត្រូវថា ចំនួនជនរងគ្រោះនៃបទឧក្រិដ្ឋទាំងនេះនៅមន្ទីរស២១ មានមិនតិចជាង ១២២៧៣ នាក់ ឡើយ ដែលជាកត្តាមួយនៃស្ថានទម្ងន់ទោសបន្ថែមទៀត[99]។

៤៨- អង្គជំនុំជម្រះសាលាដំបូងបានរកឃើញផងដែរថា អ្នកជាប់ឃុំនៅមន្ទីរស២១ ដែលរួមមានកុមារ សហព័ទ្ធ និងសមាជិកក្រុមគ្រួសារផ្សេងទៀតរបស់អ្នកជាប់ឃុំ គឺមិនមានលទ្ធភាពការពារខ្លួន ហើយងាយនឹងទទួលរងការរំលោភបំពាន[100]។ ក្នុងអំឡុងពេលជាប់ឃុំ ការរស់នៅរបស់អ្នកជាប់ឃុំទាំងនោះ គឺស្ថិតនៅក្រោមការឃោមកាមដោយរួមបញ្ចូលទាំងការកំណត់ថ្ងៃ និងវិធីសាស្ត្រនៃការសម្លាប់ផងដែរ[101]។

៤៩- អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរថា លើកលែងតែបទល្មើសការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ចំពោះបទល្មើសការធ្វើទុក្ខបុកម្នេញនេះ ចេតនានៃការរើសអើងគឺជាធាតុផ្សំផ្នែកច្បាប់មួយដ៏សំខាន់) ចេតនារើសអើងនៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ អាចត្រូវបានពិចារណាជាស្ថានទម្ងន់ទោសក្នុងការផ្តន្ទាទោស[102]។ ដោយផ្អែកទៅលើរឿងក្តី *Simic* អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ចេតនាដូច្នេះអាចទាញចេញពីកាលៈទេសៈផ្សេងៗនៃបទឧក្រិដ្ឋ

---

97 សាលក្រម កថាខណ្ឌ ៦០៣។

98 សាលក្រម កថាខណ្ឌ ៦០៣។

99 សាលក្រម កថាខណ្ឌ ៦០៣។

100 សាលក្រម កថាខណ្ឌ ៦០៤។

101 សាលក្រម កថាខណ្ឌ ៦០៤។

102 សាលក្រម កថាខណ្ឌ ៦០៥។

00613486



ដែលចុងបណ្តឹងសាទុក្ខបានដឹងច្បាស់ និងបានចូលរួមប្រព្រឹត្តនៅក្នុងប្រព័ន្ធនៃការរើសអើងដោយមូលហេតុនយោបាយនោះ[103]។ អង្គជំនុំជម្រះបានរកឃើញថា ចុងបណ្តឹងសាទុក្ខ បានប្រព្រឹត្តអំពើឧក្រិដ្ឋដោយមានចេតនារើសអើងជាក់លាក់ផ្អែកទៅលើឋានៈ និងការប្រឆាំងផ្នែកនយោបាយរបស់ជនរងគ្រោះដែលត្រូវបានគេយល់ឃើញថាជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា។

### ឃ.២.៣.៣ ការភាន់ច្រឡំ

៥០- ក្រោយពីបានវាយតម្លៃលើស្ថានទម្ងន់ទោស ដោយផ្អែកលើកត្តាទាំងឡាយដែលសហព្រះរាជអាជ្ញាបានស្នើឡើង អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានផ្តល់ទម្ងន់ឱ្យបានគ្រប់គ្រាន់លើស្ថានទម្ងន់ទោសទាំងនេះ។ ដោយសារហេតុនេះ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានភ្ជាប់ឧក្រិដ្ឋកម្មរបស់ចុងបណ្តឹងសាទុក្ខឱ្យសមនឹងគោលបំណងដ៏ឧក្រិដ្ឋនៅក្នុងវង្វង់នៃឧក្រិដ្ឋកម្ម និងភាពធ្ងន់ធ្ងរដែលមិនអាចសមនឹងទទួលនូវស្ថានសម្រាលទោស ដែលមាននៅក្នុងរឿងក្តីនេះ។

#### *ឃ.២.៣.៣.១ ការបំពានអំណាច*

៥១- អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានផ្តល់ទម្ងន់អោយបានគ្រប់គ្រាន់លើស្ថានទម្ងន់ទោស ដែលបង្ហាញថា ចុងបណ្តឹងសាទុក្ខបានបំពានអំណាចតាមព្រឹត្តិហេតុ និងតាមផ្លូវច្បាប់របស់ខ្លួន ដោយចេតនា និងដោយជាក់ស្តែង ចាប់តាំងពីពេលកកើត ស-២១ ក្នុងឋានៈខ្លួនជាអនុលេខា រហូតដល់ថ្ងៃខ្លួនរត់ចេញពី ស-២១ ក្នុងឋានៈជាលេខា ស-២១។ ក្នុងឋានៈខ្លួនជាប្រធានជាផ្លូវការនៃមន្ទីរស-២១ ចុងបណ្តឹងសាទុក្ខមានការទទួលខុសត្រូវធានាឱ្យមានការការពារក្នុងលក្ខណៈមនុស្សធម៌ និងតាម

---

[103] សាលក្រម កថាខណ្ឌ ៦០៥ (ដកស្រង់រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Simic* សាលក្រម IT-95-9-T អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ ៥១)។

00613487



ផ្លូវច្បាប់ជាចាំបាច់ដល់អ្នកជាប់ឃុំដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន មិនថាពួកគេជាប្រជាជនកម្ពុជា ជាឈ្លើយសឹក ឬជាជនបរទេសឡើយ។ ចុងបណ្តឹងសាទុក្ខពិតជាខកខានមិនបានអនុវត្តអំណាចរបស់ខ្លួន ក្នុងការរារាំងការរំលោភបំពានសិទ្ធិមនុស្សជាសារវ័ន្តលើអ្នកទោស និងក្នុងការដាក់ទណ្ឌកម្មលើបុគ្គលិកក្រោមបង្គាប់របស់ខ្លួន ដែលបានរំលោភបំពានបែបនេះ។ ផ្ទុយមកវិញ ចុងបណ្តឹងសាទុក្ខបែរជាប្រើប្រាស់អំណាចរបស់ខ្លួនជួយបង្កើត និងរៀបចំមន្ទីរឃុំឃាំងមួយដ៏សាហាវឃោរឃៅ និងគួរឱ្យព្រឺក្បាល នៅក្នុងប្រវត្តិសាស្ត្រទំនើប។ ចុងបណ្តឹងសាទុក្ខបានប្រើប្រាស់អំណាចរបស់ខ្លួនគ្រប់របៀបទាំងអស់ដែលខ្លួនអាចធ្វើទៅបានមកលើអ្នកទោស ដោយមិនផ្តល់ការការពារដល់ពួកគេ។ ចុងបណ្តឹងសាទុក្ខបានប្រើប្រាស់អំណាចនោះមកបង្ហាត់បង្រៀនអ្នកសួរចម្លើយឱ្យចេះធ្វើទារុណកម្ម និងរំលោភបំពានលើអ្នកទោស ឱ្យចេះកំណត់មុខសញ្ញាឱ្យបានច្រើនដើម្បីចាប់ខ្លួន និងឱ្យចេះកាប់សម្លាប់ក្នុងវិធីមួយដែលមានប្រសិទ្ធភាព និងសម្ងាត់។ ភស្តុតាងជាច្រើនដែលមានលក្ខណៈមិនអាចប្រកែកបាន និងមានចេតនា ដែលចុងបណ្តឹងសាទុក្ខបានបំពានអំណាចដែលខ្លួនមាននៅ ស-២១[104]។

*ឃ.២.៣.៣.២ ភាពគ្មានធម៌មេត្តាចំពោះជនរងគ្រោះ*

៥២- អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានផ្តល់ទម្ងន់ឱ្យបានគ្រប់គ្រាន់លើស្ថានទម្ងន់ទោសដែលបង្ហាញអំពីភាពគ្មានធម៌មេត្តាចំពោះអ្នកទោសណាម្នាក់ ដោយរួមទាំងកូនក្មេង នៅស -២១។ តាមរយៈភស្តុតាងបង្ហាញនាពេលសវនាការ គុកនេះគឺពិតជាមន្ទីរសម្រាប់ពិឃាដ និងធ្វើទារុណកម្មដ៏ធំមួយដែលលទ្ធភាពប្រតិបត្តិការងារក្នុងលក្ខណៈដ៏សាហាវ និងគួរឱ្យភ័យខ្លាច ដោយគ្មានស្រាកស្រាន។ វិធីធ្វើទារុណកម្មជាច្រើនបែបបានយកមកប្រើប្រាស់ក្នុងលក្ខណៈប្រព័ន្ធ ដែលភាគច្រើនរួមមាន

[104] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៣៩១-៣៩២។

00613488



ការបង្កឱ្យមានរបួស និង/ឬ ការឈឺចាប់ខ្លាំងលើរូបរាងកាយ ព្រមទាំងការបង្កឱ្យមានការភ័យខ្លាច ការបន្ទាបបន្ថោក និងការបង្កឱ្យមានការតក់ស្លុតខាងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ។ ការធ្វើទារុណកម្មបាន បណ្តាលរហូតដល់ស្លាប់ជាច្រើនករណី ហើយអ្នកដែលត្រូវបានគេចាប់ខ្លួនយកទៅស-២១ ភាគច្រើន ប្រហែលជាបានដឹងតិចតួចណាស់អំពីទីកន្លែងដែលខ្លួនត្រូវទៅ និងហេតុផលពិតប្រាកដនៃការចាប់ខ្លួន។ ប៉ុន្តែក្នុងពេលខ្លួនរងការធ្វើបាប ទារុណកម្ម និងជាប់ឃុំឃាំង ជនរងគ្រោះជាច្រើនទំនងជាបានដឹងអំពីជោគវាសនាដែលបានរង់ចាំខ្លួន មុនពេលខ្លួនត្រូវបានគេយកទៅសម្លាប់ចោល។ អ្នកទោសដែលមានសមាជិកគ្រួសារត្រូវបានគេចាប់ខ្លួនផងដែរនោះ ទំនងជាបានដឹងអំពីជោគវាសនាដែលបានរង់ចាំមនុស្សជាទីស្រលាញ់របស់ខ្លួនដូចគ្នា។ ការដឹងដូច្នេះបាននាំឱ្យមានភាពអស់សង្ឃឹម ការប៉ះទង្គិចផ្លូវចិត្ត និងការឈឺចាប់ខាងផ្លូវអារម្មណ៍ បន្ថែមលើការឈឺចាប់ខាងផ្លូវកាយដែលទទួលរងដោយសារស្ថានភាពអមនុស្សធម៌ និងការធ្វើទារុណកម្ម។ ទាំងអស់នេះហើយជាស្ថានទម្ងន់ទោសយ៉ាងពិតប្រាកដ។ ចុងបណ្តឹងសាទុក្ខបានរៀបចំ ប្រព្រឹត្ត តាមដាន និងអនុញ្ញាតឱ្យមានភាពសាហាវបែបនេះបន្តកើតមានទៅគ្រប់ដំណាក់កាលដែលអ្នកទោសបានឆ្លងកាត់ ស-២១ ក្នុងរយៈពេលជាងបីឆ្នាំ[105]។

*ឃ.២.៣.៣.៣ ភាពងាយរងគ្រោះ និងភាពគ្មានទីពឹងរបស់ជនរងគ្រោះ*

៩៣- អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានផ្តល់ទម្ងន់ឱ្យបានគ្រប់គ្រាន់លើស្ថានទម្ងន់ទោសដែលបង្ហាញអំពីភាពងាយរងគ្រោះ និងភាពគ្មានទីពឹងរបស់អ្នកទោសនៅមន្ទីរស-២១ ដែលជោគវាសនារបស់ពួកគេស្ថិតនៅក្នុងកណ្តាប់ដៃរបស់អ្នកដែលចាប់ខ្លួន និងដែលត្រូវបានគេដកហូតនូវសិទ្ធិមនុស្សជាមូលដ្ឋានរបស់ខ្លួន។ ពួកអ្នកទោសត្រូវបានគេបន្ទាបបន្ថោក ធ្វើទារុណកម្ម មិនផ្តល់អាហារគ្រប់

---

105 សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៣៩៦ -៣៩៨។

គ្រាន់ និងបង្ខាំងនៅក្នុងបរិស្ថានដែលពោរពេញដោយជម្ងឺ។ ជាធម្មតា សហព័ទ្ធ កូនៗ និងសមាជិកគ្រួសារដទៃទៀតរបស់អ្នកទោសត្រូវបានគេចាប់ខ្លួន ឃុំខ្លួន និងសម្លាប់។ ពួកគេទាំងអស់ត្រូវបានដាក់ឃុំនៅក្នុងស្ថានភាពអមនុស្សធម៌ និងគួរឱ្យស្អប់ខ្ពើម ដោយឆ្នាំកាន់អាវុធចាំយាមជាប្រចាំ។ ចុងបណ្តឹងសាទុក្ខបានដឹងទាំងស្រុងនូវលក្ខខណ្ឌឃុំខ្លួនដ៏អមនុស្សធម៌ ភាពភ័យខ្លាចគ្មានស្រាកស្រាន ទារុណកម្ម និងការកាប់សម្លាប់នេះជាហូរហែរមក ប៉ុន្តែមិនដែលបង្ហាញក្តីមេត្តាធម៌ មិនបានចាត់វិធានការដើម្បីធ្វើឱ្យការឈឺចាប់របស់ជនរងគ្រោះធូរស្បើយ ហើយបែរជានៅតែបន្តប្រព្រឹត្តនូវឧក្រិដ្ឋកម្មរបស់ខ្លួនដដែល[106]។

*ឃ.២.៣.៣.៤ ការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយមានចេតនារើសអើង*

៥៤- នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានកាត់ទោសចុងបណ្តឹងសាទុក្ខពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចំពោះតែការធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាលើស្ថានទម្ងន់ទោសនៃចេតនារើសអើងនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និងអំពើអមនុស្សធម៌ផ្សេងទៀត ទោះបីជាអង្គហេតុទាំងឡាយ ដែលជាមូលដ្ឋានលើចេតនាចំពោះឧក្រិដ្ឋកម្មទាំងនេះបានបង្ហាញនាពេលសវនាការក៏ដោយ[107]។ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាថា ចុងបណ្តឹងសាទុក្ខបានប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ខ្លួនដោយមានចេតនារើសអើងជាក់លាក់ ដោយសារតែទស្សនៈនយោបាយរបស់ជនរងគ្រោះ (ឧទាហរណ៍ ចំពោះអ្នកទោសទាំងឡាយណាដែលត្រូវបានគេយល់ថាបានប្រឆាំងនឹងទស្សនៈនយោបាយរបស់របបនោះ) និងដោយសារតែជាតិពិន្ទុ និង សញ្ជាតិ

---

[106] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤០២ - ៤០៣។

[107] សាលក្រម កថាខណ្ឌ ៦០៥។

(ឧទាហរណ៍ ចំពោះអ្នកទោសវៀតណាម)។ ការបង្ហាត់បង្រៀន និងការអប់រំអ្នកសួរចម្លើយ និងបុគ្គលិកនានា ដោយចុងបណ្តឹងសាទុក្ខ រួមទាំងចំណាររបស់ចុងបណ្តឹងសាទុក្ខនៅលើ ចម្លើយសារភាព បានបង្ហាញយ៉ាងច្បាស់អំពីភាពស្អប់ខ្ពើមរបស់ចុងបណ្តឹងសាទុក្ខមកលើ "ខ្មាំង" ទាំងនេះ។ ចុងបណ្តឹងសាទុក្ខបានណែនាំបុគ្គលិកក្រោមបង្គាប់របស់ខ្លួន អោយចាត់ទុកអ្នកទោសស-២១ ជាសត្វធាតុ ដោយសារតែខ្សែរយៈរបស់អ្នកទោសមានប្រភពមកពីខាងណា ដែលចំណុចនេះបានដើរតួនាទីសំខាន់មួយនៅក្នុងការពង្រឹងអ្នកសួរចម្លើយក្មេងៗ និងជម្រុញពួកគេឱ្យយកវិធីទារុណកម្មដែលហួសហេតុទាំងនេះមកប្រើប្រាស់ចំពោះអ្នកទោស។ ហេតុដូច្នេះ ចេតនាឧក្រិដ្ឋរបស់ចុងបណ្តឹងសាទុក្ខគួរតែចាត់ទុកថាជាស្ថានទម្ងន់ទោស នៅក្នុងការដាក់ទោសចុងបណ្តឹងសាទុក្ខចំពោះឧក្រិដ្ឋកម្មរបស់ខ្លួន លើកលែងតែចំពោះការធ្វើទុក្ខបុកម្នេញនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[108]។

៩៥- ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញអង្គហេតុទាំងឡាយ ដែលគាំទ្រដល់ស្ថានទម្ងន់ទោស សហព្រះរាជអាជ្ញាសូមសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ នៅពេលខ្លួនផ្តល់ទម្ងន់មិនគ្រប់គ្រាន់លើកាលៈទេសៈដ៏ជាក់លាក់ទាំងនោះនៅក្នុងរឿងក្តីនេះ។ ហេតុដូច្នេះហើយអង្គជំនុំជម្រះសាលាដំបូងមិនកំណត់ដាក់ទោសទៅតាមទម្រង់នៃឧក្រិដ្ឋកម្ម និងការចូលរួមចម្បងរបស់ចុងបណ្តឹងសាទុក្ខនៅក្នុងឧក្រិដ្ឋកម្មនេះ ពោលគឺទោសជាប់ពន្ធនាគារអស់មួយជីវិត។

## ឃ.៣ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ស្ថានសម្រាលទោសហួសហេតុ

### ឃ.៣.១ អង្គច្បាប់

---

[108] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤០៨។

៥៦- ការសម្រេចលើស្ថានសម្រាលទោសគឺជាប់ទាក់ទងនឹងការកំណត់ទោស ប៉ុន្តែមិនមែនថាមិនរលំនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មឡើយ[109] ពោលគឺវាសម្រាលដល់ទណ្ឌកម្ម មិនមែនឧក្រិដ្ឋកម្មឡើយ[110]។ ការពិចារណាលើស្ថានសម្រាលទោស ត្រូវតែជាដំណាក់កាលក្រោយពីការពិចារណាលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងផលប្រយោជន៍របស់ជនរងគ្រោះ[111]។

៥៧- ការបង្ហាញអំពីស្ថានសម្រាលទោសមិនមែនផ្តល់ដល់ជនជាប់ចោទនូវ "ការទូទាត់ទោស" ដោយស្វ័យប្រវត្តិ នៅពេលសម្រេចលើការកំណត់ទោសឡើយ[112]។ អង្គជំនុំជម្រះសាលាដំបូងគួរកំណត់ទោសជាប់ពន្ធនាគារអស់មួយជីវិត នៅពេលលក្ខខណ្ឌនៃភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មតម្រូវឱ្យធ្វើដូច្នោះ[113]។

## ឃ.៣.២ លទ្ធផលរកឃើញ

៥៨- នៅពេលពិចារណាលើរយៈពេលដែលឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង ចំនួនដ៏ច្រើននៃជនរងគ្រោះ និងការប្តេជ្ញារបស់ចុងបណ្តឹងសាទុក្ខក្នុងការធ្វើឱ្យប្រតិបត្តិការនៃស-២១ កាន់តែប្រសើរឡើង អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានបានត្រឹមត្រូវថា ចុងបណ្តឹងសាទុក្ខខកខានមិនបានបង្ហាញឱ្យជឿថា ការបង្គាប់បញ្ជារបស់ថ្នាក់លើអាចចាត់ទុកថាជាស្ថានសម្រាលទោស[114]។ ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ចុងបណ្តឹងសាទុក្ខខកខានមិនបានបង្ហាញឱ្យជឿថា ការបង្ខិតបង្ខំគឺជាស្ថាន

---

[109] សាលក្រមនៃអង្គជំនុំជម្រះសាលាដំបូងលើការដាក់ទោស *Kambanda* កថាខណ្ឌ ៥៦។

[110] សាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង *Brdanin* កថាខណ្ឌ ១១១៧។

[111] ប្រតិចារឹកសវនាការ Richard Goldstone ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ T.២៣-២៤។

[112] *រដ្ឋអាជ្ញា ទល់នឹង Niyitegeka* សាលដីកា ICTR-96-14-A អង្គជំនុំជម្រះតុលាការកំពូលនៃ ICTR ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ២៦៧។

[113] *រដ្ឋអាជ្ញា ទល់នឹង Musema* សាលដីកា ICTR-96-13-A អង្គជំនុំជម្រះតុលាការកំពូលនៃ ICTR ថ្ងៃទី១៦ វិច្ឆិកា ២០០១ កថាខណ្ឌ ៣៩៦។ *សូមមើល រដ្ឋអាជ្ញា ទល់នឹង Stakic* សាលដីកា IT-97-24-A អង្គជំនុំជម្រះតុលាការកំពូលនៃ ICTY ថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០៦ ("សាលដីកា *Stakic* ") កថាខណ្ឌ ៤០៧ (ដែលកត់សម្គាល់ថា ទោះបីជាស្ថានសម្រាល ត្រូវបានរកឃើញក៏ដោយចៅក្រមអាចពិចារណាថា កត្តានានាដូចជា ភាពធ្ងន់ធ្ងរនៃបទល្មើសតម្រូវឱ្យមានការដាក់ទោស អតិបរមា)។

[114] សាលក្រម កថាខណ្ឌ ៦០៧។

សម្រាលទោសមួយ[115]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំ ដោយសារបាន "ផ្តល់ទម្ងន់មានកម្រិតទៅលើបរិយាកាសបង្ខិតបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាទៅលើតំណែងជាអ្នកនៅក្រោមឱវាទគេរបស់គាត់ នៅក្នុងបក្សកម្មុយនីស្តកម្ពុជា"[116]។

៥៩- ទោះបីជាចុងចោទបណ្តឹងសាទុក្ខបានធ្វើការសុំខមាលទោស និងសម្តែងនូវវិប្បដិសារីជាសាធារណៈចំពោះឧក្រិដ្ឋកម្មរបស់ខ្លួនក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ស្ថានសម្រាលទោសចំពោះវិប្បដិសារីនោះ បានបាត់បង់តម្លៃ ដោយសារចុងបណ្តឹងសាទុក្ខខកខានមិនទទួលស្គាល់ទាំងស្រុង និងជាក់លាក់លើការទទួលខុសត្រូវរបស់ខ្លួន[117]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថាសំណើសុំឱ្យរួចផុតពីបទចោទរបស់ចុងបណ្តឹងសាទុក្ខនៅក្នុងពេលធ្វើ សេចក្តីសន្និដ្ឋានបិទការជជែកដេញដោល បានបន្ថយនូវវិសាលភាពដែលវិប្បដិសារី អាចសម្រាលទោសដល់ចុងបណ្តឹងសាទុក្ខ[118]។ បើទោះជាមានការរកឃើញដូច្នេះក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកការសហការរបស់ចុងបណ្តឹងសាទុក្ខជាស្ថានសម្រាលទោស។

៦០- ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលរបស់សាលាក្តី ICTY បានសម្រេចថា ការស្តារនីតិសម្បទាឡើងវិញមិនមែនជាកត្តា "ដែលគួរផ្តល់ស្ថានសម្រាលហួសហេតុពេក"ក៏ដោយ[119] អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ "ការពិចារណាបន្តិចបន្តួចចំពោះឧបនិស្ស័យនៃការស្តារនីតិសម្បទាឡើងវិញរបស់ចុងបណ្តឹងសាទុក្ខ"[120]។

---

[115] សាលក្រម កថាខណ្ឌ ៦០៨។

[116] សាលក្រម កថាខណ្ឌ ៦០៨។

[117] សាលក្រម កថាខណ្ឌ ៦១០។

[118] សាលក្រម កថាខណ្ឌ ៦១០។

[119] សាលក្រម កថាខណ្ឌ ៦១១ (ដែលដកស្រង់*រដ្ឋអាជ្ញា ទល់នឹង Delalic* សាលដីកា IT-96-21-A អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ ("សាលដីកា *Celebici*") កថាខណ្ឌ ៨០៦)។

[120] សាលក្រម កថាខណ្ឌ ៦១១។

## ឃ.៣.៣ ការភាន់ច្រឡំ

### ឃ.៣.៣.១ ទូទៅ

៦១- ទោះបីជាបានរកឃើញថា ស្ថានសម្រាលទោសដែលដាក់ជូនដោយចុងបណ្ដឹងសាទុក្ខ ចាំបាច់ត្រូវផ្ដល់ទម្ងន់"ដែលមានកម្រិត" ឬ"តិចតួច"[121] ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការសម្រេចចុងក្រោយលើទោស បានជ្រើសរើសចាត់ទុកកត្តាទាំងនេះ "មានតម្លៃ"[122]។ ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយភាន់ច្រឡំថា ទោសដែលខ្ពស់បំផុតដែលខ្លួនគួរកំណត់ ពោលគឺទោសជាប់ពន្ធនាគារអស់មួយជីវិត ចាំបាច់ត្រូវបន្ថយមក "ទោសដែលមានរយៈពេលកំណត់"[123] គឺ ៣៥ ឆ្នាំ[124]។

៦២- នៅក្នុងសេចក្ដីសម្រេចចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់អំពីការឃុំខ្លួនចុងបណ្ដឹងសាទុក្ខនៅមុនពេលនៅ អ.វ.ត.ក និងបានរកឃើញថា ចុងបណ្ដឹងសាទុក្ខមានសិទ្ធិទទួលការទូទាត់ទោស ដែលខ្លួនបានជាប់ឃុំរួចហើយ ហើយនឹងទទួលបានការបន្ថយទោសបន្ថែមទៀត ចំពោះការរំលោភបំពានលើសិទ្ធិរបស់ខ្លួន[125]។

៦៣- អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានពិចារណាលើសេចក្ដីសន្និដ្ឋានបើកការដេញដោលរបស់សហព្រះរាជអាជ្ញាដែលបានលើកឡើងថា ចុងបណ្ដឹងសាទុក្ខគួរទទួលបានការបន្ថយទោសតិចតួចប៉ុណ្ណោះ ចំពោះកិច្ចសហការ "ជាទូទៅ" របស់ខ្លួនជាមួយនឹងតុលាការ ការទទួលស្គាល់ការទទួល

---

[121] សាលក្រម កថាខណ្ឌ ៦០៨ កថាខណ្ឌ ៦១០-៦១១។

[122] សាលក្រម កថាខណ្ឌ ៦២៩។

[123] សាលក្រម កថាខណ្ឌ ៦២៩។

[124] សាលក្រម កថាខណ្ឌ ៦៣១។

[125] សេចក្ដីសម្រេចលើការស្នើសុំឱ្យមានការដោះលែង សំណុំរឿងលេខ ០០១/១៨.០៧.០៧/អវតក/អជសដ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ឯកសារលេខ E៣៩/៥។

ខុសត្រូវតិចតួច និងផលប៉ះពាល់ដែលអាចមានលើការផ្សះផ្សាជាតិ[126]។ អង្គជំនុំជម្រះសាលាដំបូងក៏ខកខានមិនបានពិចារណាលើសេចក្ដីសន្និដ្ឋានបញ្ចប់របស់សហព្រះរាជអាជ្ញាថា ដោយសារការផ្លាស់ប្ដូរនូវវិធីការពារក្ដីរបស់ចុងបណ្ដឹងសាទុក្ខ និងសំណើសុំឲ្យរួចផុតពីបទចោទ តុលាការមិនគួរយកស្ថានសម្រាលទោសមកពិចារណាឡើយ[127]។

ឃ.៣.៣.២ "បរិយាកាសបង្ខិតបង្ខំ"

៦៤- អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំ ដោយខកខានមិនបានសម្រេចលើសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាថា ចុងបណ្ដឹងសាទុក្ខគឺជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងក៏ជាជនមួយរូបដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទាំងឡាយនៅក្នុងរបបនោះ[128]។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានសម្រេចដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនធ្វើការផ្ដល់ទម្ងន់លើ "បរិយាកាសបង្ខិតបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាទៅលើតំណែងជាអ្នកនៅក្រោមឱវាទគេរបស់ចុងបណ្ដឹងសាទុក្ខនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា"[129]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ក្នុងនាមគាត់ជាប្រធានតាមព្រឹត្តហេតុ និងតាមផ្លូវច្បាប់ នៃមន្ទីរឃុំឃាំងធំមួយរបស់របបកម្ពុជាប្រជាធិបតេយ្យ ចុងបណ្ដឹងសាទុក្ខគឺជាអ្នករួមបង្កើត មិនមែនជាជនរងគ្រោះនៅក្នុង "បរិយាកាសបង្ខិតបង្ខំ" ហើយមិនសមទទួលនូវស្ថានសម្រាលទោសណាមួយចំពោះការកំណត់ទោសឡើយ[130]។

---

[126] សាលក្រម កថាខណ្ឌ ៦០៦។

[127] សាលក្រម កថាខណ្ឌ ៦០៦។

[128] សាលក្រម កថាខណ្ឌ ២៥។

[129] សាលក្រម កថាខណ្ឌ ៦០៨។

[130] សេចក្ដីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ២៤៤។

៦៥- អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិ នៅពេលខ្លួនបានរកឃើញពីដំបូងថា "បរិយាកាសបង្ខិតបង្ខំ" គឺជាស្ថានសម្រាលទោស និងនៅក្នុងចំណុចទីពីរ គឺដោយសារអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទម្ងន់ដល់កត្តានេះ ទោះក្នុងកម្រិតណាក៏ដោយ។

### ឃ.៣.៣.៣ កិច្ចសហការជាមួយនឹងតុលាការ

៦៦- អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំ នៅពេលខ្លួនបានផ្តល់ទម្ងន់ហួសហេតុលើកិច្ចសហការរបស់ចុងចោទបណ្តឹងសាទុក្ខជាមួយនឹងតុលាការ[131]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋាននាពេលសវនាការថា ទោះបីជាចុងបណ្តឹងសាទុក្ខបានសហការជាមួយនឹងអាជ្ញាធរទាំងឡាយ តាំងពីដំបូងក៏ដោយ តាមរយៈការបង្ហាញឆន្ទៈទូទៅក្នុងការផ្តល់សក្ខីកម្ម ផ្តល់យោបល់លើភស្តុតាងដែលមាន និងបើមិនដូច្នោះទេ ចូលរួមក្នុងការស៊ើបអង្កេត និងការជំនុំជម្រះ កិច្ចសហការនេះមានលក្ខណៈតិចតួច[132]។ ទោះបីជាចុងបណ្តឹងសាទុក្ខបានទទួលស្គាល់នូវឧក្រិដ្ឋកម្មនៅស-២១ និងទទួលស្គាល់ការទទួលខុសត្រូវជារួមលើឧក្រិដ្ឋកម្មទាំងនេះក៏ដោយ ចុងបណ្តឹងសាទុក្ខបានតវ៉ាលើការចោទប្រកាន់ជាច្រើនដែលជាប់ទាក់ទងនឹងការជាចូលរួមដោយផ្ទាល់របស់គាត់ និងបានព្យាយាមបង្ហាញតួនាទីរបស់ខ្លួននៅស-២១ ក្នុងលក្ខណៈមួយដែលមិនស៊ីសង្វាក់ទាំងស្រុងជាមួយនឹងភស្តុតាងដែលមាន[133]។ នៅក្នុងពេលជាច្រើននាពេលសវនាការ នៅពេលប្រឈមនឹងសំនួរនានាស្តីពីអំណាចបង្គាប់បញ្ជា ឆន្ទៈចេតនា និងកម្រិតនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្ម ចុងបណ្តឹងសាទុក្ខផ្តល់សក្ខីកម្មដោយគេចវេសមិនពេញលេញ និងធ្វើឱ្យមានការភាន់ច្រឡំ[134]។

---

[131] សាលក្រម កថាខណ្ឌ ៦០៩។

[132] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤២៥។

[133] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤២៥។

[134] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤២៥។

៦៧- ជាងនេះទៅទៀត នៅក្នុងទូទាំងអំឡុងពេលនៃកិច្ចស៊ើបសួរ និងសវនាការជំនុំជម្រះក្តីទាំងមូល ចុងបណ្តឹងសាទុក្ខ (១) បានបដិសេធមិនបកស្រាយការពិតទាំងស្រុងនៃហេតុការណ៍ទាំងឡាយនៅ ស-២១ និងនៅជុំវិញមន្ទីរស-២១ (២) បានស្វះស្វែងបង្រួមតួនាទី និងការចូលរួមដោយផ្ទាល់របស់គាត់នៅក្នុងឧក្រិដ្ឋកម្មទាំងនោះឱ្យមកតូច និង (៣) បញ្ឈាក់អះអាងថា មិនអាចនឹកឃើញឡើងវិញ ឬ បដិសេធមិនឆ្លើយទៅនឹងសំនួរនានាលើបញ្ហាទាំងឡាយ ដែលនៅក្នុងរង្វង់នៃការដឹងរបស់គាត់[135]។ តាមរយៈមេធាវីរបស់គាត់ ចុងបណ្តឹងសាទុក្ខ (១) បានជំទាស់នឹងការចោទថា ខ្លួនគឺជាមេដឹកនាំជាន់ខ្ពស់ ឬជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងថាគាត់ត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ (២) បានជំទាស់នឹងការចោទពីការទទួលខុសត្រូវរបស់គាត់ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មផ្សេងៗតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម (៣) បានជំទាស់នឹងការចោទពីការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មនានា អនុលោមតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ (៤) បានជំទាស់នឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលសុំបញ្ចីបម្រុងសាក្សីមួយនៃឈ្មោះសាក្សីសម្រាប់សវនាការ (៥) បានជំទាស់នឹងសំណើសុំឱ្យយល់ព្រមទទួលយកភស្តុតាងជាឯកសារដែលពាក់ព័ន្ធ និងជាភវនីយភាព (៦) បានជំទាស់នឹងសំណើមួយ ដែលសុំឱ្យយល់ព្រមទទួលយកនូវសេចក្តីសង្ខេបចម្លើយសាក្សី ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង (៧) បានជំទាស់យ៉ាងទូលាយ ដោយគ្មានមូលដ្ឋានជាក់លាក់នៅក្នុងទូទាំងរយៈពេលនៃការចោទសួរអ្នកជំនាញដ៏សំខាន់មួយរូប គឺលោក Craig Etcheson និង (៨) បានខិតខំដើម្បីធ្វើឱ្យសាក្សីនានានៅក្នុងសវនាការជំនុំជម្រះកាន់តែមានការភ័យខ្លាចខ្លាំងឡើង ថាគេអាចនឹងយកសាក្សីទាំងនោះទៅធ្វើការជំនុំជម្រះក្តីនៅក្នុងតុលាការជាតិនានា ដែលតាមរយៈនេះ បានធ្វើឱ្យតម្លៃភវនីយភាពនៃការ

[135] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤២៦។

00613497



ផ្តល់សក្ខីកម្មរបស់ពួកគេនៅក្នុងសវនាការត្រូវបានថយចុះ ហើយបានធ្វើឱ្យបាត់បង់ស្ថានសម្រាលទោស ឬការចរចាដែលអាចសម្របសម្រួលគ្នាបាន[136]។

៦៨- ហេតុដូច្នេះ កិច្ចសហការរបស់ចុងបណ្តឹងសាទុក្ខ បានជួយសម្រួលដល់អង្គជំនុំជម្រះមានកម្រិតតិចតួចតែប៉ុណ្ណោះ។ ព័ត៌មានដែលចុងបណ្តឹងសាទុក្ខបានផ្តល់ឱ្យមានប្រយោជន៍តិចតួច ដែលអាចឱ្យយើងយល់ឱ្យបានច្រើនជាងនេះអំពីឧក្រិដ្ឋកម្មនានានៅ ស-២១ ឬ តួនាទីរបស់ចុងបណ្តឹងសាទុក្ខនៅទីនោះ។ ការណ៍នេះបានធ្វើឱ្យអានុភាពនៃស្ថានសម្រាលថយចុះ ដែលចុងបណ្តឹងសាទុក្ខត្រូវទទួលបាន។ អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំ ក្នុងការខកខានមិនបានទទួលស្គាល់ថាចុងបណ្តឹងសាទុក្ខ មិនអាចស្វះស្វែងឱ្យមានការសម្រាលទោស តាមរយៈបង្ហាញឱ្យឃើញថាខ្លួនសហការពេញលេញ ក្នុងខណៈដែលនៅពេលតែមួយ បដិសេធមិនសហការ និងតវ៉ាទិដ្ឋភាពសំខាន់ៗនៃរឿងក្តីដែលដាក់បន្ទុកមកលើខ្លួន[137]។

៦៩- អង្គជំនុំជម្រះសាលាដំបូងក៏ខកខានមិនបានកត់សម្គាល់ថា កិច្ចសហការរបស់ចុងបណ្តឹងសាទុក្ខមិនបានធ្វើឡើងភ្លាមៗបន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ រហូតដល់រយៈពេល ២០ឆ្នាំក្រោយមក ពោលគឺវាបានធ្វើឡើងនៅពេលអ្នកកាសែតមួយរូបឈ្មោះ Nic Dunlop បានរកឃើញចុងបណ្តឹងសាទុក្ខដោយចៃដន្យតែប៉ុណ្ណោះ។ តាមពិត ចុងបណ្តឹងសាទុក្ខនៅតែជាផ្នែកមួយនៃខ្មែរក្រហម ហើយនៅតែផ្តល់ការគាំទ្រដល់ពួកគេអស់ជាច្រើនឆ្នាំ ក្រោយពេលដែលរបបនេះបានដួលរលំ។ ចុងបណ្តឹងសាទុក្ខមិនបានចូលខ្លួនជួយដល់អាជ្ញាធរក្នុងការស៊ើបអង្កេតឧក្រិដ្ឋកម្មទាំងឡាយនៅស-២១ ឡើយ ទោះបីក្រោយពេលដែលខ្លួនមានការខកចិត្តនឹងខ្មែរក្រហមក៏ដោយ។ ប៉ុន្តែ

---

[136] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤២៦។

[137] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤២៧។

ចុងបណ្តឹងសាទុក្ខបានសម្រេចចិត្តនៅលាក់អត្តសញ្ញាណរបស់ខ្លួនទៅវិញ។ នៅក្នុងដំណាក់កាលខុសគ្នាក្នុងពេលជំនុំជម្រះ ជាធម្មតានៅពេលប្រឈមនឹងភស្តុតាង ឬសំនួរនានា ដែលទាក់ទងនឹងការពាក់ព័ន្ធរបស់ខ្លួនផ្ទាល់ ចុងបណ្តឹងសាទុក្ខបានគេចវេស និងនៅស្ងៀមមិនឆ្លើយទៅនឹងសំនួរធំៗទាំងនោះ។ ត្រង់បញ្ហានេះដែរ ចុងបណ្តឹងសាទុក្ខក៏បានអះអាងថា ខ្លួននឹកមិនឃើញនូវហេតុការណ៍សំខាន់ៗទាំងនេះ (ផ្ទុយទៅវិញចុងបណ្តឹងសាទុក្ខបានចងចាំយ៉ាងល្អចំពោះបញ្ហាទាំងឡាយដែលមានប្រយោជន៍ដល់គាត់) ឬ ក៏បានរៀបរាប់ដោយមិនទំនង ដែលមិនស៊ីសង្វាក់គ្នានឹងភស្តុតាងនៅចំពោះមុខតុលាការ[138]។

៧០- ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង មានការភាន់ច្រឡំក្នុងការផ្តល់ទម្ងន់ហួសហេតុពេកលើកិច្ចសហការទៅតាមការជ្រើសរើស និងទៅតាមការឆក់ឱកាសរបស់ចុងបណ្តឹងសាទុក្ខជាមួយនឹងតុលាការនេះ។

ឃ.៣.៣.៤ ការទទួលយកនូវការទទួលខុសត្រូវ និងវិប្បដិសារី

៧១- អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ចុងបណ្តឹងសាទុក្ខបានធ្វើការសុំខមាលទោសជាសាធារណៈ និងសម្តែងវិប្បដិសារីនៅក្នុងពេលជំនុំជម្រះ។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ការខកខានមិនបានបង្ហាញនូវការទទួលខុសត្រូវរបស់គាត់ឱ្យបានពេញលេញ និងដោយគ្មានលក្ខខណ្ឌ បានប៉ះពាល់ដល់ស្ថានសម្រាលទោស ដែលអាចនឹងបានមកពីការសម្តែងវិប្បដិសារីរបស់គាត់[139]។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា សំណើរបស់ចុងបណ្តឹង

---

[138] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤៤០។

[139] សាលក្រម កថាខណ្ឌ ៦១០។

សាទុក្ខសុំឱ្យខ្លួនរួចផុតពីបទចោទ ក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ "ទោះបីជាខ្លួនបានទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្លួននាពេលដើមដំបូងយ៉ាងច្បាស់ក៏ដោយ" បានបន្ថយវិសាលភាពនៃស្ថានសម្រាលពិរុទ្ធភាពរបស់ខ្លួន ដែលអាចធ្វើឡើងដោយផ្អែកលើវិប្បដិសារី[140]។

៧២- សហព្រះរាជអាជ្ញាទទួលស្គាល់ថា ចុងបណ្តឹងសាទុក្ខបានធ្វើការសុំទោស និងសេចក្តីថ្លែងវិប្បដិសារីជាសាធារណៈនៅក្នុងឱកាសមួយចំនួន។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានកត់សម្គាល់វិសាលភាពនៃវិប្បដិសារីរបស់ចុងបណ្តឹងសាទុក្ខ ដែលបានប៉ះពាល់ដោយសារតែករណីដែលថា វាកើតចេញតាមរយៈការព្យាយាមកម្រិតលើការទទួលខុសត្រូវដោយផ្ទាល់របស់ខ្លួននៅក្នុងឧក្រិដ្ឋកម្មទាំងនោះ និងអវិភាពរបស់ខ្លួននៅក្នុងអំឡុងពេលដំណើរការនីតិវិធីទៅលើសាក្សីអ្នកជំនាញ និងអ្នកចូលរួមក្នុងនីតិវិធីនេះ[141]។

៧៣- នៅពេលជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងអំពីអាកប្បកិរិយារបស់ចុងបណ្តឹងសាទុក្ខនៅក្នុងឱកាសមួយចំនួន ដោយបានដាស់តឿនគាត់ចំពោះការសើចចំអក និងធ្វើកាយវិការផ្សេងៗ និងចំពោះ"អាកប្បកិរិយា"[142]។ អង្គជំនុំជម្រះសាលាដំបូងបានប្រាប់ចុងបណ្តឹងសាទុក្ខកុំឱ្យប្រើភាសាមិនសមរម្យ[143]។ នៅក្នុងឱកាសជាច្រើន ចុងបណ្តឹងសាទុក្ខបានបដិសេធមិនឆ្លើយ[144] ឬនៅស្ងៀមមិនឆ្លើយនឹងសំនួរ[145] រួមទាំងសំនួររបស់ក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូង[146]។

---

140 សាលក្រម កថាខណ្ឌ ៦១០។

141 សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៥៥៧។

142 ប្រតិចារិកសវនាការ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ T.៧៦។

143 ប្រតិចារិកសវនាការ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ T.៨៣។

144 ប្រតិចារិកសវនាការ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ T.២៧។

145 ប្រតិចារិកសវនាការ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ T.១០៦-១០៨។ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ T.៣-៥។

146 ប្រតិចារិកសវនាការ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ T.១៥-១៦។

៧៤- អ្នកចិត្តសាស្ត្រ ដែលបានធ្វើកោសលវិច័យលើឌុចបណ្ដឹងសាទុក្ខបានផ្ដល់សក្ខីកម្មថា ស្ទើរតែពេញមួយជីវិតយុវវ័យរបស់ខ្លួន ឌុចបណ្ដឹងសាទុក្ខមិនអាចយល់ចិត្ត មិនមានក្ដីមេត្តា ឬ មិនយល់អារម្មណ៍ទុក្ខសោក និងការឈឺចាប់របស់អ្នកដទៃ[147]។ នៅពេលបញ្ជាក់អំពីការវាយតម្លៃនេះ ប្រវត្តិ និងអាកប្បកិរិយារបស់ឌុចបណ្ដឹងសាទុក្ខនាពេលជំនុំជម្រះបានបង្ហាញថា វិប្បដិសារីរបស់ឌុចបណ្ដឹងសាទុក្ខគឺមិនមានភាពស្មោះត្រង់[148]។

៧៥- អ្នកចិត្តសាស្ត្រជនជាតិកម្ពុជាម្នាក់ និងអ្នកចិត្តសាស្ត្រអន្តរជាតិម្នាក់ទៀតបានផ្ដល់សក្ខីកម្មថា ឌុចបណ្ដឹងសាទុក្ខមាន "ឆន្ទៈទទួលយកបាននូវអង្គហេតុទាំងឡាយដែលបានបង្ហាញ និងអង្គហេតុទាំងឡាយដែលមិនអាចបង្ហាញបានឌុចបណ្ដឹងសាទុក្ខមិនទទួលយកទេ"[149]។ ប្រតិចារឹកមានឧទាហរណ៍ជាច្រើនដែលជាមូលដ្ឋានគាំទ្រចំពោះការសន្និដ្ឋានដូច្នេះ[150]។ ឧទាហរណ៍មួយគឺ ការតវ៉ារបស់ឌុចបណ្ដឹងសាទុក្ខចំពោះភស្តុតាងរបស់ នង ចាន់ផល ដែលជាកុមារមួយរូបនៅរស់ពី ស-២១។ ពីដំបូងឌុចបណ្ដឹងសាទុក្ខមិនបាន "ទទួលស្គាល់" ថា នង ចាន់ផល ជាប់នៅក្នុង ស-២១ ឡើយ[151] ប៉ុន្តែនៅពេលតទល់នឹងភស្តុតាងជាឯកសារ និងជាខ្សែវីដេអូ ឌុចបណ្ដឹងសាទុក្ខបែរជាលើកឡើងថា "នៅពេលនោះខ្ញុំមិនមានឯកសារ ទើបខ្ញុំមិនទទួលស្គាល់។ ប៉ុន្តែនាពេលនេះខ្ញុំទទួលស្គាល់ទាំងស្រុង"[152]។

៧៦- ជនជាប់ចោទម្នាក់ដែលបដិសេធការទទួលខុសត្រូវពិរុទ្ធភាព គឺក្នុងគោលបំណងចង់ឱ្យព្រះរាជអាជ្ញាបង្ហាញធាតុផ្សំនីមួយៗនៃបទឧក្រិដ្ឋ និងចំណុចនីមួយៗនៃការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់គាត់។

---

[147] ប្រតិចារិកសវនាការ Fran–oise Sironi-Guilbard និង កា ស៊ុនបូណាត ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ T.៣២-៣៣។

[148] សេចក្ដីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៥៤៩។

[149] ប្រតិចារិកសវនាការ Fran–oise Sironi-Guilbard និង កា ស៊ុនបូណាត ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ T.៩៣។

[150] *សូមមើល* ប្រតិចារិកសវនាការ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ T.៥៦-៥៨។ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ T.៤៨-៥០។ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ T.៨៥។

[151] ប្រតិចារិកសវនាការ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ T.៨៥។

[152] ប្រតិចារិកសវនាការ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩ T.៥។

ប៉ុន្តែ ជនជាប់ចោទដែលស្វះស្វែងសម្តែងនូវវិប្បដិសារី និងការយល់ព្រមទទួលស្គាល់ពិរុទ្ធភាពដើម្បីទទួលបានការសម្រាលទោស គួរផ្តល់ការសហការពិតប្រាកដ ជាជាងការប្រឹងប្រែងពិនិត្យពិច័យលើភស្តុតាង។ ជនជាប់ចោទបានបដិសេធមិនឆ្លើយនឹងសំណួរលើបញ្ហាដែលខ្លួនបានដឹង និងបង្រួមការទទួលខុសត្រូវរបស់ខ្លួន ទោះបីមានភស្តុតាងផ្ទុយយ៉ាងច្បាស់លាស់ក៏ដោយ។ វិធីសាស្ត្រទាំងពីរនេះ គឺមានលក្ខណៈដាច់ដោយឡែកពីគ្នា។ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាថា ចេតនា ដែលមានលក្ខណៈសម្បត្តិខ្ពស់ដូច្នេះ មិននាំឱ្យមានការសម្រាលទោសឡើយ[153]។

៧៧- ទំនោរហាក់បីដូចជាការព្រមទទួលពិរុទ្ធភាពរបស់ចុងបណ្តឹងសាទុក្ខ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរ ស-២១ ហើយក្នុងពេលទន្ទឹមគ្នានោះខ្លួនបានធ្វើការបដិសេធភស្តុតាងសំខាន់ៗមួយចំនួន ដែលចង្អុលបង្ហាញពីការពាក់ព័ន្ធដោយផ្ទាល់របស់គាត់ បានបង្កើតឱ្យមានការមន្ទិលសង្ស័យតាមផ្លូវច្បាប់ចំពោះភាពពេញលេញនៃការទទួលស្គាល់វិប្បដិសារី និងចេតនារបស់គាត់ដើម្បីជួយដល់ការស្វែងរកការពិត។ ជាការពិត វាបង្ហាញចុងបណ្តឹងសាទុក្ខព្រមទទួលពិរុទ្ធភាពដោយចេញពីវិចារណញ្ញាណពិតប្រាកដនៃការយល់ដល់អារម្មណ៍របស់ជនរងគ្រោះនោះទេ តែបានសារភាពដោយគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីសម្រាលបន្ទុកនៃទណ្ឌកម្ម ដែលខ្លួនកំពុងតែប្រឈមមុខ[154]។ ករណីនេះបានបញ្ជាក់តាមរយៈសំណើរបស់ចុងបណ្តឹងសាទុក្ខ សុំឱ្យខ្លួនរួចផុតពីបទចោទ និងសុំដោះលែងខ្លួនឱ្យមានសេរីភាពនៅថ្ងៃសវនាការចុងក្រោយ។

៧៨- ហេតុដូច្នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំក្នុងការផ្តល់ទម្ងន់លើការទទួលស្គាល់ការទទួលខុសត្រូវ និងវិប្បដិសារីរបស់ចុងបណ្តឹងសាទុក្ខ។

---

[153] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤៥១។

[154] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤៥២។

### ឃ.៣.៣.៥ ការផ្សះផ្សាជាតិ

៧៩- អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំនៅពេលសន្និដ្ឋានថា ទោះបីចុងបណ្តឹងសាទុក្ខស្នើសុំឱ្យខ្លួនរួចផុតពីបទចោទក៏ដោយ កិច្ចសហការរបស់ចុងបណ្តឹងសាទុក្ខជាមួយនឹងតុលាការ "ជួយនៅក្នុងការស្វែងរកការផ្សះផ្សាជាតិ ដែលនេះជាគោលបំណងមួយក្នុងចំណោមគោលបំណងជាច្រើនទៀតរបស់ អ.វ.ត.ក"[155]។

៨០- ការផ្សះផ្សាជាតិនឹងមាន ក្នុងករណីដែលការសារភាពពិរុទ្ធភាពរបស់ជនជាប់ចោទជម្រុញឱ្យជនដទៃទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួនដែរ[156]។ ការផ្សះផ្សាជាតិអាចឱ្យមានស្ថានសម្រាលបាន ក្នុងករណីជនជាប់ចោទជួយផ្តល់សក្ខីកម្មបំភ្លឺដល់ក្រុមគ្រួសារ និងជនរងគ្រោះ[157]។ កត្តាទាំងនេះមិនបានធ្លាប់យកមកអនុវត្ត ហើយក៏មិនបានអនុវត្តចំពោះនៅក្នុងករណី របស់ចុងបណ្តឹងសាទុក្ខនេះដែរ។

៨១- ការទទួលស្គាល់អំពីការទទួលខុសត្រូវរបស់ចុងបណ្តឹងសាទុក្ខ និងការសម្តែងវិប្បដិសារីតិចតួចស្តួចស្តើងក្នុងពេលជំនុំជម្រះមួយចំនួន (ដោយមិនគិតពីការស្នើសុំឱ្យរួចផុតពីបទចោទ) អាចជាការអះអាងថាមានប្រយោជន៍ដល់ដំណើរការផ្សះផ្សាជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក៏ប៉ុន្តែសហព្រះរាជអាជ្ញា បានស្នើអង្គជំនុំជម្រះសាលាដំបូងឱ្យវាយតម្លៃលើការចូលរួមចំណែកពីខាងចុងបណ្តឹងសាទុក្ខចំពោះដំណើរការផ្សះផ្សាជាតិ ក្រោយពីពិចារណាលើគុណសម្បត្តិសំខាន់ៗលើការទទួលស្គាល់ការទទួលខុសត្រូវ និងកិច្ចសហការរបស់ចុងបណ្តឹងសាទុក្ខ[158]។

---

[155] សាលក្រម កថាខណ្ឌ ៦០៩។

[156] *រដ្ឋអាជ្ញា ទល់នឹង Nzabirinda* សាលក្រមដាក់ទោស ICTR-2001-77-T អង្គជំនុំជម្រះសាលាដំបូងនៃ ICTR ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ ៦៨។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង *Bisengimana* កថាខណ្ឌ ២០១។

[157] សាលក្រមអង្គជំនុំជម្រះលើការដាក់ទោស *Dragan Nikolić* កថាខណ្ឌ ២៤៧-២៤៨, ២៥២។

[158] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤៣៩។

៨២- សាក្សីជំនាញបានផ្តល់សក្ខីកម្មនាពេលសវនាការថា ឥទ្ធិពលដ៏ខ្លាំងក្លាបំផុតដែលសវនាការជំនុំជម្រះក្តីរឿងព្រហ្មទណ្ឌអាចមានទៅលើការផ្សះផ្សាជាតិគឺ ការចងក្រង "ប្រវត្តិសាស្ត្រតែមួយនូវអ្វីដែលបានកើតឡើង"[159]។ លោក Stephane Hessel សាក្សីជំនាញដែលបានផ្តល់សក្ខីកម្មទៅតាមសំណើរបស់ចុងបណ្តឹងសាទុក្ខបានលើកឡើងថា "ការផ្សះផ្សាជាតិអាចដើរទន្ទឹមគ្នាជាមួយនឹងទស្សនាទាននៃសច្ចភាពតែប៉ុណ្ណោះ"[160]។ ប្រសិនបើការលាតត្រដាងទាំងស្រុង និងការយល់ព្រមទទួលស្គាល់ទាំងស្រុងចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ គឺជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ការផ្សះផ្សានោះ ជាការពិតវាត្រូវតែដូច្នេះ នៅពេលនោះការខិតខំប្រឹងប្រែងរបស់ចុងបណ្តឹងសាទុក្ខដើម្បីបង្រួមចំនួនភស្តុតាងក្នុងពេលសវនាការ និងការប៉ុនប៉ងរបស់គាត់ដើម្បីជំទាស់តវ៉ារឿងក្តីជាមួយសហព្រះរាជអាជ្ញានឹងកាត់បន្ថយនូវតម្លៃនៃការចូលរួមរបស់គាត់ជាក់ជាមិនខាន[161]។ សហព្រះរាជអាជ្ញាកត់សម្គាល់ផងដែរថាជនរងគ្រោះដែលផ្តល់សក្ខីកម្មដល់អង្គជំនុំជម្រះសាលាដំបូង មិនមានឆន្ទៈអនុគ្រោះដល់ចុងបណ្តឹងសាទុក្ខឡើយ[162]។ ចំណុចនេះគឺជាសញ្ញាចង្អុលបញ្ជាក់អំពីអារម្មណ៍មួយផ្នែកដ៏សំខាន់របស់សហគមន៍កម្ពុជា[163]។

៨៣- ហេតុដូច្នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំក្នុងការផ្តល់ទម្ងន់ហួសហេតុពេកលើការផ្សះផ្សាជាតិ ប៉ុន្តែបើសំអាងលើទង្វើ និងអាកប្បកិរិយានានារបស់ចុងបណ្តឹងសាទុក្ខ នៅក្នុងការផ្តន្ទាទោសទោសដល់ចុងបណ្តឹងសាទុក្ខ ក្នុងកម្រិតមួយតិចតួច។

---

[159] ប្រតិចារឹកសវនាការ Richard Goldstone ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ T.២៦។

[160] ប្រតិចារឹកសវនាការ Stephane Hessel ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ T.៦៣។

[161] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៥៤១។

[162] សហព្រះរាជអាជ្ញាយោងជាទូទៅលើប្រតិចារឹកសវនាការនៃសាក្សីទាំងឡាយនេះ ហេតុដូច្នេះហើយ មិនបានដកស្រង់សំដីទាំងស្រុងនោះទេ៖ Hamill Robert តូច មុនិន្ទ, អ៊ឹម ស៊ុន្នី, ស៊ាង វ៉ាន់ឌី, ភឹងហួត ស៊ុនថារី, អោគ ខន អ៊ូ សាវរិទ្ធ, សូ សួង ជុំ ស៊ីរ៉ាត, អ៊ុក នារី, Lefeuvre Martine, ជូឡុង អង់តូនីយ៉ា, ជុំ នៅ, ឈិន ណារី, នេត ផល្លី និង ហាវ សោភា។

[163] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៥៤១។

ឃ.៣.៣.៦ ការស្តារនីតិសម្បទា និងការចូលរួមរស់នៅក្នុងសង្គមឡើងវិញ

៨៤- អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំក្នុងការផ្តល់ទម្ងន់ហួសហេតុពេកថា ចុងបណ្តឹងសាទុក្ខអាចមានសមត្ថភាពភាពទទួលការស្តារនីតិសម្បទា និងអាចចូលរួមរស់នៅក្នុងសង្គមឡើងវិញ[164]។

៨៥- អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំនៅពេលរកឃើញថា ចុងបណ្តឹងសាទុក្ខៈ (១) ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែល "មានភាពធ្ងន់ធ្ងរខ្លាំង" និងដែលស្ថិតនៅក្នុងប្រភេទដ៏អាក្រក់ក្រៃលែងនៅចំពោះមុខសាលាក្តីអន្តរជាតិ (២) បានស្នើសុំឱ្យរួចផុតពីបទចោទ (៣) អះអាងថាខ្លួនមិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬ ជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង (៤) តវ៉ាយុត្តាធិការរបស់តុលាការដែលចោទប្រកាន់ខ្លួន។ ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើសមត្ថភាពរបស់ចុងបណ្តឹងសាទុក្ខ ដែលអាចចូលរួមរស់ជាមួយនឹងជនរងគ្រោះនៃរបបខ្មែរក្រហមឡើងវិញនោះ គឺមិនស៊ីសង្វាក់នឹងការអះអាងរបស់ចុងបណ្តឹងសាទុក្ខ ដែលបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខចំពោះសាលក្រមថាតុលាការនេះគួររកឃើញថា ចុងបណ្តឹងសាទុក្ខគឺជា"សាក្សីនៃហេតុការណ៍" តែមួយរូបនៅស-២១ និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[165]។

៨៦- អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំ នៅពេលសន្និដ្ឋានដូច្នេះ ទោះបីជាបានស្តាប់សក្ខីកម្មរបស់សាក្សីជំនាញផ្នែកចិត្តសាស្ត្រហើយក៏ដោយ ក៏ចុងបណ្តឹងសាទុក្ខគ្មានមនោសញ្ចេតនា ហើយ

---

[164] សាលក្រម កថាខណ្ឌ ៦១៦។

[165] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច ចំពោះសាលក្រមអង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ សំណុំរឿងលេខ 001/18-0/-2007-អវតក/អជសដ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ E188/8 កថាខណ្ឌ ៨។

អាចបង្កើតនូវយន្តការការពារដ៏រឹងមាំ ដែលជួយទប់ទល់គាត់មិនឱ្យមានប្រតិកម្មផ្លូវអារម្មណ៍ និងការប៉ះទង្គិចខាងក្នុងខ្លួន ដែលបណ្តាលមកពីតថភាពខាងក្រៅរបស់គាត់។ អ្នកជំនាញពិពណ៌នាទៀតថា នេះជាយន្តការដែលជាមូលដ្ឋានអាចឱ្យជនជាប់ចោទអាចចិញ្ចឹមបីបាច់ក្រុមគ្រួសាររបស់គាត់ដោយមិនមានការខ្វាយខ្វល់អំពីសេចក្តីស្លាប់របស់កុមារនៅមន្ទីរស-២១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់នោះទេ[166]។

៨៧- អង្គជំនុំជម្រះសាលាដំបូងក៏ខកខានមិនបានពិចារណាថា យុត្តិកម្មចំបងចំនួនពីរចំពោះការដាក់ទោសនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺ ការធ្វើឱ្យភ័យខ្លាច និងបដិទាន[167]។ ការធ្វើឱ្យភ័យខ្លាច មានពីរទម្រង់គឺដើម្បីឱ្យបុគ្គលម្នាក់ ឬ បុគ្គលទូទៅភ័យខ្លាច[168]។ ការធ្វើឱ្យបុគ្គលម្នាក់ភ័យខ្លាចគឺមានគោលដៅជម្រុញកុំឱ្យជនជាប់ចោទប្រព្រឹត្តឧក្រិដ្ឋកម្មសារជាថ្មី ចំណែកការធ្វើឱ្យបុគ្គលទូទៅភ័យខ្លាចគឺការព្យាយាមឱ្យសង្គមទាំងមូលមានការភ័យខ្លាចនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មអន្តរជាតិ[169]។

៨៨- ទស្សនាទាននៃបដិទាន គឺមានន័យថា "សមនឹងទទួល" មិនមែនមានន័យថា សងសឹកឡើយ[170]។ ទណ្ឌកម្មដែល "ឆ្លុះបញ្ចាំងពិរុទ្ធភាពរបស់ជនល្មើសបានសមរម្យនោះ"[171] ស្របគ្នាជាមួយនឹងកាតព្វកិច្ចដ៏សំខាន់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដាក់ទោសឱ្យបានសមស្របលើជនជាប់ចោទ

---

[166] សាលក្រម កថាខណ្ឌ ៦១៤។

[167] *រដ្ឋអាជ្ញា ទល់នឹង Barayagwiza* សាលដីកា ICTR-99-52-A អង្គជំនុំជម្រះតុលការកំពូលនៃ ICTR ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ ១០៥៧។ សាលដីកា *Stakic* កថាខណ្ឌ ៤០២។ សាលដីកា *Celebici* កថាខណ្ឌ ៨០៦។

[168] *រដ្ឋអាជ្ញា ទល់នឹង Kordic* និង *Cerkez* សាលដីកា IT-95-14/2-A អង្គជំនុំជម្រះតុលាការកំពូលនៃ ICTY ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ ("សាលដីកា *Kordic* និង *Cerkez*) កថាខណ្ឌ ១០៧៦។

[169] សាលដីកា *Kordic* និង *Cerkez* កថាខណ្ឌ ១០៧៧-១០៧៨។

[170] សាលដីកា *Kordic* និង *Cerkez* កថាខណ្ឌ ១០៧៥។

[171] សាលដីកា *Kordic* និង *Cerkez* កថាខណ្ឌ ១០៧៥ (ដកស្រង់ *R ទល់នឹង* M. (C.A.) [1996] 1 S.C.R. 500 កថាខណ្ឌ ៨០។

ក្រោយពីពិចារណាលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងកាលៈទេសៈ និងតួនាទីរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មទាំងនោះ។ បន្ថែមពីនេះ បដិទានមានការជាប់ពាក់ព័ន្ធនឹងការស្តីបន្ទោសផ្នែកសីលធម៌ និងការនាំឱ្យមានការឯកភាពលើយន្តការពង្រឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដោយសារបដិទាន "បានសម្តែងយ៉ាងត្រឹមត្រូវនូវកំហឹងរបស់សហគមន៍អន្តរជាតិចំពោះឧក្រិដ្ឋកម្មទាំងនេះ"[172]។

៨៩- ទោះបីជាតុលាការអន្តរជាតិនានាបានលើកឡើងថា ការស្តារនីតិសម្បទាឡើងវិញ គឺជាកត្តាមួយសម្រាប់កំណត់ទោសក៏ដោយ[173] សហព្រះរាជអាជ្ញាសន្និដ្ឋាននៅក្នុងសារណារបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំនៅក្នុងការផ្តល់ទម្ងន់ហួសហេតុពេក ឬក៏បានផ្តល់ទម្ងន់ទាំងអស់លើសមត្ថភាពភាពរបស់ចុងបណ្តឹងសាទុក្ខថាអាចស្តារនីតិសម្បទាឡើងវិញ ដោយមិនបានបង្ហាញឱ្យឃើញផងនោះ។

## ឃ.៣.៤ សេចក្តីសន្និដ្ឋាន

៩០- សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំនៅក្នុងការផ្តល់ទម្ងន់ហួសហេតុពេក នៅពេលសម្រេចដោយភាន់ច្រឡំលើ "ស្ថានសម្រាលទោសសំខាន់ៗ" និង ដោយសារការសម្រេចដូច្នេះ ធ្វើឱ្យមានការភាន់ច្រឡំយ៉ាងច្បាស់ក្រឡែតលើការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងការដាក់ទោស ហើយនិងការសម្រេចកំណត់ទោសមួយដែលមិនសមស្រប និងតាមអំពើចិត្តយ៉ាងច្បាស់ក្រឡែត។

---

[172] *រដ្ឋអាជ្ញា ទល់នឹង Aleksovski* សាលដីកា IT-95-14/1-A អង្គជំនុំជម្រះតុលាការកំពូលនៃ ICTY ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ ("សាលដីកា *Aleksovski*) កថាខណ្ឌ ១៨៥។

[173] ទោះបីជាការស្តារនីតិសម្បទាឡើងវិញគឺជាគោលបំណងនៃការដាក់ទោសមួយដ៏ត្រឹមត្រូវតាមផ្លូវច្បាប់ក៏ដោយ តុលាការក៏បានបញ្ជាក់ថា គេមិនគួរផ្តល់ទម្ងន់ហួសហេតុពេកដល់ការស្តារនីតិសម្បទាឡើងវិញឡើយ។ *សូមមើល* សាលដីកា *Kordic* និង *Cerkez* កថាខណ្ឌ ១០៧៩។ *រដ្ឋអាជ្ញា ទល់នឹង Blagojevic* និង *Jokic* សាលក្រម IT-02-60-T អង្គជំនុំជម្រះនៃ ICTY ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៨២៤។

## ឃ.៤ ការដាក់ទោសធ្វើឡើងតាមអំពើចិត្ត និងមិនគ្រប់គ្រាន់យ៉ាងច្បាស់

### ឃ.៤.១ ទិដ្ឋភាពរួម

៩១- គ្រប់សេចក្តីសម្រេចរបស់តុលាការត្រូវមានសំអាងហេតុ នេះគឺជាបទដ្ឋានអន្តរជាតិ[174] ហើយអនុវត្តដូចគ្នាចំពោះសេចក្តីសម្រេចដែលបានធ្វើឡើងដោយផ្អែកលើឆន្ទានុសិទ្ធិ ដូចជា សេចក្តីសម្រេច លើការដាក់ទោស[175]។ ការផ្តល់សំអាងហេតុ អនុញ្ញាតឱ្យភាគីយល់អំពីហេតុផលនៅក្នុងសេចក្តីសម្រេច ហើយក្នុងករណីមានការប្តឹងសាទុក្ខ អនុញ្ញាតឱ្យតុលាការជាន់ខ្ពស់អាចអនុវត្តការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខដោយមានប្រសិទ្ធភាព[176]។ ច្បាប់តម្រូវឱ្យចៅក្រម ដែលចេញសេចក្តីសម្រេចផ្តល់សំអាងហេតុនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ការខកខានធ្វើដូច្នេះគឺនឹងបណ្តាលឱ្យមានកំហុសលើអង្គច្បាប់[177]។

៩២- សាលក្រមមិនបានផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅពេល

---

[174] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព សំណុំរឿងលេខ 002/19-09-2007/អវតក/កសចស (អបជ ០៦) អង្គបុរេជំនុំជម្រះ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ D55/I/8 ("បណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព") កថាខណ្ឌ ២១ (ដែលដកស្រង់សេចក្តីសម្រេចរបស់គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប (ECHR) និង ICTY)។

[175] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" សំណុំរឿងលេខ 002/19-09-2007/អវតក/កសចស (អបជ ៦២) អង្គបុរេជំនុំជម្រះ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ D353/2/3 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍លើសំណើសុំបំពេញកិច្ចស៊ើបសួររបស់ អៀង ធីរិទ្ធ") កថាខណ្ឌ ២៣។

[176] សាលដីកាលើបណ្តឹងឧទ្ធរណ៍លើសំណើសុំបំពេញកិច្ចស៊ើបសួររបស់ អៀង ធីរិទ្ធ កថាខណ្ឌ ២៨ (ដែលបានដកស្រង់សេចក្តីសម្រេចរបស់ ECHR និង ICTY)។

[177] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសំណើសុំបញ្ចូលឯកសារភស្តុតាងបន្ថែមនៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង សំណុំរឿងលេខ 002/19-09-2007-អវតក/កសចស (អបជ ៦៧) អង្គបុរេជំនុំជម្រះ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ D365/2/10 កថាខណ្ឌ ២៦។

ដាក់ទោសចុងបណ្តឹងសាទុក្ខកំណត់ ៣៥ឆ្នាំ ហេតុដូច្នេះសាលក្រមនេះ (១) បានសម្រេចទោសតាមអំពើចិត្ត (២) ដោយមិនផ្អែកលើយុត្តិសាស្ត្រនៅក្នុងរឿងក្តីណាមួយដែលមានលក្ខណៈស្រដៀងគ្នា និងដោយមិនផ្អែកលើច្បាប់ពាក់ព័ន្ធទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅពេលជំនុំជម្រះ។ ករណីនេះមានន័យថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំលើអង្គច្បាប់យ៉ាងច្បាស់ក្រឡែតនៅពេលសម្រេចដាក់ទោសមួយមិនសមស្របយ៉ាងច្បាស់លើចុងបណ្តឹងសាទុក្ខ។ ការដាក់ទោសនេះស្ថិតនៅក្រៅរង្វង់ទោស ដែលអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចនៅក្នុងកាលៈទេសៈនៃរឿងក្តីនេះ។

៩៣- យុត្តិសាស្ត្រអន្តរជាតិដែលធ្លាប់សម្រេចរួចហើយលើកឡើងថា "សេចក្តីសម្រេចមុនៗលើការដាក់ទោសអាចជាបទដ្ឋានណែនាំ ប្រសិនបើវាពាក់ព័ន្ធនឹងបទល្មើសដូចគ្នា និងប្រសិនបើបទល្មើសនោះបានប្រព្រឹត្តនៅក្នុងកាលៈទេសៈសំខាន់ៗស្រដៀងគ្នា"[178]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការកំណត់ទោសខុសៗគ្នាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTY បានលើកឡើងថា "នៅក្នុងករណីមានកាលៈទេសៈអង្គហេតុ និងការកាត់ទោសស្រដៀងគ្នា [...] ទោសមិនត្រូវមានភាពខុសគ្នាខ្លាំងនោះទេ លើកលែងតែកាលៈទេសៈរបស់ជនជាប់ចោទជាក់លាក់ណាមួយ បានផ្តល់យុត្តិកម្មយ៉ាងត្រឹមត្រូវ"[179]។

៩៤- នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងមិនបានដកស្រង់សំអាងហេតុណាមួយ ដែលដូចជាមិនសូវមានសំអាងមូលដ្ឋានផ្លូវច្បាប់ ដែលជម្រុញឱ្យខ្លួនដាក់ទោសកំណត់ ៣៥ឆ្នាំ លើចុងបណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះសាលាដំបូងក៏មិនបានបញ្ជាក់ហេតុផល ដែលខ្លួនបានយករយៈពេលនេះមក

---

[178] *រដ្ឋអាជ្ញា ទល់នឹង Furundcija* សាលដីកា IT-95-17/1-A អង្គជំនុំជម្រះតុលាការកំពូលនៃ ICTY ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ ២៥០។

[179] សាលដីកា *Celebici* កថាខណ្ឌ ៧៥៨។

ចាប់ផ្តើមពិចារណាលើស្ថានសម្រាលទោសដែរ។ អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់យុត្តិកម្ម ដែលខ្លួនចាប់ផ្តើមពីការអនុវត្តនៅក្នុងក្របខណ្ឌអន្តរជាតិ។ ជាការពិតទៅ ការអនុវត្តបែប នេះមិនមានអត្ថិភាព។ ការភាន់ច្រឡំលើអង្គច្បាប់ដ៏ច្បាស់បែបនេះ ដែលអង្គជំនុំជម្រះតុលាការកំពូលគួរតែកែតម្រូវ គឺត្រូវយកទោសដែលធ្ងន់ជាងនេះមកជំនួសទោសរយៈពេលកំណត់ ៣៥ឆ្នាំ។ អង្គជំនុំជម្រះតុលាការកំពូលគួរសម្រេចដោយដាក់ទោស ដែលស្ថិតនៅក្នុងរង្វង់នៃទោស ដែលអាចអនុវត្តចំពោះរឿងក្តីរបស់ចុងបណ្តឹងសាទុក្ខ ដោយផ្អែកលើរឿងក្តីនៃចុងចោទទាំងឡាយដែលមានស្ថានភាពស្រដៀងគ្នានៅចំពោះសាលាក្តីនានា ដែលជំនុំជម្រះសេចក្តីលើរឿងក្តីស្រដៀងៗគ្នា។

## ឃ.៤.២ ការខកខានមិនបានពិចារណាលើច្បាប់ជាធរមាន

### ឃ.៤.២.១ ទូទៅ

៩៥- អង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងកថាខណ្ឌ ៦៣១ នៃសាលក្រមថា "ដោយផ្អែកលើហេតុផលខាងលើ" អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ទោសសមស្របចំពោះចុងបណ្តឹងសាទុក្ខនោះគឺ ៣៥ឆ្នាំ។ ប៉ុន្តែ នៅពេលពិនិត្យឡើងវិញលើកថាខណ្ឌមុនៗនៅក្នុងសាលក្រម វាបានបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងមិនបានដកស្រង់ ឬ ពិចារណាច្បាប់ណាមួយឡើយ រួមទាំងច្បាប់ដែលដាក់ជូនដោយសហព្រះរាជអាជ្ញាផងនោះ ដែលច្បាប់នេះបានចែងអំពីរង្វង់នៃទោសនៅក្នុងរឿងក្តីស្រដៀងៗគ្នា។ តាមពិត ការពិពណ៌នានៅក្នុងកថាខណ្ឌដំបូងៗមុនកថាខណ្ឌ ៦៣១ ដែលជាកថាខណ្ឌគ្រង់ផ្នែកនៃសេចក្តីសម្រេច គឺជាការពិពណ៌នាអំពីស្ថានទម្ងន់ និងស្ថានសម្រាលទោសដែលអាចអនុវត្តបានចំពោះរឿងក្តីរបស់ចុងបណ្តឹងសាទុក្ខនេះ[180]។ អង្គជំនុំជម្រះសាលាដំបូងបាន

[180] សាលក្រម កថាខណ្ឌ ៦០១-៦០៥ (ស្តីពីស្ថានទម្ងន់ទោស) ៦០៦-៦១១ (ស្តីពីស្ថានសម្រាលទោស) ៦១២-៦១៦ (ស្តីពីការវាយតម្លៃផ្នែកចិត្តសាស្ត្រ និងវិកលចរិត លើចុងបណ្តឹងសាទុក្ខ) ៦១៧-៦២២ (ស្តីពីសាក្សីលើអត្តចរិត) ៦២៣-៦២៧

លើកឡើងតែមួយប្រយោគ ដោយមិនយកច្បាប់ជាធរមានមកវិភាគដើម្បីជាមូលដ្ឋានឡើយថា "ពិតជាមានស្ថានសម្រាលទោសដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះកំណត់ទោសដាក់ពន្ធនាគារ ដែលមានរយៈពេលកំណត់ជាក់លាក់មួយបាន ក្នុងករណីដែលទោសដាក់ពន្ធនាគារអស់មួយជីវិតមិនត្រូវយកមកអនុវត្តនោះ"[181]។

៩៦- ការវិភាគនេះ ឬក៏គ្មានតែម្តង របស់អង្គជំនុំជម្រះសាលាដំបូងមិនបានបំពេញលក្ខខណ្ឌដ៏តឹងរ៉ឹងដែលវាជាលក្ខខណ្ឌនៃការចេញសាលក្រម ដោយមានសំអាងហេតុមួយដោយតុលាការព្រហ្មទណ្ឌអន្តរជាតិមួយ ដែលតុលាការនេះជំនុំជម្រះលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងឡាយ ដែលមិនធ្លាប់ជំនុំជម្រះដោយស្ថាប័នតុលាការ។ តាមពិតទៅ អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំលើអង្គច្បាប់នៅក្នុងករណីនេះ ដែលតាមអង្គច្បាប់នាំឱ្យមោឃភាពសាលក្រមនេះ[182]។ ហេតុដូច្នេះ វាជារឿងក្តីមួយសមស្រប ដែលអង្គជំនុំជម្រះតុលាការកំពូលគួរចាត់ការដើម្បីផ្តល់សំអាងហេតុរបស់ខ្លួនលើរយៈពេលកំណត់នៃទោសមកជំនួសសេចក្តីសម្រេច ដោយមិនមានសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។

### *ឃ.៤.២.២ សាលក្រមមិនអើពើចំពោះយុត្តិសាស្ត្រពាក់ព័ន្ធដែលសហព្រះរាជអាជ្ញាបានលើកយោង*

៩៧- ក្រៅពីមិនបានផ្អែកទៅលើឯកសារសំអាងតាមផ្លូវច្បាប់ ចំពោះរយៈពេលនៃការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូងក៏មិនបានពិចារណាទៅលើយុត្តិសាស្ត្រ និងការវិភាគដែលសហព្រះរាជអាជ្ញាបាន

(ស្តីពីផលប៉ះពាល់លើការរំលោភសិទ្ធិមនុស្សពីមុនលើចុងបណ្តឹងសាទុក្ខ នៅពេលដាក់ទោស) ៦២៨-៦៣០ (លើកឡើងជាទូទៅអំពីការដាក់ទោស ដោយមិនមានកំណត់តាមរយៈពេលនៃទោសទៅតាមច្បាប់។

[181] សាលក្រម កថាខណ្ឌ ៦២៩។

[182] ដើម្បីបំពេញលក្ខខណ្ឌនៃវិធាន ១០៤(១)(ក)នៃវិធានផ្ទៃក្នុងចំពោះភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ។

លើកយោងឡើយ[183]។ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល សហព្រះរាជអាជ្ញាបានផ្តល់ការវិភាគទៅលើការដាក់ទោស នៅក្នុងរឿងក្តីនានាដែលប្រហាក់ប្រហែលគ្នា នៅតុលាការអន្តរជាតិនានាដូចជា តុលាការ ICTY តុលាការ ICTR និង តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន("SCSL") ដោយផ្តោតទៅលើការវិនិច្ឆ័យឲ្យមានទោសចំពោះជនជាប់ចោទ ដែលកាន់តួនាទីដែលមានសិទ្ធិអំណាចសំខាន់ ដែលទទួលខុសត្រូវក្នុងការសម្លាប់មនុស្សដ៏ច្រើន (ចាប់ពីមួយរយនាក់ឡើងទៅ) និងដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរយៈពេលមួយដ៏យូរអង្វែង[184]។ ដោយឡែក សហព្រះរាជអាជ្ញាបានលើកឡើងដូចខាងក្រោម[185]៖

ក. ចាប់តាំងពីឆ្នាំ២000 មក មានជនជាប់ចោទ៧៦នាក់ ត្រូវបានវិនិច្ឆ័យឲ្យមានទោស និងផ្តន្ទាទោសដាក់ពន្ធនាគារនៅតុលាការ ICTY ទាំងនៅសាលាដំបូង និងតុលាការជាន់ខ្ពស់។ ក្នុងចំណោមនោះ មានជនជាប់ចោទ៤0នាក់ ដែលកាន់តួនាទីដែលមានសិទ្ធិអំណាចសំខាន់[186]

---

[183] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤៥៣-៤៥៦។

[184] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ ៤៥៣។

[185] ការវាយតម្លៃនេះត្រូវបានធ្វើឡើងនៅថ្ងៃទី១១ វិច្ឆិកា ២០០៩ ជាកាលបរិច្ឆេទនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល។

[186]សហព្រះរាជអាជ្ញាយោងជាទូទៅដល់ករណីរឿងក្តីខាងក្រោម និងផ្តល់តារាងព័ត៌មានអង្គហេតុពីករណីរឿងក្តីដូចខាងក្រោម នៅក្នុងឧបសម្ព័ន្ធ កៈ ឯកសារព័ត៌មានករណីរឿងក្តីដែលបានជ្រើសរើសពី ICTY, ICTR(ដូចដែលមានចែងដោយ Hague Justice Portal) និង SCSL៖ សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Aleksovski* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Babic* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Blagojevic* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Blaskic* សាលក្រមសាលាដំបូងលើរឿងក្តី *Brahimaj* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Brdanin* សាលក្រមសាលាដំបូងលើរឿងក្តី *Delic* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Delic* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Deronjic* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Galic* សាលក្រមសាលាដំបូងលើរឿងក្តី *Hadžihasanović* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Jelisić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Jokic* សាលក្រមសាលាដំបូងលើរឿងក្តី *Kordic* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Krajišnik* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Krnojelac* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Krstić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Kunarac* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Kvočka* សាលក្រមសាលាដំបូងលើរឿងក្តី *Lazarević* សាលក្រមសាលាដំបូងលើរឿងក្តី*Milan Lukić* សាលក្រមសាលាដំបូងលើរឿងក្តី *Sreten Lukić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Martić*

ហើយក្នុងចំណោមអ្នកទាំង ៤០ នាក់នោះ មាន២១នាក់ ទទួលខុសត្រូវលើការបាត់បង់អាយុជីវិតប្រជាជនលើសពី១០០នាក់ឡើងទៅ[187]។ ជាមធ្យមភាគ (គិតជាឆ្នាំ) ជនជាប់ចោទទាំងនេះបានទទួលការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២៥,៦ ឆ្នាំ។ ជាក់លាក់ជាងនេះទៅទៀត ក្នុងចំណោមរឿងក្តីទាំង ២១ ករណី ដែលបណ្តាឧក្រិដ្ឋកម្មទាំងឡាយត្រូវបានប្រព្រឹត្តឡើងចាប់ពី ១ ខែឡើងទៅ ការផ្តន្ទាទោសដាក់ពន្ធនាគារជាមធ្យមគឺមានរយៈពេល ២៦ឆ្នាំ។ ប្រសិនបើរយៈពេលដែលអំពើឧក្រិដ្ឋនោះបានប្រព្រឹត្តបន្តលើសពី ១ឆ្នាំឡើងទៅ ដូចនៅក្នុងករណីរឿងក្តីនេះ ការផ្តន្ទាទោសដាក់ពន្ធនាគារជាមធ្យម គឺមានរយៈពេល ៤៤ ឆ្នាំ[188]។

---

សាលក្រមសាលាដំបូងលើរឿងក្តី *Dragomir Milošević* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Mrkšić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Mucić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Naletilić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Dragan Nikolić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Momir Nikolić* សាលក្រមសាលាដំបូងលើរឿងក្តី *Obrenović* សាលក្រមសាលាដំបូងលើរឿងក្តី *Ojdanić* សាលក្រមសាលាដំបូងលើរឿងក្តី *Pavković* សាលក្រមសាលាដំបូងលើរឿងក្តី *Plavšić* សាលក្រមសាលាដំបូងលើរឿងក្តី *Rajić* សាលក្រមសាលាដំបូងលើរឿងក្តី *Šainović* សាលក្រមសាលាដំបូងលើរឿងក្តី *Sikirica* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Simić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Stakić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Strugar* សាលក្រមសាលាដំបូងលើរឿងក្តី *Todorović*។

[187] សូមមើលឧបសម្ព័ន្ធ គៈ សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Babić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Blagojević* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *BlaÈkić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Brđanin* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Galić* សាលក្រមសាលាដំបូងលើរឿងក្តី *Kordić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *KrajiÈnik* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Krstić* សាលក្រមសាលាដំបូងលើរឿងក្តី *Lazarević* សាលក្រមសាលាដំបូងលើរឿងក្តី *Milan Lukić* សាលក្រមសាលាដំបូងលើរឿងក្តី *Sreten Lukić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Martić* សាលក្រមសាលាដំបូងលើរឿងក្តី *Dragomir MiloÈević* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *MrkÈić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Naletilić* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Momir Nikolić* សាលក្រមសាលាដំបូងលើរឿងក្តី *Obrenović* សាលក្រមសាលាដំបូងលើរឿងក្តី *Ojdanić* សាលក្រមសាលាដំបូងលើរឿងក្តី *Pavković* សាលក្រមសាលាដំបូងលើរឿងក្តី *Èainović* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Stakić*។

[188] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ៤៥៤។

ខ. ចាប់តាំងពីឆ្នាំ១៩៩៨មក មានជនជាប់ចោទ ៣៩ នាក់ ត្រូវបានវិនិច្ឆ័យឱ្យមានទោស និងផ្តន្ទាទោសដាក់ពន្ធនាគារនៅតុលាការ ICTR ទាំងនៅសាលាដំបូង និងតុលាការជាន់ខ្ពស់[189]។ ក្នុងចំណោមនោះ មានជនទាំង២២នាក់ បានកាន់តួនាទីដែលមានសិទ្ធិអំណាចសំខាន់[190] ហើយក្នុងចំណោមនោះ មាន២០នាក់ ទទួលខុសត្រូវលើការបាត់បង់អាយុជីវិតប្រជាជន

---

[189] សូមមើលឧបសម្ព័ន្ធ គ៖ សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Akayesu* សាលក្រមសាលាដំបូងលើរឿងក្តី*Bagosora* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Barayagwiza* សាលក្រមសាលាដំបូងលើរឿងក្តី*Bikindi* សាលក្រមសាលាដំបូងលើរឿងក្តី *Bisengimana* សាលក្រមដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Gacumbitsi* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Imanishimwe* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kajelijeli* សាលក្រមសាលាដំបូងលើរឿងក្តី*Kalimanzira* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kambanda* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kamuhanda* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kayishema* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kerera* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Muhimana* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Musema* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Nahimana* សាលក្រមសាលាដំបូងលើរឿងក្តី *Nchaminhigo* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Ndindabahizi* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Ngeze* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Niyitegeka* សាលក្រមសាលាដំបូងលើរឿងក្តី*Nsengiyumva* សាលក្រមសាលាដំបូងលើរឿងក្តី*Nshogoza* សាលក្រមសាលាដំបូងលើរឿងក្តី *Ntabakuze* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Ntakirutimana* សាលក្រមសាលាដំបូងលើរឿងក្តី*Nzabirinda* សាលក្រមសាលាដំបូងលើរឿងក្តី*Renzaho* សាលក្រមសាលាដំបូងលើរឿងក្តី *Rugambarara* សាលក្រមសាលាដំបូងលើរឿងក្តី*Ruggiu* សាលក្រមសាលាដំបូងលើរឿងក្តី *Rukundo* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Rutaganda* សាលក្រមសាលាដំបូងលើរឿងក្តី *Rutanganira* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Ruzindana* សាលក្រមសាលាដំបូងលើរឿងក្តី *Semanza* សាលក្រមសាលាដំបូងលើរឿងក្តី*Seromba* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Seromba* សាលក្រមសាលាដំបូងលើរឿងក្តី*Serugendo* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Serushago* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Simba* សាលក្រមសាលាដំបូងលើរឿងក្តី*Zigiranyirazo*។

[190] សូមមើលឧបសម្ព័ន្ធ គ៖ សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Akayesu* សាលក្រមសាលាដំបូងលើរឿងក្តី*Bagosora* សាលក្រមសាលាដំបូងលើរឿងក្តី*Bisengimana* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Gacumbitsi* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Imanishimwe* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kajelijeli* សាលក្រមសាលាដំបូងលើរឿងក្តី *Kalimanzira* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kambanda* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kamuhanda* សាលដីកា សាលាឧទ្ធរណ៍លើរឿងក្តី *Karera* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kayishema* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Muhimana* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Ndindabahizi* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Niyitegeka* សាលក្រមសាលាដំបូងលើរឿងក្តី *Nsengiyumva* សាលក្រមសាលាដំបូងលើរឿងក្តី*Ntabakuze* សាលក្រមសាលាដំបូងលើរឿងក្តី*Renzaho* សាលក្រមសាលាដំបូងលើរឿងក្តី*Rugambarara* សាលក្រមសាលាដំបូងលើរឿងក្តី*Rutaganira* សាលក្រមសាលាដំបូងលើរឿងក្តី*Semanza* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Serushago* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Simba*។

លើសពី១០០នាក់ឡើងទៅ[191]។ ជាមធ្យមភាគ(គិតជាឆ្នាំ) ជនជាប់ចោទទាំងអស់នេះបាន ទទួលការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៣៧,៨៥ ឆ្នាំ។ ពិសេសជាងនេះទៅទៀត ក្នុង ចំណោមរឿងក្តីទាំងអស់នេះដែលបណ្តាឧក្រិដ្ឋកម្មទាំងឡាយត្រូវបានប្រព្រឹត្តចាប់ពីមួយខែ ឡើងទៅ ការផ្តន្ទាទោសដាក់ពន្ធនាគារជាមធ្យមគឺមានរយៈពេល ៤៥,៤២ ឆ្នាំ[192]។

គ. ចាប់តាំងពីឆ្នាំ២០០០ មក មានជនជាប់ចោទប្រាំបីនាក់ត្រូវបានវិនិច្ឆ័យឱ្យមានទោស និង ផ្តន្ទាទោសដាក់ពន្ធនាគារនៅតុលាការ SCSL ទាំងនៅសាលាដំបូង ឬតុលាការជាន់ខ្ពស់[193]។ ជនជាប់ចោទទាំងអស់បានកាន់តួនាទីដែលមានសិទ្ធិអំណាចយ៉ាងសំខាន់ ហើយអ្នកទាំង អស់គ្នានេះបានទទួលខុសត្រូវលើការបាត់បង់អាយុជីវិតប្រជាជនលើសពី១០០នាក់។ ការ ផ្តន្ទាទោសដាក់ពន្ធនាគារជាមធ្យមគឺមានរយៈពេល ៣៧ ឆ្នាំ។ ជនជាប់ចោទទាំងអស់ត្រូវ បានវិនិច្ឆ័យឱ្យមានទោសពីបទប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗ ដែលត្រូវបានប្រព្រឹត្តក្នុងរយៈពេល ចាប់ពី១ខែឡើងទៅ។ មិនដូចនៅក្នុងករណីរឿងក្តីរបស់ចុងបណ្តឹងសាទុក្ខនេះទេ នៅក្នុង

---

[191] សូមមើលឧបសម្ព័ន្ធ គ៖ សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Akayesu* សាលក្រមសាលាដំបូងលើរឿងក្តី*Bagosora* សាលក្រមសាលាដំបូងលើរឿងក្តី*Bisengimana* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Gacumbitsi* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kambanda* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Karera* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kajelijeli* សាលក្រមសាលាដំបូងលើរឿងក្តី*Kalimanzira* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Kayishema* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Muhimana* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Ndindabahizi* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Niyitegeka* សាលក្រមសាលាដំបូងលើរឿងក្តី*Nsengiyumva* សាលក្រមសាលាដំបូងលើរឿងក្តី*Ntabakuze* សាលក្រមសាលាដំបូងលើរឿងក្តី *Renzaho* សាលក្រមសាលាដំបូងលើរឿងក្តី *Rugambarara* សាលក្រមសាលាដំបូងលើរឿងក្តី *Rutaganira* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Serushago* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Simba* ។

[192] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ៤៥៥។

[193] សូមមើលឧបសម្ព័ន្ធ គ៖ សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Brima* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី*Fofana* និង *Kondewa* សាលក្រមសាលាដំបូងលើរឿងក្តី*Sesay*។

តុលាការនោះគឺគ្មានជនជាប់ចោទណាមួយបានប្រព្រឹត្តអំពើឧក្រិដ្ឋដែលប្រើរយៈពេលដ៏យូរអង្វែងដូចនេះទេ[194]។

៩៨- ក្រៅពីមិនបានផ្តល់នូវសំអាងហេតុនានា ដើម្បីគាំទ្រដល់ការសម្រេចពីរយៈពេលនៃការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៣៥ ឆ្នាំនោះ អង្គជំនុំជម្រះសាលាដំបូងក៏ខកខានមិនបានផ្តល់សំអាងហេតុចំពោះការមិនអើពើរបស់ខ្លួន ឬដែលខ្លួនមិនបានផ្អែកទៅលើ ចំពោះការអនុវត្ត និងយុត្តិសាស្ត្រដែលសហព្រះរាជអាជ្ញាបានលើកយោង។ នេះជាការអនុវត្តដោយភាន់ច្រឡំនូវឆន្ទានុសិទ្ធិ ហើយតម្រូវឱ្យមានការធ្វើអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូល។

៩៩- ដើម្បីជាជំនួយ និងដើម្បីសម្រួលជាឯកសារយោងដល់អង្គជំនុំជម្រះតុលាការកំពូល សហព្រះរាជ-អាជ្ញា សូមផ្តល់ជាឯកសារស្ទាបស្ទង់មតិមួយដែលមាននៅក្នុងឧបសម្ព័ន្ធ ខ ស្តីពីការផ្តន្ទាទោសនានាដោយតុលាការ ICTY, ICTR និង SCSL ដែលពាក់ព័ន្ធនឹងជនជាប់ចោទនានា ដូចជាចុងបណ្តឹងឧទ្ធរណ៍ រូបនេះជាដើម ដែលឋិតនៅក្នុងតំណែងជាអ្នកដឹកនាំ ត្រូវបានរកឃើញពីការទទួលខុសត្រូវចំពោះការស្លាប់ជនរងគ្រោះចំនួនច្រើនជាងមួយរយនាក់[195] ។

*ឃ.៤.២.៣ ករណីនេះជាផ្នែក "ដ៏អាក្រក់បំផុត" នៃករណីរឿងក្តីនានា*

១០០- ទោះបីអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការសម្រេចលើបញ្ហាផ្តន្ទាទោសក៏ដោយ ក៏ការផ្តន្ទាទោសចុងចោទធ្វើឱ្យមានភាន់ច្រឡំដ៏ច្បាស់ក្រឡែត ដោយសារការផ្តន្ទាទោសនេះមិនបានឆ្លុះបញ្ចាំងច្បាស់

---

[194] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ៤៥៦។

[195] ឧបសម្ព័ន្ធ ក៖ ការផ្តន្ទាទោសជាប់ពន្ធនាគារនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន សម្រាប់ជនដែលត្រូវបានកាត់ឱ្យជាប់ ទោសរួចហើយដែលត្រូវទទួលខុសត្រូវចំពោះការស្លាប់ចំនួនច្រើនជាងមួយរយ (ជាង១០០) នាក់ ។

00613516

F10



លាស់ ពីស្ថានទម្ងន់បំផុតនៃអំពើឧក្រិដ្ឋទាំងឡាយ (រួមមាន មនុស្សឃាត និងការធ្វើទារុណកម្ម ដោយមានចេតនាជាការរើសអើង) និងតំណែងជាន់ខ្ពស់ និងតួនាទីរបស់ចុងបណ្តឹងឧទ្ធរណ៍ឡើយ។

១០១- ទោះបីតុលាការនេះជាតុលាការមានយុត្តាធិការថ្មីមួយក៏ដោយ តែមានយុត្តាធិការនៅតុលាការថ្នាក់ជាតិ និងអន្តរជាតិមួយចំនួនទៀតបានឆ្លើយតបទៅនឹងរឿងក្តីករណីជាច្រើន ដែលទាក់ទិននឹងអំពើឧក្រិដ្ឋធ្ងន់ធ្ងរ និងបានបង្កើតនូវគោលការណ៍នៃការផ្តន្ទាទោសដែលពាក់ព័ន្ធ។ ដោយសារតុលាការនេះផ្អែកលើចំណុចប្រសព្វនៃយុត្តាធិការរបស់តុលាការក្នុងស្រុកផង និងតុលាការអន្តរជាតិផងនោះ សហព្រះរាជអាជ្ញាបានជូនយោបល់ថា ការពិនិត្យឡើងវិញនូវការវិវត្ត និងការអនុវត្តគោលការណ៍នៃការផ្តន្ទាទោស នៅក្នុងយុត្តាធិការរបស់តុលាការកម្ពុជា និងតុលាការថ្នាក់ជាតិ និងអន្តរជាតិដទៃទៀត អាចផ្តល់ជាព័ត៌មានសម្រាប់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការសម្រេចសេចក្តីចំពោះបណ្តឹងឧទ្ធរណ៍នេះ។ នេះអាចជាករណីដែរ ដោយសារតែគោលបំណងនានានៃការផ្តន្ទាទោសទាំងនៅតុលាការអន្តរជាតិ និងតុលាការក្នុងស្រុក ត្រូវតែចែករំលែកគ្នាឱ្យបានទូលំទូលាយ[196]។

១០២- សហព្រះរាជអាជ្ញារំលឹកឡើងវិញពីភាពធ្ងន់ធ្ងរនៃការសម្លាប់មនុស្ស រួមជាមួយនឹងការធ្វើទារុណកម្ម ត្រូវបានចាត់ទុកថាស្ថិតក្នុងយុត្តាធិការរបស់តុលាការក្នុងស្រុក។ បើតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដែលអាចអនុវត្តបានក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះគឺថា អំពីឧក្រិដ្ឋនៃការធ្វើទារុណកម្ម និងការមនុស្សឃាត មានលក្ខណៈប្រហាក់ប្រហែលនឹងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិគឺថា គេ

---

[196] ដូចបានថ្លែងដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Stakić* សាលក្រមលេខ IT-97-24-T អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ ("សាលក្រមសាលាដំបូងលើរឿងក្តី *Stakić*") ថា៖ "នៅក្នុងក្របខណ្ឌនៃតុលាការនេះ មានការទទួលស្គាល់ជាសាកល និងឆ្លុះបញ្ចាំងក្នុងសាលក្រមនៃតុលាការនេះ និងតុលាការនៅប្រទេសរ្វាន់ដា ដែលថា ការធ្វើឱ្យរាងចាល និង ការសងសឹក ជាកត្តាទូទៅដែលត្រូវបានយកមកពិចារណា នៅពេលសម្រេចក្នុងការកំណត់ទោស" (កថាខណ្ឌ ៤០០)។

00613517



អាចអនុវត្តទោសប្រហារជីវិតបាន[197]។ ជាងនេះទៅទៀត ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ចែងពីការផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិត ចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរនានាដូចជា បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋសង្គ្រាម[198]។

១០៣- នៅក្នុងគំរូមួយនៃយុត្តាធិការរបស់តុលាការចំនួន ២១, ការសម្លាប់ (ដែលមានស្ថានទម្ងន់) តែមួយ (ដូចជា "*ឃាតកម្មគិតទុកជាមុន*", "មនុស្សឃាត", "មនុស្សឃាតដោយចេតនា" ឬ "មនុស្សឃាតកម្រិតទី១") អាចបណ្តាលឲ្យមានការផ្តន្ទាទោសកម្រិតអតិបរមាដែលអាចមាន។ នៅប្រទេសចំនួន ១៩ ក្នុងចំណោម ២១ ការផ្តន្ទាទោសអតិបរមាសម្រាប់បទល្មើសមនុស្សឃាត គឺការដាក់ពន្ធនាគារអស់មួយជីវិត (ឬទោសប្រហារជីវិត) ហើយនៅប្រទេសចំនួន ១១ ក្នុងចំណោមយុត្តាធិការរបស់តុលាការទាំងនេះ មនុស្សឃាតដែលមានស្ថានទម្ងន់ ត្រូវបានចាត់ទុកថាមានកម្រិតធ្ងន់ធ្ងរ ដែលអប្បរមានៃការផ្តន្ទាទោសគឺដាក់ពន្ធនាគារអស់មួយជីវិត[199]។ សហព្រះរាជអាជ្ញាបានធ្វើវិភាគពីយុត្តាធិការនៃតុលាការទាំងនេះ និងបានរៀបចំជាតារាងទិន្នន័យលទ្ធផលក្នុងឧបសម្ព័ន្ធ ខ។

១០៤- ប្រការនេះបង្ហាញថា បទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងការដកហូតជីវិតមនុស្សដោយចេតនា ត្រូវបានទទួលស្គាល់ជាសាកលថាមានស្ថានទម្ងន់ជាពិសេស។ ហេតុនេះលក្ខខណ្ឌតម្រូវឲ្យមានការការពារជាមុន និងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋទាំងនេះ គឺជាការចាំបាច់បំផុត គឺថាចាំបាច់រហូតទាល់តែធ្វើឲ្យយុត្តាធិការនៃតុលាការជាច្រើនបានសម្រេចផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរជាអតិបរមា ចំពោះបទ

---

[197] សាលក្រម កថាខណ្ឌ៥៧៥។

[198] ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ មាត្រា១៨៤, ១៨៩, ១៩៥ (ទាក់ទិននឹងអំពើប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម)។

[199] *សូមមើល* ឧបសម្ព័ន្ធ ខ៖ ការដាក់ទណ្ឌកម្មអប្បរមា និងអតិបរមាសម្រាប់ (មនុស្សឃាតមានស្ថានទម្ងន់) នៅក្នុងយុត្តាធិការរបស់តុលាការក្នុងស្រុកចំនួន ២១។

ល្មើសទាំងនេះ។ ជាងនេះទៅទៀត ប្រទេសដែលអនុម័តច្បាប់ពិសេសដើម្បីឆ្លើយតបទៅនឹងបទឧក្រិដ្ឋអន្តរជាតិ បានសម្រេចផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរចំពោះបទឧក្រិដ្ឋទាំងនេះ[200]។

១០៥- ការអនុវត្តនៅថ្នាក់ជាតិយ៉ាងទូលំទូលាយនេះឆ្លុះបញ្ចាំងពីអង្គហេតុដែលថា សម្រាប់បទឧក្រិដ្ឋធ្ងន់ធ្ងរដូចជាមនុស្សឃាតនេះ វាអាចជួយការពារជាមុន និងសំដែងពីការខឹងសម្បាររបស់សហគមន៍តាមរយៈការផ្តន្ទាទោសឲ្យបានធ្ងន់ធ្ងរបំផុត។ ខណៈដែលតុលាការក្នុងស្រុកប្រឈមមុខជាមួយនឹងបទឧក្រិដ្ឋអន្តរជាតិនានាក្នុងទម្រង់ជាបទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលទាក់ទិននឹងការបាត់បង់អាយុជីវិតមនុស្ស មិនមានអ្វីដែលបង្ហាញថា តុលាការត្រូវពិចារណាថា បទឧក្រិដ្ឋទាំងនេះមានកម្រិតស្រាលជាងប្រភេទបទឧក្រិដ្ឋផ្សេងទៀត ទាក់ទិននឹងការផ្តន្ទាទោសនោះទេ[201]។

---

[200] *អង់គ្លេស និង វេលស៍៖* ច្បាប់ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ២០០១ ជំពូក១៧ ផ្នែក៥ ចំណុច៥៣ ៦០ ដែលរួមជាមួយច្បាប់ស្តីពីមនុស្សឃាត (ការលុបចោលទោសប្រហារជីវិត) ឆ្នាំ១៩៦៥ ជំពូក៧១ មាត្រា១(១) តម្រូវឲ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិតសម្រាប់បទល្មើសមនុស្សឃាត។ *កាណាដា៖ ២០០១* ច្បាប់ស្តីពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម S.C. ឆ្នាំ២០០០ c. ២៤ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ ចំណុច៤ ចែងថាការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត គឺជាកាតព្វកិច្ច ប្រសិនបើការសម្លាប់មនុស្សដោយចេតនាបង្កើតជាមូលដ្ឋាននៃការវិនិច្ឆ័យឲ្យមានទោសពីបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម។ *បារាំង៖ ក្រមព្រហ្មទណ្ឌ* មាត្រា២១២-១ ចែងពីការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។ *អាល្លឺម៉ង់៖* ក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងអន្តរជាតិ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០២ ចំណុច ៧-៨ ចែងពីការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតជាកាតព្វកិច្ចចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមពាក់ព័ន្ធនឹងមនុស្សឃាត។ *នូវែលហ្សេឡង់៖* ច្បាប់ស្តីពីបទឧក្រិដ្ឋអន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ២០០០ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០០ ផ្នែក២ ចំណុច៩-១១ ចែងថាប្រសិនបើជាបទល្មើសប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម រួមទាំងការសម្លាប់មនុស្សដោយចេតនា នោះការផ្តន្ទាទោសត្រូវដូចគ្នានឹងអំពើមនុស្សឃាត ដែលមានកម្រិតទោសជាប់ពន្ធនាគារអស់មួយជីវិតដែរ។ *រ៉្វាន់ដា៖* ច្បាប់អង្គការលេខ 8/96 ស្តីពីការរៀបការវិនិច្ឆ័យទោសចំពោះបទល្មើសដែលមានទម្រង់ជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី៣០ សីហា ១៩៩៦ មាត្រា៦៨-៦៩ កំណត់មានចារីនៃអំពើប្រល័យពូជសាសន៍មាន ៤ ប្រភេទ។ ជនជាប់ចោទណាដែលត្រូវបានចាត់ថ្នាក់នៅក្នុងប្រភេទទី១ ឬទី២ នឹងត្រូវទទួលទោសប្រហារជីវិត ឬជាប់ពន្ធនាគារអស់មួយជីវិត។

[201] ដូចឧទាហរណ៍មួយនៃការវិនិច្ឆ័យទោសនៅតុលាការក្នុងស្រុក ចំពោះបទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ សូមមើល៖ *ចក្រភពអង់គ្លេស៖ រឿងក្តី Regina តទល់នឹង Sawoniuk* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ (ផ្នែកព្រហ្មទណ្ឌ) [ឆ្នាំ២០០០] របាយការណ៍ ២ ស្តីពីច្បាប់ព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០ កំណត់ទោសចំពោះជនជាប់ចោទដោយដាក់ពន្ធនាគារអស់មួយជីវិត តាមច្បាប់បទឧក្រិដ្ឋសង្គ្រាម (ឆ្នាំ១៩៩១)។

១០៦- ខណៈដែលតុលាការក្នុងស្រុកទទួលបានឆន្ទានុសិទ្ធិដើម្បីអនុវត្តការផ្តន្ទាទោស នៅក្នុងកម្រិតមួយនោះ តុលាការទាំងនេះរក្សាសិទ្ធិទុកការផ្តន្ទាទោសរបស់ខ្លួនក្នុងកម្រិតធ្ងន់ធ្ងរបំផុតសម្រាប់ "រឿងក្តីនានាដែលស្ថិតនៅក្នុងប្រភេទធ្ងន់ធ្ងរបំផុតនៃការផ្តន្ទាទោស"[202]។ ក៏ប៉ុន្តែ មិនមែនជាចាំបាច់ទេដែលគេត្រូវតែអនុញ្ញាតថា "ដោយសារវាអាចកើតមានពេលខាងមុខ និងពិតជាអាចរកបាននៅក្នុងសំណុំរឿងរបស់តុលាការ ជាករណីដែលអាក្រក់ជាងករណីរឿងក្តីបច្ចុប្បន្ន [ដែលថាករណីរឿងក្តីដោយឡែកមួយ] មិនសមរម្យសម្រាប់ផ្តន្ទាទោសក្នុងកម្រិតអតិបរមាឡើយ"[203]។ តុលាការ ICTY ក៏បានទទួលយកសញ្ញាណដែលថា ករណីរឿងក្តីប្រភេទអាក្រក់បំផុតមិនត្រូវបានកំណត់ត្រឹមតែករណីរឿងក្តីដែលធ្ងន់ធ្ងរបំផុតដែលគេអាចប្រមើលមើលបាននោះទេ៖ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងមួយរបស់តុលាការ ICTY បានសង្កត់ធ្ងន់ថា "តុលាការអន្តរជាតិក្តី និងតុលាការជាតិក្តី ការផ្តន្ទាទោសកម្រិតអតិបរមាត្រូវបានកំរិតត្រឹមតែ ការប្រព្រឹត្តិអំពើឧក្រិដ្ឋដែលអាចប្រមើលមើលបានថាមានលក្ខណៈធ្ងន់ធ្ងរបំផុតនោះទេ"[204]។

១០៧- ការប្រៀបធៀបនឹងករណីរឿងក្តីចុងបណ្តឹងសាទុក្ខនេះ ជាមួយនឹងករណីរឿងក្តីទាំងឡាយនៅតុលាការអន្តរជាតិ ក៏អាចនាំឱ្យមានការធ្វើសន្និដ្ឋានដូចគ្នាដែលមិនអាចចៀសវាងបាន។ ក្នុងរឿងក្តី *Galic* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTYបានសម្រេចថាជនជាប់ចោទដែលទទួលខុសត្រូវចំពោះយុទ្ធនាការភេរវកម្មមួយជាប្រព័ន្ធប្រឆាំងនឹងជនស៊ីវិលជាបុរស ស្ត្រី និងកុមារ ដោយការឡោមព័ទ្ធក្រុង Sarajevo សក្តិសមនឹងទទួលទោសកម្រិតធ្ងន់ធ្ងរបំផុតពីតុលាការនេះ គឺការផ្តន្ទាទោសដាក់

202 *រឿងក្តី Veen តទល់នឹង Regina (លេខ២)* (ឆ្នាំ១៩៨៨) សំណុំរឿងលេខ 64 CLR 465 F.C. 88/001 កថាខណ្ឌ១៥។

203 *រឿងក្តី Regina តទល់នឹង Twala* [ឆ្នាំ១៩៩៤] NSWCCA [ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៩៤]។

204 សាលក្រមសាលាដំបូងលើរឿងក្តី *Stakić* កថាខណ្ឌ៩៣២។

ពន្ធនាគារមួយជីវិត[205]។ ក្នុងរឿងក្តី *Jelisic* តុលាការ ICTY បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៤០ ឆ្នាំ ចំពោះបទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលទាក់ទិននឹងការសម្លាប់អ្នកទោសជនជាតិប៊ូស្នី-មូស្លីម នៅជំរំ Luka[206]។ ការផ្តន្ទាទោសក្នុងករណីរឿងក្តីនោះ គឺជាបណ្តុំពីកង្វះស្ថានសម្រាលទោសរួមជាមួយកត្តាស្ថានទម្ងន់នានា ដែលទាក់ទិននឹងវិធីសាស្ត្រគួរឱ្យពេញចិត្តក្នុងការប្រព្រឹត្តិការធ្វើទារុណកម្ម និងការសម្លាប់អ្នកទោសដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន[207]។ ខណៈដែល Jelisic សារភាពចំពោះពិរុទ្ធភាពរបស់ខ្លួន និងសំដែងពីវិប្បដិសារី តុលាការនេះរកឃើញថាអង្គហេតុទាំងនេះធ្វើឡើងដោយមិនមានភាពស្មោះត្រង់ ហើយអាស្រ័យហេតុនេះតុលាការនេះបានផ្តល់ទម្ងន់តិចតួចដល់អង្គហេតុនេះ[208]។ ក្នុងរឿងក្តី*Kambanda*ជនជាប់ចោទបានសារភាពចំពោះពិរុទ្ធភាពរបស់ខ្លួន និងបានចូលរួមសហការជាមួយរដ្ឋអាជ្ញា តែគាត់នៅតែទទួលការផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិតពីតុលាការ ICTR ដោយយោលទៅលើកត្តាស្ថានទម្ងន់នានា ដូចជាការគ្រប់គ្រងតំណែងជាន់ខ្ពស់នៅក្នុងក្រសួង និងការប្រព្រឹត្តិបទក្រិដ្ឋទាំងឡាយដោយមានចេតនាគិតទុកជាមុន និងដោយសារតែស្ថានទម្ងន់ខាងផ្លូវចិត្តនៃអំពើប្រល័យពូជសាសន៍ជាប្រព័ន្ធផង[209]។

១០៨- នៅក្នុងករណីរឿងក្តីទាំងអស់នេះ អ្វីដែលត្រូវគេយកមកពិចារណានោះគឺថា តើមានព្រឹត្តិការណ៍អ្វីអំពីបទឧក្រិដ្ឋទាំងនោះ អំពីការប្រព្រឹត្តរបស់ជនជាប់ចោទ អំពីកាលៈទេសៈនានារបស់ជនល្មើសជាក់លាក់ណាម្នាក់ ឬអំពីអង្គហេតុនៃករណីរឿងក្តីដោយឡែកណាមួយ ដែលបណ្តាលឱ្យវាត្រូវបាន

---

205 សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Galic*។

206 សាលក្រមសាលាដំបូងលើរឿងក្តី *Jelisic* កថាខណ្ឌ១៣៨-៣៩។

207 សាលក្រមសាលាដំបូងលើរឿងក្តី *Jelisic* កថាខណ្ឌ១២៤-៣៥។

208 សាលក្រមសាលាដំបូងលើរឿងក្តី *Jelisic* កថាខណ្ឌ១២៧។

209 សាលក្រមសាលាដំបូងផ្តន្ទាទោសលើរឿងក្តី *Kambanda* កថាខណ្ឌ៦១។

ចាត់ថ្នាក់នៅក្នុងប្រភេទអាក្រក់បំផុតនៃបទល្មើស និង/ឬ ប្រភេទអាក្រក់បំផុតនៃជនល្មើស។ ការផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិតមានលក្ខណៈសក្តិសមចំពោះរឿងក្តីករណីទាំងនោះ“នៅពេលដែលកម្រិតនៃពិរុទ្ធភាពមានលក្ខណៈធ្ងន់ធ្ងរពេករហូតទាល់ការផ្តន្ទាទោសកម្រិតអតិបរមា ទើបស្របទៅនឹងផលប្រយោជន៍របស់សហគមន៍ក្នុងការសងសឹក (retribution) និងការផ្តន្ទាទោស”[210]។

*ឃ.៤.២.៤ អង្គជំនុំជម្រះសាលាឧទ្ធរណ៍អន្តរជាតិបានបង្កើនការកាត់ទោសលើបណ្តឹងឧទ្ធរណ៍*

១០៩- អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY និងតុលាការ ICTR ធ្លាប់បានកែសម្រួលការផ្តន្ទាទោសទៅតាមការប៉ាន់ប្រមាណមិនត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះស្ថានទម្ងន់នៃបទល្មើស ឬស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោស។ អង្គជំនុំជម្រះតុលាការកំពូលរបស់ អ.វ.ត.ក គួរអនុវត្តតាមលំអាននេះ។

១១០- ភាគច្រើននៃការពិនិត្យកែប្រែទៅលើការផ្តន្ទាទោសនៅតុលាការ ICTY និង តុលាការ ICTR ត្រូវបានធ្វើឡើងដោយសារ “សំអាងមួយក្នុងចំណោមសំអាងហេតុទាំងបីគឺៈ ដោយសារការប្រែប្រួលនៃការផ្តន្ទាទោស ការសម្រេចអោយរួចទោស ឬវិធីសាស្ត្រនៃការចូលរួមដែលអាចអនុវត្តបាន *ដោយសារការភាន់ច្រឡំអង្គហេតុទាក់ទិននឹងស្ថានទម្ងន់ ឬស្ថានសម្រាល ឬដោយសារតែអង្គជំនុំជម្រះសាលាដំបូងផ្តល់ទម្ងន់មិនសមរម្យចំពោះកត្តាជាស្ថានទម្ងន់ ឬស្ថានសម្រាលទោស ឬចំពោះស្ថានទម្ងន់នៃបទល្មើស*”[211]។ គិតមកដល់ឆ្នាំ២០០៨ ក្នុងចំណោមរឿងក្តី ៥ករណី នៅកម្រិត

---

[210] *រឿងក្តី Regina តទល់នឹង Garforth* [ឆ្នាំ១៩៩៤] NSWCCA 13 [ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៤]។

[211] Jennifer J. Clark, *Zero to Life: Sentencing Appeals at the International Criminal Tribunals for the Former Yugoslavia and Rwanda*, 96 GEO. L.J. 1685, ខែមិថុនា ឆ្នាំ២០០៨ (“Clark”) ត្រង់ទំព័រ ១៧០៣-១៧០៤

ឧទ្ធរណ៍ទាក់ទិននឹងការផ្តន្ទាទោស (៤ករណីនៅតុលាការ ICTY និង ១ ករណីនៅតុលាការ ICTR) អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំក្នុងការប៉ាន់ប្រមាណពីស្ថានទម្ងន់ និង/ឬ ទម្ងន់នៃកត្តានានាដែលជាស្ថានទម្ងន់ ឬស្ថានសម្រាលទោស[212]។ ក្នុងករណីរឿងក្តីទាំង ៥ ករណីនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបង្កើនការផ្តន្ទាទោស ដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តី ៤ ករណី (៣ ករណីនៅតុលាការ ICTY និង ១ ករណីនៅតុលាការ ICTR)[213] ដែលក្នុងករណីរឿងក្តីនីមួយៗ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសង្កត់ធ្ងន់ពីតួនាទីដែលមានសិទ្ធិអំណាចសំខាន់ ជាកត្តាស្ថានទម្ងន់ទោស[214]។

១១១- តទៅនេះជាការប៉ាន់ប្រមាណដោយសង្ខេបក្នុងរឿងក្តីទាំង ៤ ករណី៖

ក) *រឿងក្តី Zlatko Aleksovski*៖ ក្នុងឋានៈជាមេបញ្ជាការពន្ធនាគារ Kaonik, Aleksovski ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋសង្គ្រាមដោយកំហឹងចំពោះកិត្តិយសផ្ទាល់ខ្លួនជាសំខាន់គឺគាត់

---

(គូសបញ្ជាក់បន្ថែម)។ នៅតុលាការ ICTY និងតុលាការ ICTR មានបណ្តឹងឧទ្ធរណ៍ទៅលើការកំណត់ទោស។ ក្នុងចំណោមសាលក្រមសម្រេចទោសចំនួន ៩៥ ករណីដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេច មកដល់ចុងឆ្នាំ២០០៧ មានចំនួន ៦២ ករណីបានក្លាយជាសាលដីកាស្ថាពរ ក្រោយពេលមានបណ្តឹងឧទ្ធរណ៍ និង ៤ ករណីពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជុំទីពីរ បន្ទាប់បានទាមទារទៅអង្គជំនុំជម្រះសាលាដំបូង។ បណ្តឹងឧទ្ធរណ៍ទាំងអស់នេះរួមមានបណ្តឹងតវ៉ាចំពោះការកំណត់ទោសរបស់អង្គជំនុំជម្រះសាលាដំបូង។ បណ្តឹងឧទ្ធរណ៍ចំនួន ២៥ ករណីត្រូវបានកែប្រែការកំណត់ទោស (ការកំណត់ទោសចំនួន ៧ ករណីត្រូវបានបន្ថែមចំនួនទោស និង ១៨ ករណីទៀតត្រូវបានកាត់បន្ថយទោស)។ សូមមើល Clark ត្រង់ទំព័រ ១៧០៣-១៧០៤។

[212] សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Aleksovski* *រឿងក្តី Gacumbitsi តទល់នឹង រដ្ឋអាជ្ញា* សាលដីកាលេខ ICTR-2001-64-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦ ("សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Gacumbitsi*") កថាខណ្ឌ២០៦-២០៧ សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Galić* *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលដីកាលេខ IT-97-25-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Čelebići*។

[213] សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Aleksovski* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Gacumbitsi* កថាខណ្ឌ២០៧ សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Galić* កថាខណ្ឌ៤៥៥ សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Čelebići*។

[214] Clark, ត្រង់ទំព័រ១៧១២។

ខកខានមិនបានទប់ស្កាត់ការធ្វើបាបអ្នកទោស។ នៅអង្គជំនុំជម្រះសាលាដំបូង Aleksovski បានទទួលទោសជាប់ពន្ធនាគារចំនួន ២,៥ឆ្នាំ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា "មានការភាន់ច្រឡំក្នុងការវិនិច្ឆ័យទោស នៅពេលអង្គជំនុំជម្រះសាលាដំបូងអនុវត្តឆន្ទានុសិទ្ធិក្នុងការផ្តន្ទាទោស"។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរកឃើញថា ការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២,៥ ឆ្នាំគឺ "មិនទាន់គ្រប់គ្រាន់"[215] ហើយសម្រេចថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ "ទម្ងន់មិនទាន់គ្រប់គ្រាន់ចំពោះស្ថានទម្ងន់ទោសចំពោះការប្រព្រឹត្តិរបស់ [Aleksovski]"[216]។ ទោះបីអង្គជំនុំជម្រះសាលាដំបូងបានរកឃើញយ៉ាងត្រឹមត្រូវថា Aleksovski បានកាន់កាប់តំណែងមេបញ្ជាការ និងថាការចូលរួមដោយផ្ទាល់របស់គាត់ក្នុងការធ្វើបាបអ្នកទោសត្រូវបានកំហិតក៏ដោយ តែអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានទទួលស្គាល់ថាគាត់ជាមេបញ្ជាការគុក "ការចូលរួមដោយផ្ទាល់របស់គាត់ [...] បានផ្តល់ជាការលើកទឹកចិត្តបន្ថែមទៀតដល់អ្នកក្រោមបង្គាប់ ក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋស្រដៀងគ្នានេះ"[217]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានកែប្រែការផ្តន្ទាទោសនោះ ដោយសម្រេចដាក់ពន្ធនាគាររហូតដល់ ៧ ឆ្នាំ[218]។

ខ) *រឿងក្តី Zdravko Mucic៖* ក្នុងឋានៈជាមេបញ្ជាការពន្ធនាគារ Čelebici, Mucic ត្រូវបានផ្តន្ទាទោសពីបទទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ក្នុងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវរួមមានការប្រព្រឹត្តិបែបអមនុស្សធម៌ ការបណ្តាលឱ្យមានការឈឺ

---

[215] សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Aleksovski* កថាខណ្ឌ១៨៧។

[216] សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Aleksovski* កថាខណ្ឌ១៨៣។

[217] សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Aleksovski* កថាខណ្ឌ១៨៣។

[218] សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Aleksovski* កថាខណ្ឌ១៩១។

ចាប់យ៉ាងធ្ងន់ធ្ងរដោយចេតនា ការធ្វើទារុណកម្ម និង មនុស្សឃាតដោយចេតនា។ Mucic ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៧ឆ្នាំ[219]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានកែប្រែករណីនេះ ដោយសម្រេចថាក្នុងការផ្តន្ទាទោសអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានយកចិត្តទុកដាក់ឱ្យបានពេញលេញនូវ (ក) ឥទ្ធិពលក្នុងឋានៈជាមេបញ្ជាការពន្ធនាគារ ដែលជំរុញ និងលើកតម្កើងបទឧក្រិដ្ឋ និងបរិយាកាសមិនគោរពច្បាប់នៅក្នុងពន្ធនាគារដោយសារគាត់ខកខានជាបន្តបន្ទាប់ នូវការអនុវត្តតួនាទីថ្នាក់លើរបស់ខ្លួន និង (ខ) ស្ថានទម្ងន់នៃបទល្មើសទាំងឡាយរបស់គាត់ និងជាពិសេសគឺស្ថានទម្ងន់ចំពោះបទឧក្រិដ្ឋទាំងនេះ និង (គ) អង្គហេតុដែលថាទាំងការទទួលខុសត្រូវដោយផ្ទាល់ និងទាំងក្នុងនាមជាថ្នាក់លើ គឺពាក់ព័ន្ធនឹងការបណ្តាលឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ ឬព្យសនកម្មយ៉ាងធ្ងន់ធ្ងរដោយចេតនាដល់រាងកាយ ឬសុខភាព ដោយសារស្ថានភាពបែបអមនុស្សធម៌នៅក្នុងពន្ធនាគារនោះ។ អង្គជំនុំជម្រះអង្គសាលាដំបូងថ្មីនេះបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៩ ឆ្នាំ ហើយចុងក្រោយត្រូវបានតម្កល់ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍[220]។

គ) *រឿងក្តី Stanislav Galic*៖ ក្នុងឋានៈជាមេបញ្ជាការកង Sarajevo Romanija Corps, Galic ត្រូវបានផ្តន្ទាទោសនៅអង្គជំនុំជម្រះសាលាដំបូងដាក់ពន្ធនាគាររយៈពេល ២០ ឆ្នាំ ពីបទមានតួនាទីក្នុងការឡោមព័ទ្ធក្រុង Sarajevo។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានដឹងថាអង្គជំនុំជម្រះសាលាដំបូងមិនភាន់ច្រឡំក្នុងការសម្រេចទៅលើអង្គហេតុដែលពាក់ព័ន្ធទេ។

---

219 សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Čelebići* កថាខណ្ឌ៧២៧-៧២៨។

220 *សូមមើល* តារាងព័ត៌មាននៃរឿងក្តី, តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី "ជំរំ *Čelebići* (ឯកសារលេខ IT-96-21) *រឿងក្តី Mucic និង អ្នកដទៃទៀត*"។

ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា ការផ្តន្ទាទោសដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងមិនបានឆ្លុះបញ្ចាំងពេញលេញ ចំពោះកម្រិតនៃស្ថានទម្ងន់របស់បទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តឡើងដោយGalic និងកម្រិតនៃការចូលរួមរបស់គាត់ទេ[221]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានកែប្រែការផ្តន្ទាទោសនោះសម្រេចដាក់ពន្ធនាគារមួយជីវិតជាស្ថាពរមុនគេចំពោះចុងចោទនៅតុលាការ ICTY នេះ[222]។

ឃ) *រឿងក្តីSylvestre Gacumbitsi៖* ក្នុងឋានៈជាមេឃុំRusumo នៅប្រទេសរ៉្វាន់ដា Gacumbitsi ត្រូវបានសម្រេចឱ្យរួចទោសពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ គឺមនុស្សឃាត តែត្រូវបានផ្តន្ទាទោសនៅអង្គជំនុំជម្រះសាលាដំបូងឱ្យជាប់ពន្ធនាគាររយៈពេល ៣០ ឆ្នាំ ពីបទប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដោយការសម្លាប់ផ្តាច់ពូជសាសន៍ និងរំលោភសេពសន្ថវៈ[223]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានច្រានចោលការសម្រេចឱ្យរួចទោសពីបទឃាតកម្ម និងបានសម្រេចបន្ថែមថា Gacumbitsi បានបញ្ជាក្រុមចោរីបន្ថែមទៀតឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ សម្លាប់ផ្តាច់ពូជសាសន៍ និងរំលោភសេពសន្ថវៈ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចផ្តន្ទាទោស Gacumbitsi ដាក់ពន្ធនាគារអស់មួយ

---

[221] សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Galić* កថាខណ្ឌ៤៥៥។

[222] *សូមមើល* សេចក្តីប្រកាសព័ត៌មាន, តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, Stanislav Galić ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងអំឡុងពេលឡោមព័ទ្ធក្រុង Sarajevo សំណុំរឿងលេខ RH/MOW/ 1131e ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ អាចរកបាននៅគេហទំព័រ៖http://www.icty.org/x/cases/galic /press/en/PR1131e%20Stanislav%20galic%20Appeal%20Judgement.pdf.។

[223] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* សាលក្រមលេខ ICTR-2001-64-T សាលក្រមសាលាដំបូងនៃតុលាការ ICTR ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៤ កថាខណ្ឌ៣៣៤, ៣៥៦។

ជីវិត[224]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏បានទទួលយកបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាចំពោះការផ្តន្ទាទោសដាក់ពន្ធនាគារ ដោយសម្រេចថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបាន "ផ្តល់ទម្ងន់ឲ្យបានសមរម្យដល់ស្ថានទម្ងន់នៃបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តដោយម្ចាស់បណ្តឹងឧទ្ធរណ៍ និងតួនាទីសំខាន់របស់គាត់នៅក្នុងបទឧក្រិដ្ឋទាំងនោះ"[225]។ ដោយផ្តោតតែទៅលើការផ្តន្ទាទោសតែមួយ និងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើអង្គហេតុនានាពាក់ព័ន្ធនឹងបទចោទទាំងនោះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា៖ "ក្នុងលក្ខណៈទូលំទូលាយធំនៃបទឧក្រិដ្ឋទាំងនេះ និងតួនាទីដឹកនាំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅក្នុងអំពើឧក្រិដ្ឋទាំងនេះ រួមទាំងភាពមិនសំខាន់នៃកត្តាស្ថានសម្រាលនានា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តហួសពីវិសាលភាពឆន្ទានុសិទ្ធិ ដោយសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារត្រឹមតែរយៈពេល ៣០ឆ្នាំ"[226]។ អាស្រ័យហេតុនេះ ដោយរួមទាំងការសម្រេចចុងក្រោយរួមមានការផ្តន្ទាទោសថ្មីមួយផងនោះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍សម្រេចកែប្រែដោយបន្ថែមទណ្ឌកម្ម ទោះបីមិនមានការផ្តន្ទាទោសបន្ថែមក៏ដោយ។

១១២- សហព្រះរាជអាជ្ញាសូមស្នើថា អង្គជំនុំជម្រះតុលាការកំពូលករណីក្នុងរឿងក្តីបច្ចុប្បន្ននេះធានាឲ្យមានការធ្វើអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូល ដើម្បីកែប្រែការផ្តន្ទាទោសដោយអយុត្តិធម៌ដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង។

### ឃ.៤.៣ ការខកខានមិនបានពិចារណាអំពីគោលបំណងនៃការកាត់ទោស

[224] សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Gacumbitsi* កថាខណ្ឌ២០៧។

[225] សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Gacumbitsi* កថាខណ្ឌ២០៦។

[226] សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Gacumbitsi* កថាខណ្ឌ២០៥។

### *ឃ.៤.៣.១ ទូទៅ*

១១៣- អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាថាតើ គោលការណ៍នៃការផ្តន្ទាទោសព្រហ្មទណ្ឌនៅតុលាការអន្តរជាតិ បានផ្តល់ការគាំទ្រក្នុងការសម្រេចផ្តន្ទាទោសអតិបរមាដល់ចុងបណ្តឹងសាទុក្ខឬយ៉ាងណា។ ជាប្រពៃណី តុលាការអន្តរជាតិទាំងឡាយបានផ្អែកលើសញ្ញាណនៃការសងសឹក និងសញ្ញាណនៃការធ្វើឱ្យរាងចាលរបស់សង្គម ជាលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តន្ទាទោសក្នុងរឿងក្តីព្រហ្មទណ្ឌ។ សញ្ញាណនៃការសងសឹកគាំទ្រនូវការផ្តន្ទាទោសធ្ងន់ធ្ងរចំពោះចុងបណ្តឹងសាទុក្ខ ដោយផ្អែកលើមូលដ្ឋានទាំងឡាយថា បទឧក្រិដ្ឋរបស់គាត់មានលក្ខណៈសាហាវព្រៃផ្សៃ ហេតុនេះហើយគួរតែផ្តន្ទាទោសគាត់ឱ្យបានធ្ងន់ធ្ងរតាមដែលអាចធ្វើបាន។ ដោយសារលក្ខណៈសាហាវព្រៃផ្សៃនៃបទឧក្រិដ្ឋទាំងឡាយរបស់ចុងបណ្តឹងសាទុក្ខ សញ្ញាណនៃការធ្វើឱ្យរាងចោលរបស់សង្គមជាការផ្តន្ទាទោសធ្ងន់ធ្ងរ ពីព្រោះសញ្ញាណនេះជំរុញអង្គជំនុំជម្រះសាលាដំបូងឱ្យអនុវត្តការផ្តន្ទាទោសដែលនឹងដើរតួនាទីជាអ្នកមានឥទ្ធិពលក្នុងការធ្វើឱ្យរាងចាល ប្រឆាំងនឹងបទឧក្រិដ្ឋទាំងឡាយស្រដៀងគ្នានេះនាពេលអនាគត។

### *ឃ.៤.៣.២ គោលបំណងនៃការកាត់ទោស*

១១៤- ទ្រឹស្តីមួយក្នុងចំណោមទ្រឹស្តីខាងក្រោមស្តីពីការផ្តន្ទាទោស ត្រូវបានគេដកស្រង់ជាទូទៅមកធ្វើយុត្តិកម្មដើម្បីគាំទ្រដល់ការកាត់ទោសក្នុងរឿងក្តីព្រហ្មទណ្ឌរួមមាន៖ ការធ្វើឱ្យរាងចាល ការសងសឹកការស្តារនីតិសម្បទា និងការការពារពីសង្គម[227]។

---

[227] Andrew Dubinsky, *An Examination of International Sentencing Guidelines and a Proposal for Amendments to the International Criminal Court"s Sentencing Structure,* 33 N.E. J. ON CRIM & CIV. CON. 609, រដូវក្តៅ ឆ្នាំ២០០៧ ("Dubinsky") ត្រង់ទំព័រ ៦១៨។

១១៥- បើតាមទ្រឹស្តីនៃការផ្តន្ទាទោសធ្វើឱ្យរាងចាល គោលបំណងសំខាន់នៃការផ្តន្ទាទោសគឺដើម្បីបញ្ជូនសារមួយដ៏ខ្លាំងដើម្បីបំភ័យមនុស្សមិនឱ្យប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ដែលជននោះបានប្រព្រឹត្តរួចហើយ[228]។ ជាការពិត ទ្រឹស្តីនេះសន្មតថា គំនិតនៃការផ្តន្ទាទោសនឹងជួយបញ្ចុះបញ្ចូលឧក្រិដ្ឋជនមិនឱ្យប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ដើម្បីចៀសវាងការផ្តន្ទាទោស[229]។ ទ្រឹស្តីនេះ ផ្តោតទៅលើការផ្តន្ទាទោសដើម្បីជាគុណប្រយោជន៍ និងសុវត្ថិភាពដល់សង្គមទាំងមូល និងយ៉ាងហោចណាស់ក៏មានប្រសិទ្ធភាពទៅលើបុគ្គលដែលត្រូវបានគេដាក់ទោសផងដែរ។

១១៦- ទ្រឹស្តីនៃការសងសឹកអំពាវនាវឱ្យមានឧត្តមគតិនៃការទទួលខុសត្រូវ និងភាពយុត្តិធម៌ ដើម្បីធ្វើយុត្តិកម្មគាំទ្រដល់ការផ្តន្ទាទោស[230]។ ទ្រឹស្តីនេះបង្ហាញពីសញ្ញាណដែលថា បទឧក្រិដ្ឋមួយគួរត្រូវបានផ្តន្ទាទោសដោយមានការដាក់ទោសសមាមាត្រទៅនឹងកំហុសនៃអំពើឧក្រិដ្ឋនោះ[231]។ តុលាការមួយដែលចង់អនុវត្តតាមទ្រឹស្តីនេះ គួរពិចារណាទៅដល់កំហុសនៃបទឧក្រិដ្ឋមួយ និងសម្រេចផ្តន្ទាទោសមួយដែលឆ្លុះបញ្ចាំងពីស្ថានទម្ងន់នៃបទល្មើស។ ជាចុងក្រោយ ព្យសនកម្មដែលបណ្តាលដោយអំពើឧក្រិដ្ឋនឹងត្រូវបានពិចារណាដោយផ្ទាល់ នៅពេលធ្វើការសម្រេចពីការផ្តន្ទាទោស[232]។

១១៧- ទ្រឹស្តីនៃការស្តារនីតិសម្បទាផ្តោតទៅលើតម្រូវការរបស់បុគ្គលដែលបានប្រព្រឹត្តបទឧក្រិដ្ឋមួយ និងស្វែងរកការស្តារនីតិសម្បទាចំពោះឧក្រិដ្ឋជននោះ ដើម្បីឱ្យគេអាចរួមរស់ក្នុងសង្គមវិញ។ នៅពេលសម្រេចកាត់ទោសដោយមានចេតនាស្តារនីតិសម្បទាឡើងវិញ តុលាការមួយត្រូវពិចារណាទៅលើ

[228] Dubinsky, ត្រង់ទំព័រ ៦១៨។

[229] Dubinsky, ត្រង់ទំព័រ ៦១៨។

[230] Dubinsky, ត្រង់ទំព័រ ៦១៨។

[231] Dubinsky, ត្រង់ទំព័រ ៦១៨។

[232] Dubinsky, ត្រង់ទំព័រ ៦១៨។

ស្ថានភាពផ្ទាល់ខ្លួនរបស់បុគ្គលនោះ ហើយថាតើការផ្តន្ទាទោសបែបណាជាការចាំបាច់ ដើម្បីទប់ស្កាត់មិនឱ្យបុគ្គលនោះប្រព្រឹត្តបទឧក្រិដ្ឋបន្ថែមទៀតនាពេលអនាគត[233]។

១១៨- ទ្រឹស្តីនៃការការពារសង្គមសន្មតជាមុនថា បទឧក្រិដ្ឋអាចនឹងកើតមានឡើងដរាបណាសង្គមបានទប់ស្កាត់យ៉ាងសកម្មមិនឱ្យកើតមាន។ នៅពេលជនជាប់ទោសម្នាក់ត្រូវបានកាត់ទោស តុលាការត្រូវពិចារណាពីរបៀបកាត់ទោសដែលឆ្លុះបញ្ចាំងពីតម្រូវការ ដើម្បីការពារសង្គមពីឧក្រិដ្ឋជននោះ[234]។

១១៩- នៅក្នុងសេចក្តីសម្រេចទាំងឡាយរបស់ខ្លួន ជាញឹកញាប់បំផុត តុលាការអន្តរជាតិនានាតែងតែដកស្រង់យកទ្រឹស្តីនៃការធ្វើឱ្យរាងចាល និងទ្រឹស្តីនៃការសងសឹកមកធ្វើជាសំអាងហេតុសម្រាប់កាត់ទោស ដែលជួនកាលទ្រឹស្តីនៃការស្តារនីតិសម្បទាឡើងវិញត្រូវបានបន្ថែមលំដាប់ទីបីសម្រាប់ធ្វើការពិចារណា តែទ្រឹស្តីនេះមានទម្ងន់តិចជាងទ្រឹស្តីពីរខាងដើមទេ[235]។ ទ្រឹស្តីនៃការធ្វើឱ្យរាងចាល គឺគោលការណ៍មួយដែលក្រុមប្រឹក្សាសន្តិសុខពេញចិត្តជាងគេ ដើម្បីយកមកធ្វើយុត្តិកម្មគាំទ្រដល់ការបង្កើតតុលាការ ICTY និងតុលាការ ICTR[236]។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY និង តុលាការ ICTR តែងតែដកស្រង់យកទ្រឹស្តីនៃការធ្វើឱ្យរាងចាល មកធ្វើជាកត្តាមួយសំខាន់ នៅពេលសម្រេចសេចក្តីលើការកាត់ទោស[237]។ ជាការពិត អង្គជំនុំជម្រះសាលាដំបូងតុលាការ ICTY បានបង្ហាញការសង្កេតនៅក្នុងរឿងក្តី *Todorovic*

---

[233] Dubinsky, ត្រង់ទំព័រ ៦១៩។

[234] Dubinsky, ត្រង់ទំព័រ ៦១៨-៦១៩។

[235] Alison Marston Danner, *Constructing a Hierarchy of Crimes in International Criminal Law Sentencing*, 87 VA. L. REV. 415, ខែឧសភា ឆ្នាំ២០០១ ("Danner"), ត្រង់ទំព័រ ៤៤៤-៤៤៥ *សូមមើលផងដែរ រឿងក្តី Momir Nikolić*, សាលក្រមសាលាដំបូងផ្តន្ទាទោស កថាខណ្ឌ៨៥ ("អង្គជំនុំជម្រះសាលាដំបូងរកឃើញថាគោលបំណងនៃការកំណត់ទោសដែលទទួលស្គាល់ដោយយុត្តិសាស្ត្រនៃតុលាការនេះ គឺការសងសឹក ការធ្វើឱ្យរាងចាល និងការស្តារនីតិសម្បទាឡើងវិញ")។

[236] Danner, ត្រង់ទំព័រ ៤៤៦។

[237] Danner, ត្រង់ទំព័រ ៤៤៧។

ថាការកាត់ទោសត្រូវតែមាន "តម្លៃនៃការធ្វើឲ្យរាងចាលគ្រប់គ្រាន់ ដើម្បីធានាបានថាអ្នកដែលមានបំណងចង់ប្រព្រឹត្តបទឧក្រិដ្ឋស្រដៀងគ្នានេះ នឹងខ្លាចរអាលែងហ៊ានប្រព្រឹត្តទៀត"[238]។

១២០- ស្របជាមួយនឹងទ្រឹស្តីនៃការធ្វើឲ្យរាងចាលនេះ ទ្រឹស្តីនៃការសងសឹកគឺជាទ្រឹស្តីមួយទៀតដែលតុលាការអន្តរជាតិតែងតែដកស្រង់ញឹកញយជាងគេដែរ ដើម្បីធ្វើជាគោលការណ៍សម្រាប់ពិចារណាទៅលើការផ្តន្ទាទោស។ ដូចគ្នាដែរតុលាការ ICTY បានកត់សម្គាល់ក្នុងរឿងក្តី *Erdemovic* ថាមុខងារសំខាន់មួយនៃការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ គឺដើម្បីឆ្លុះបញ្ចាំងពីកំហឹងរបស់សហគមន៍អន្តរជាតិទៅលើបទឧក្រិដ្ឋសាហាវព្រៃផ្សៃទាំងឡាយ និងការប្តឹងបរិហារចំពោះចារី[239]។ នៅតុលាការ ICTR អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា "គោលបំណងនៃការបង្កើតតុលាការនេះគឺដើម្បីវិនិច្ឆ័យទោស និងផ្តន្ទាទោសដល់ចារីនៃអំពើសាហាវយង់ឃ្នងនៅប្រទេសរ្វាន់ដា ទៅតាមវិធីមួយដើម្បីបញ្ចប់អំពើនិទណ្ឌភាព និងដើម្បីលើកតម្កើងការផ្សះផ្សាជាតិ និងការស្តាបនាសន្តិភាពឡើងវិញ"[240]។

### *ឃ.៤.៣.៣ សេចក្តីសន្និដ្ឋាន*

១២១- ការផ្តន្ទាទោសដែលសម្រេចដោយ អង្គជំនុំជម្រះសាលាដំបូង មិនបានឆ្លុះបញ្ចាំងពីគោលដៅជាសារវ័ន្តនៃការផ្តន្ទាទោសក្នុងរឿងព្រហ្មទណ្ឌនៅតុលាការអន្តរជាតិទេ ដោយឡែកគឺគោលដៅនៃការធ្វើឲ្យរាងចាល និងការសងសឹក។ ចុងបណ្តឹងសាទុក្ខត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋធ្ងន់ធ្ងរជាងគេមួយចំនួនដែលអាចប្រមើលមើលថា បានប្រព្រឹត្តក្នុងរយៈពេលយូរអង្វែង រួមមានមនុស្សឃាត និងការធ្វើទារុណកម្មដែលបានប្រព្រឹត្តដោយមានចេតនារើសអើង។ ការផ្តន្ទាទោសណាដែលទាបជាង

---

238 *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Todorovic* សាលក្រមផ្តន្ទាទោសលេខ IT-95-9/1-S សាលក្រមសាលាដំបូងនៃតុលាការ ICTY ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ៣០។

239 *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Erdemovic* សាលក្រមផ្តន្ទាទោសលេខ IT-96-22-T សាលក្រមសាលាដំបូងនៃតុលាការ ICTY ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩៦ កថាខណ្ឌ៦៥។

240 សាលក្រមសាលាដំបូងផ្តន្ទាទោសលើរឿងក្តី *Kambanda* កថាខណ្ឌ២៦។

ការជាប់ពន្ធនាគារអស់មួយជីវិត នឹងមិនបានឆ្លុះបញ្ចាំងគ្រប់គ្រាន់ដល់កំហឹងរបស់សហគមន៍ជាតិ និងអន្តរជាតិ ក្នុងទិដ្ឋភាពនៃអំពើឧក្រិដ្ឋទាំងឡាយរបស់គាត់ និងមិនបានបំភ័យមិនឱ្យប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយដែលមានលក្ខណៈស្រដៀងគ្នានេះនាពេលអនាគត នៅកម្ពុជាបានឡើយ។

### ឃ.៤.៤ ចុងចោទគ្មានសិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌទេ

១២២- តុលាការនេះមិនបានអនុញ្ញាតឱ្យមានការដោះលែងដោយមានលក្ខខណ្ឌដល់ជនជាប់ចោទទេ។ ហេតុនេះ ក្រោយពេលអង្គជំនុំជម្រះតុលាការកំពូលចេញសាលដីកាសម្រេចស្ថាពរហើយនោះ ចុងចោទសាទុក្ខមិនអាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ខណៈដែលគាត់អនុវត្តទោសនៅក្នុងពន្ធនាគារប្រទេសកម្ពុជាបានឡើយ។

១២៣- នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា អ.វ.ត.ក មិនមែនជា "របបនៃការកំណត់ទោសពិសេសដាច់ដោយឡែកមួយ" ទេ[241]។ ប្រការនេះបង្ហាញពីការអនុវត្តឆន្ទានុសិទ្ធិពេញលេញរបស់ អ.វ.ត.ក ទៅលើទិដ្ឋភាពទាំងអស់នៃការកំណត់ទោស រួមមានការដោះលែងដោយមានលក្ខខណ្ឌផងដែរ។ ការពឹងផ្អែកលើរបបនៃការកំណត់ទោសដោយឯករាជ្យនេះ អង្គជំនុំជម្រះសាលាដំបូង បានកំណត់ទោសចំពោះចុងចោទសាទុក្ខឱ្យជាប់ពន្ធនាគារខ្ពស់ជាង ៣០ឆ្នាំ លើសពីអ្វីដែលបានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ដោយបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងមាន"ឆន្ទានុសិទ្ធិក្នុងការកំណត់រយៈពេលជាក់លាក់មួយសម្រាប់ផ្តន្ទាទោសដាក់ពន្ធនាគារ ក្នុងករណីដែលទោសដាក់ពន្ធនាគារអស់មួយជីវិតមិនអាចយកមកអនុវត្តបាន"[242]។ ដោយបានសម្រេចលើសចំនួនឆ្នាំ ចំពោះការកំណត់ទោសដាក់ពន្ធនាគាររយៈពេលជាក់លាក់ ដែលមានចែងក្នុងច្បាប់កម្ពុជានោះ

[241] សាលក្រម កថាខណ្ឌ៥៧៥។

[242] សាលក្រម កថាខណ្ឌ៥៩៥។

អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា របបនៃការកំណត់ទោសពិសេសដាច់ដោយឡែកមួយរបស់តុលាការនេះ ហើយអង្គជំនុំជម្រះសាលាដំបូងក៏បានសង្កត់ធ្ងន់ពីលទ្ធភាពរបស់ខ្លួន ក្នុងការសម្រេចលើការកំណត់ទោស ដោយមិនបានគោរពតាមការអនុវត្តក្នុងស្រុករបស់ប្រទេសកម្ពុជាឡើយ។

១២៤- ខណៈដែលការដោះលែងដោយមានលក្ខខណ្ឌទទួលបានការអនុញ្ញាតនៅតុលាការអន្តរជាតិដទៃទៀត មិនមានឯកសារណាមួយនៅ អ.វ.ត.ក យោងទៅដល់ការដោះលែងដោយមានលក្ខខណ្ឌចំពោះជនជាប់ចោទឡើយ។ តុលាការព្រហ្មទណ្ឌអន្តរជាតិដែលអនុញ្ញាតឱ្យមានការដោះលែងដោយមានលក្ខខណ្ឌចំពោះជនជាប់ចោទរបស់ខ្លួន រួមមានបទប្បញ្ញត្តិដាក់លាក់ស្តីពីការដោះលែងដោយមានលក្ខខណ្ឌ (ជាទូទៅ គេតែងហៅថាជាការប្តូរទោស "commutation of sentence") នៅក្នុងលក្ខន្តិកៈ និង វិធានស្តីពីនីតិវិធីនិងភ័ស្តុតាងរបស់តុលាការទាំងនោះ។ ការសម្រេចសេចក្តីបែបនេះត្រូវបានធ្វើឡើងដោយតុលាការខ្លួនឯង គឺមិនមែនដោយអាជ្ញាធរជាតិ ឬអន្តរជាតិ ក្រៅតុលាការនោះទេ។ ជាឧទាហរណ៍ នៅតុលាការ ICTY តុលាការ ICTR និង តុលាការ SCSL ជនជាប់ចោទម្នាក់ដែលមានពិរុទ្ធ អាចដាក់ពាក្យសុំទៅប្រធានតុលាការដើម្បីសុំឱ្យដោះលែងជាមុនបាន បន្ទាប់មកប្រធានតុលាការនោះត្រូវពិភាក្សាជាមួយចៅក្រមដែលកំណត់ទោស ដើម្បីវាយតម្លៃពីពាក្យសុំទាំងនោះ ក្នុងការពិចារណាពី "ប្រយោជន៍នៃយុត្តិធម៌ និងគោលការណ៍ទូទៅនៃច្បាប់"[243]។ ប្រធានត្រូវពិចារណាពីស្ថានទម្ងន់នៃបទឧក្រិដ្ឋទាំងនោះ ការប្រព្រឹត្តិប្រហាក់ប្រហែលគ្នាចំពោះអ្នកទោស

---

[243] លក្ខន្តិកៈនៃតុលាការ ICTY មាត្រា២៨, លក្ខន្តិកៈនៃតុលាការ ICTR មាត្រា២៧, លក្ខន្តិកៈនៃតុលាការ SCSL មាត្រា២៣, វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការ SCSL មាត្រា១២៣-២៤។

ផ្សេងទៀត ការស្តារនីតិសម្បទាឡើងវិញ និងការសហការជាមួយរដ្ឋអាជ្ញាក្នុងពេលជាប់ឃុំ[244]។ ស្រដៀងគ្នានេះដែរ ចៅក្រមបីរូបនៅតុលាការ ICC បានពិនិត្យឡើងវិញពីកត្តានានា ក្នុងការសម្រេចទៅលើភាពស្របច្បាប់នៃការដោះលែងដោយមានលក្ខខណ្ឌ រួមទាំងផលប៉ះពាល់ពីការដោះលែងជាមុន ចំពោះជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគាត់ ដែលកំពុងបន្តសហការជាមួយរដ្ឋអាជ្ញា និងការមិនចូលរួមសហការពីអ្នកទោសដែលមានបទឧក្រិដ្ឋ ក្នុងពេលកំពុងជាប់ឃុំឃាំងនោះ[245]។

១២៥- អង្គហេតុដែលថា ឯកសារនានាស្តីពីការបង្កើតតុលាការអន្តរជាតិពិសេសដាច់ដោយឡែក មិនមានចែងពីការដោះលែងដោយមានលក្ខខណ្ឌបង្ហាញថា អ្នកធ្វើសេចក្តីព្រាងឯកសារទាំងនោះមិនបានប្រមើលមើលថាតើ ការដោះលែងដោយមានលក្ខខណ្ឌគួរតែមានសម្រាប់ជនជាប់ចោទដែលត្រូវបានកាត់ទោសដោយតុលាការនេះ ឬយ៉ាងណា។ ក្នុងការដាក់សំណើរបស់ខ្លួនលើបញ្ហានេះ សហព្រះរាជអាជ្ញាមានចំណងយ៉ាងជិតស្និទ្ធទៅនឹងអាណត្តិការងាររបស់តុលាការនេះក្នុងការវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតមួយចំនួន ចំពោះបទឧក្រិដ្ឋទាំងឡាយដែលកើតឡើងនៅក្នុងរបបនោះ។

១២៦- ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាសូមស្នើថា គុណប្រយោជន៍នៃការដោះលែងដោយមានលក្ខខណ្ឌតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CCP") គឺមិនមានចំពោះចុងបណ្តឹងឧទ្ធរណ៍នេះទេ ដោយសារគាត់ត្រូវបានផ្តន្ទាទោសតែពីបទឧក្រិដ្ឋអន្តរជាតិប៉ុណ្ណោះ។ ហេតុនេះ មានតែរបបនៃការកាត់ទោស

---

[244] វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ ICTY មាត្រា១២៣-២៥, វិធានស្តីពីនីតិវិធីនិងភស្តុតាងនៃតុលាការ ICTR មាត្រា១២៤-២៦។

[245] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា១១០, វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ ICC មាត្រា២២៣-២៤។

អន្តរជាតិប៉ុណ្ណោះដែលគួរយកមកអនុវត្ត។ មិនមានបទឧក្រិដ្ឋដែលមានស្ថានទម្ងន់ស្រដៀងគ្នានៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ទេ សម្រាប់ចុងបណ្តឹងឧទ្ធរណ៍ដែលត្រូវវិនិច្ឆ័យថាមានទោសហើយនោះ[246]។ ជាងនេះទៀត ទោះបីគន្លីទី២ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ដែលយោងទៅដល់អំពើប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមក៏ដោយ ក៏គន្លីនេះមិនទាន់ត្រូវបានប្រកាសចូលជាធរមានអនុវត្តនៅឡើយទេ[247]។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានសំដែងពីការសង្ស័យថាតើតុលាការនេះអាចអនុវត្តតាមវិសោធនកម្មច្បាប់ក្នុងស្រុកបានដែរឬទេ ដោយសារ "ការបកស្រាយដូច្នេះ អាចមានន័យថា ច្បាប់ដែលចេញនាពេលអនាគតរបស់អង្គការនីតិបញ្ញត្តិ អាចប៉ះពាល់ដល់អានុភាពនៃកិច្ចព្រមព្រៀង [អ.វ.ត.ក]"[248]។

១២៧- ក្នុងករណីណាក៏ដោយ ច្បាប់នៃតុលាការនេះមិនបានផ្លាស់ប្តូរទេ ហើយគោលការណ៍*ភាពទន់ភ្លន់នៃច្បាប់(lex mitior)* ដែលតម្រូវឱ្យអនុវត្តការផ្តន្ទាទោសអប្បបរមា នៅពេលដែលច្បាប់ជាក់លាក់ណាមួយរបស់តុលាការត្រូវបានផ្លាស់ប្តូរ[249]។ ការធ្វើវិសោធនកម្មទៅលើច្បាប់ក្នុងស្រុកមិនប៉ះពាល់ដល់តុលាការនេះទេ[250] ដោយសារ"គោលបំណងរបស់ អ.វ.ត.ក ខុសគ្នាជាសំខាន់ពីដំណើរការសាមញ្ញរបស់តុលាការព្រហ្មទណ្ឌកម្ពុជា ដែលតម្រូវឱ្យមានប្រព័ន្ធមួយដែលមានលក្ខណៈពិសេស"[251]។

---

[246] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមនឹងវិសោធនកម្មនានា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ អ.វ.តក") ជំពូក II មាត្រា៣។

[247] សាលក្រម កថាខណ្ឌ៥៧៤។

[248] សាលក្រម កថាខណ្ឌ៥៧៤។

[249] អនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") មាត្រា១៥។

[250] អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ច្បាប់ អ.វ.ត.ក "បង្កើតឱ្យមានប្រព័ន្ធមួយដែលមានលក្ខណៈពិសេស" សាលក្រម កថាខណ្ឌ៥៧៤។

[251] បណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព កថាខណ្ឌ១៤។

ហេតុនេះចុងបណ្តឹងឧទ្ធរណ៍មិនអាចទទួលបានប្រយោជន៍ពីច្បាប់ក្នុងស្រុក ដែលមិនទាន់ចូលជាធរមាន ដែលតុលាការនេះមិនបានអនុម័តទទួលយកទេ។

១២៨- បទប្បញ្ញត្តិច្បាប់ក្នុងស្រុកទាក់ទិននឹងការដោះលែងដោយមានលក្ខខណ្ឌ មិនអនុវត្តនៅតុលាការនេះទេ ដោយសារលក្ខណៈពិសេសនៃការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋអន្តរជាតិទាំងឡាយ។តុលាការអន្តរជាតិ និងតុលាការកូនកាត់បានបង្កើតនូវលក្ខណៈវិនិច្ឆ័យបន្ថែមទៀត ដើម្បីត្រួសត្រាយផ្លូវដល់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីផ្តល់នូវការបន្ធូរទោស ឬការដោះលែងមុនពេលកំណត់ ជាជាងអ្វីដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[252]។ បើយើងធ្វើការប្រៀបធៀប មាត្រា៥១២ នៃក្រមនីតិវិធីព្រហ្ម-ទណ្ឌកម្ពុជា កំណត់ពីលក្ខខណ្ឌសម្រាប់ពិចារណាទៅដល់ការដោះលែងដោយមានលក្ខខណ្ឌ ចំពោះទណ្ឌិតដែលមានគំនិតមាយាទល្អ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញ នេះជាបទប្បញ្ញត្តិច្បាប់ដែលមិនមែនចែងសម្រាប់បទឧក្រិដ្ឋអន្តរជាតិទេ[253]។ មិនមែនជាសក្តិសមឡើយ ដែលត្រូវអនុវត្តតាមការណែនាំនៃការកំណត់ទោសកម្ពុជាចំពោះបទឧក្រិដ្ឋអន្តរជាតិ ដែលមិនមាននៅក្នុងក្របខណ្ឌនៃប្រព័ន្ធច្បាប់ក្នុងស្រុករបស់កម្ពុជា។

១២៩- ជាងនេះទៅទៀត ការអនុញ្ញាតឱ្យមានការដោះលែងដោយមានលក្ខខណ្ឌនៅក្រោមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺជាការដកចុងបណ្តឹងឧទ្ធរណ៍ចេញពីយុត្តាធិការនៃតុលាការនេះ ដែលវាផ្ទុយពីគោលការណ៍នានានៃតុលាការអន្តរជាតិ។ បើតាមបទដ្ឋានអន្តរជាតិ តុលាការដែលសម្រេចផ្តន្ទាទោសមុនគេ

---

[252] លក្ខន្តិកៈនៃតុលាការ ICTY មាត្រា២៨, លក្ខន្តិកៈនៃតុលាការ ICTR មាត្រា២៧, លក្ខន្តិកៈនៃតុលាការ SCSL មាត្រា២៣, លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា១១០, វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការ ICTY វិធាន១២៣-២៥, វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការ ICTR វិធាន១២៤-២៦, វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការ SCSL មាត្រា១២៣-២៤, វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការ ICC វិធាន២២៣-២៤។

[253] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ មាត្រា៥១២ ចែងថា៖ "គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញឱ្យឃើញថា ខ្លួនមានគំនិតមាយាទល្អក្នុងរយៈជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន"។

គឺមិនមានអំណាចចេញសេចក្តីសម្រេចលើបញ្ហាកាត់បន្ថយរយៈពេលនៃទោសឡើយ[254]។ មាត្រា ៥១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានរាប់បញ្ចូល អ.វ.ត.ក ទេ។ ហេតុនេះ ដំណើរការនៃការចេញសេចក្តីសម្រេចទាក់ទិននឹងការដោះលែងដោយមានលក្ខខណ្ឌត្រូវស្ថិតនៅក្នុង អ.វ.ត.ក តែម្តង[255]។ ការអនុញ្ញាតឱ្យមានការប្តូរទោសរបស់ចុងបណ្តឹងឧទ្ធរណ៍ដោយតុលាការណាមួយ ដែលគ្មានយុត្តាធិការលើបទឧក្រិដ្ឋអន្តរជាតិ គឺជាការមិនសមរម្យឡើយ ហើយវាក៏ធ្វើឱ្យអន្តរាយដល់គោលបំណងទាំងអស់ ដែលត្រូវបង្កើតតុលាការនេះឡើង។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា បញ្ហានៃការដោះលែងជាមុនអាចត្រូវបានពិចារណា ដោយអង្គជំនុំជម្រះណាមួយនៃតុលាការក៏បាន ប្រសិនបើអង្គជំនុំជម្រះនោះនៅមានដំណើរការក្នុងពេលពិចារណានេះ ឬក៏អាចយកទៅពិចារណាតាមយន្តការតុលាការណាមួយ ដែលនៅដំណើរការក្រោយពេល អ.វ.ត.ក រំលាយទៅ។

## ឃ.៤.៥ សេចក្តីសន្និដ្ឋាន

១៣០- អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាថាតើការកំណត់ទោសបែបណាដែលត្រូវសម្រេចចំពោះចុងបណ្តឹងឧទ្ធរណ៍ ដែលត្រូវតែឆ្លុះបញ្ចាំងពីការរន្ធត់ និងកំហឹង ដែលមនុស្សទាំងអស់យល់ឃើញចំពោះបទឧក្រិដ្ឋទាំងនេះ ដែលក្នុងន័យជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។ សហព្រះរាជអាជ្ញាសូមដាក់ស្នើ (ដូចដែលយើងបានដាក់ស្នើនៅអង្គជំនុំជម្រះសាលាដំបូងដែរ) ថាការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតគឺជាទណ្ឌកម្មតែមួយគត់ដែលសក្តិសមបំផុត សម្រាប់តួនាទីរបស់ចុងបណ្តឹង

---

[254] លក្ខន្តិកៈនៃតុលាការ ICTY មាត្រា២៨, លក្ខន្តិកៈនៃតុលាការ ICTR មាត្រា២៧, លក្ខន្តិកៈនៃតុលាការ SCSL មាត្រា ២៣, លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា១១០, វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ ICTY វិធាន១២៣-២៥, វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ ICTR វិធាន១២៤-២៦, វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ SCSL មាត្រា១២៣-២៤, វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ ICC វិធាន២៣៣-៣៤។

[255] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ មាត្រា៥១៤ ចែងថា៖ "ការដោះលែងដោយមានលក្ខខណ្ឌត្រូវផ្តល់ឱ្យដោយប្រធានតុលាការជាន់ដំបូងនៃទីកន្លែងឃុំខ្លួន។ ប្រធានតុលាការនេះ សម្រេចក្រោយពីបានទទួលយោបល់ពីគណៈកម្មាធិការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌"។

ឧទ្ធរណ៍នៅក្នុងបទឧក្រិដ្ឋទាំងនេះ[256]។ អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំ ដោយមិនបាន សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកម្រិតនេះ។

១៣១- ក្រៅពីការផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិតអង្គជំនុំជម្រះសាលាដំបូងគួរតែកាត់បន្ថយកម្រិតទោស មកត្រឹមជាប់ពន្ធនាគារ ៤៥ឆ្នាំបាន ដើម្បីជាការជួសជុលដល់ការជាប់ឃុំឃាំងដោយខុសច្បាប់ របស់ចុងបណ្តឹងឧទ្ធរណ៍។ ដោយសារថា ចុងបណ្តឹងឧទ្ធរណ៍ស្នើសុំរួចផុតពីការជាប់ទោស សហ-ព្រះរាជអាជ្ញាសូមស្នើថា ស្ថានសម្រាលទោសមិនគួរយកមកពិចារណាឡើយ។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលត្រូវពិចារណាទៅលើស្ថានសម្រាលដែលមានកម្រិតនោះ អាចផ្តល់ការបន្ធូរបន្ថយទោសជាអតិបរមាបានដល់រយៈពេល ៥ ឆ្នាំ។ អាស្រ័យហេតុនេះ ការកំណត់ទោសដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងគួរតែត្រឹមការជាប់ពន្ធនាគាររយៈពេល ៤០ ឆ្នាំ ដោយគ្មានបើកឱ្យមានការដោះលែងដោយមានលក្ខខណ្ឌឡើយ[257]។

## ខ. ឧបសគ្គករណ៍ទី២៖ ចុងបណ្តឹងសាទុក្ខគួរត្រូវបានកាត់ឲ្យជាប់ទោសពីបទឧក្រិដ្ឋកម្មទាំងអស់ ដែលបានរកឃើញថាគាត់គឺជាអ្នកត្រូវទទួលខុសត្រូវ

### ១. សេចក្តីសង្ខេប

១៣២- អង្គជំនុំជម្រះសាលាដំបូង មានការភាន់ច្រឡំផ្នែកអង្គច្បាប់ដែលធ្វើឱ្យសាលក្រមលែងមានសុពលភាព តាមរយៈការខកខានមិនបានផ្តន្ទាទោសត្រួតលើចុងបណ្តឹងសាទុក្ខ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀត និងតាមរយៈការស្រប

[256] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ៤៨៥។

[257] សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោល កថាខណ្ឌ៤៨៦។

បញ្ចូលឧក្រិដ្ឋកម្មទាំងនេះ ទៅក្នុងឧក្រិដ្ឋកម្មប្រឆាំនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ។

១៣៣- អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសឆ្គងផ្នែកអង្គច្បាប់មួយបន្ថែមទៀត តាមរយៈការកំណត់បទចោទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការរំលោភសេពសន្ថវៈ ថាជាការធ្វើទារុណកម្មទៅវិញ និងដោយខកខានមិនបានកាត់ទោសចុងបណ្តឹងសាទុក្ខឱ្យជាប់ទោសដាច់ដោយឡែកពីគ្នាពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការរំលោភសេពសន្ថវៈ និងការធ្វើទារុណកម្ម ។

## ១២. អង្គជំនុំជម្រះសាលាដំបូង បានស្រូបបញ្ចូលដោយមិនត្រឹមត្រូវនូវបទឧក្រិដ្ឋដទៃទៀតនៃការធ្វើទុក្ខបុកម្នេញ ក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

### ង.២.១ សេចក្តីផ្តើម

១៣៤- សហព្រះរាជអាជ្ញា សន្និដ្ឋានថា ទី១) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនីមួយៗ ដែលចុងបណ្តឹងសាទុក្ខត្រូវបានចោទប្រកាន់ *សុទ្ធតែមានធាតុផ្សំខុសៗគ្នាយ៉ាងពិតប្រាកដ*ដែលនៅក្នុងបទល្មើសផ្សេងៗទៀតមិនមានដូច *ទី២) ការខកខានរបស់*អង្គជំនុំជម្រះសាលាដំបូងក្នុងការកាត់ក្តីចុងបណ្តឹងសាទុក្ខឱ្យមាន ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងអស់ដែលរូបគាត់ត្រូវបានចោទប្រកាន់ គឺធ្វើឱ្យខូចដល់បំណងទាំងទ្វេរនៃការសាកល្បងនៃទោសត្រួត ទី៣) *សទិទានភាពនៃការមិនឱ្យមានការកាត់ទោសត្រួតមិនអាចឱ្យយកមកអនុវត្តនៅទីនេះបានទេ និងទី៤)* អង្គជំនុំជម្រះសាលាដំបូងខកខាន មិនបានពិចារណាឱ្យបានពេញលេញអំពីផលប្រយោជន៍សង្គម ដែលទទួលបានការការពារដោយ ឧក្រិដ្ឋកម្មនីមួយៗដែលមានចែងតាមលំដាប់លំដោយ និងអំពីតម្រូវការនៃ

កំណាត់ហេតុជាប្រវត្តិសាស្ត្រ មួយពេញលេញអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់ចុងបណ្តឹងសាទុក្ខនៅក្នុងព្រឹត្តិការណ៍ទាំងអស់នេះ ។

## ង.២.២ គ្រប់បទឧក្រិដ្ឋនីមួយៗដែលបានចោទប្រកាន់សុទ្ធតែមានធាតុផ្សំខុសៗគ្នាយ៉ាងពិតប្រាកដ

១៣៥- អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY នៅក្នុងរឿងក្តី *Čelebici* បានបង្កើតជារូបមន្តការសាកល្បងបច្ចុប្បន្ននោះសម្រាប់ធ្វើការកំណត់សម្រេចលើការអនុញ្ញាតឱ្យមានការផ្តន្ទាទោស ពីបទល្មើសជាច្រើនមុខសម្រាប់អំពើ ឬការខកខានតែមួយដដែល ដោយថ្លែងថា "ការផ្តន្ទាទោសព្រហ្មទណ្ឌពីបទល្មើសជាច្រើនមុខ ដែលស្ថិតក្រោមបទប្បញ្ញត្តិច្បាប់ខុសៗគ្នា ប៉ុន្តែផ្អែកលើមូលដ្ឋាននៃអំពើតែមួយដដែលអាចអនុញ្ញាតឱ្យបាន វៀរលែងតែបទប្បញ្ញត្តិច្បាប់នីមួយៗដែលពាក់ព័ន្ធនោះមានធាតុផ្សំខុសៗគ្នាយ៉ាងពិតប្រាកដ ដែលនៅក្នុងបទល្មើសផ្សេងទៀតមិនមានដូច ។ ធាតុផ្សំណាមួយខុសគ្នាយ៉ាងពិតប្រាកដពីធាតុផ្សំមួយទៀត បើសិនជាធាតុផ្សំនោះតម្រូវឱ្យមានភស្តុតាងបញ្ជាក់ពីអង្គហេតុមួយថា នៅក្នុងបទឧក្រិដ្ឋផ្សេងទៀតមិនបាច់តម្រូវឱ្យមានធាតុផ្សំនេះទេ[258] ។

១៣៦- នៅក្នុងរឿងក្តី *Popovic* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY នាពេលថ្មីៗនេះបានសម្រេចថាការកាត់ទោសត្រួតចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត គឺអាចអនុញ្ញាតឱ្យធ្វើបាន[259]។ ក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Popovic* បានអនុវត្តតាមការសាកល្បងក្នុងរឿងក្តី *"Čelebici"* និងបានរកឃើញថា គ្រប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនីមួយៗក្នុង

---

[258] សាលដីកាសម្រេចលើបណ្តឹងសាទុក្ខករណីរឿងក្តីរបស់ *Čelebići* កថាខណ្ឌទី ៤១២។

[259] *រដ្ឋអាជ្ញា ទល់នឹង Popović*, សាលក្រម, IT-05-88-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី១០ មិថុនា ២០១០ ("សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងករណី *Popović*) ,កថាខណ្ឌទី ២១១៣។

ចំណោមឧក្រិដ្ឋកម្មទាំងបី មានផ្ទុកនូវធាតុផ្សំខុសៗគ្នាយ៉ាងពិតប្រាកដដែលនៅក្នុងឧក្រិដ្ឋកម្មផ្សេងទៀតមិនមានដូច[260] ។

១៣៧- ស្រដៀងគ្នានេះដែរ ក្នុងករណីរឿងបច្ចុប្បន្ននេះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានស្រូបបញ្ចូលទៅក្នុងអំពើនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ទាំងអស់នេះសុទ្ធតែមានធាតុផ្សំខុសៗយ៉ាងពិតប្រាកដ ដែលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ មិនមានដូចនោះទេ។

*ង.២.២.១ ឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ*

១៣៨- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិការធ្វើមនុស្សឃាត មានធាតុផ្សំបី៖ ទី១) ការស្លាប់នៃជនរងគ្រោះដែលបណ្តាលមកពីអំពើខុសច្បាប់ ឬការខកខានណាមួយដោយចារី[261] ទី២) ការរួមចំណែកដ៏មានសក្តានុពលនៃអំពើរបស់ចារីដល់ការស្លាប់នៃជនរងគ្រោះ[262] និងទី៣) ចេតនាសម្លាប់ ឬបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់រាងកាយក្នុងដឹងដោយសមហេតុផលមួយដែលថា អំពើ ឬការខកខាននោះ ទំនងជាបណ្តាលឱ្យស្លាប់[263]។

១៣៩- ផ្ទុយទៅវិញ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមានធាតុផ្សំពីរ៖ ទី១) អំពើ ឬការខកខានដោយសារការរើសអើង ដែលបានប្រព្រឹត្តឡើងក្នុងទ្រង់

---

260 សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងករណី *Popovic*, កថាខណ្ឌទី ២១១១-២១១៣។

261 សាលក្រម, កថាខណ្ឌទី ៣៣១ ។

262 សាលក្រម, កថាខណ្ឌទី ៣៣១ ។

263 សាលក្រម, កថាខណ្ឌទី ៣៣៣ ។

00613541



ទ្រាយធំពាក់ព័ន្ធនឹងឧក្រិដ្ឋភាពដ៏ធំធេង[264] និងទី២) ចេតនាជាក់លាក់ដើម្បីធ្វើការរើសអើងដោយមូលហេតុនយោបាយ[265]។

១៤០- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ មិនតម្រូវឱ្យមានសក្ខីកម្មបង្ហាញថា ចារីត្រូវមានអំពើរើសអើង និងចេតនា ដែលបានបង្កឱ្យស្លាប់ជនរងគ្រោះណាម្នាក់នោះទេ។ ជាងនេះទៀត កំរិតនៃលក្ខខណ្ឌតម្រូវឱ្យមានការបង្ហាញពីហេតុផល និងចេតនាក្នុងការធ្វើមនុស្សឃាត សម្រាប់ឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត មិនចាំបាច់បង្ហាញភស្តុតាងដើម្បីឱ្យឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយបានកើតមានឡើង នោះទេ ។

១៤១- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើមនុស្សឃាត មិនតម្រូវឱ្យមានទាំងអំពើ និងទាំងការខកខានក្នុងលក្ខណៈរើសអើងជាទ្រង់ទ្រាយធំ ឬទាំងចេតនារើសអើងជាក់លាក់ណាមួយ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាឡើយ ។

១៤២- ដោយហេតុថា ក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលឧក្រិដ្ឋកម្មនីមួយៗសុទ្ធតែមានធាតុផ្សំពិតប្រាកដខុសៗគ្នា ដែលនៅក្នុងឧក្រិដ្ឋកម្មមួយផ្សេងទៀតមិនមានដូចនោះទេ ហេតុដូចនេះ គឺអង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំដោយខកខានមិនបានកាត់ទោសចុងបណ្តឹងសាទុក្ខឱ្យជាប់ទោសដាច់ដោយឡែកពីគ្នា ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើមនុស្សឃាត។

---

264 សាលក្រម, កថាខណ្ឌទី ៣៧៤ ។

265 សាលក្រម, កថាខណ្ឌទី ៣៧៨ ។

*ង.២.២.២ ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ*

១៤៣- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិការសម្លាប់រង្គាល មានធាតុផ្សំពីរៈ ទី១) អំពើ ការខកខានណាមួយ ឬរួមផ្សំគ្នានៃឧក្រិដ្ឋកម្មនីមួយៗដែលបណ្តាលឱ្យមានការស្លាប់មនុស្សក្នុងទំហំដ៏ធំធេងណាមួយ[266] និង ទី២) ចេតនាសម្លាប់មនុស្សក្នុងទំហំដ៏ធំធេង ឬបង្កឱ្យរងរបួសធ្ងន់ធ្ងរដល់រូបរាងកាយ ឬដើម្បីបង្កើតលក្ខខណ្ឌដល់ជីវិតរស់នៅ ដែលនាំទៅដល់ការស្លាប់នៃមនុស្សក្នុងចំនួនដ៏ច្រើនដោយដឹងដោយសមហេតុផលថា អំពើឬការខកខាននោះប្រាកដជានឹងបណ្តាលឱ្យមានការស្លាប់ក្នុងចំនួនដ៏ច្រើនជាពុំខានឡើយ[267] ។

១៤៤- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ គឺមិនតម្រូវឱ្យបង្ហាញភស្តុតាងបញ្ជាក់ពីអំពើរបស់ចារី ដែលបានបង្កឱ្យមានការស្លាប់មនុស្សក្នុងទំហំមួយដ៏ធំធេងនោះទេ ។ លើសពីនេះ ចេតនាសម្លាប់មនុស្សក្នុងទំហំដ៏ធំ ពុំចាំបាច់តម្រូវឱ្យមានភស្តុតាងបញ្ជាក់ដើម្បីកាត់ទោស ជនជាប់ចោទណាម្នាក់ពីបទប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញដោយ មូលហេតុនយោបាយឡើយ ។

១៤៥- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់រង្គាល មិនតម្រូវឱ្យមានទាំងអំពើ ទាំងការខកខានក្នុងលក្ខណៈរើសអើងធំធេង និងទាំងចេតនាជាក់លាក់ណាមួយនៃការប្រកាន់រើសអើង ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាឡើយ ។

១៤៦- ដោយហេតុថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលឧក្រិដ្ឋកម្មនីមួយៗសុទ្ធតែមានធាតុផ្សំខុសៗគ្នាយ៉ាងពិតប្រាកដដែលនៅ

---

266 សាលក្រម, កថាខណ្ឌទី ៣៣៤ ។

267 សាលក្រម, កថាខណ្ឌទី ៣៣៨ ។

ក្នុងឧក្រិដ្ឋកម្មមួយផ្សេងទៀតមិនមានដូចគ្នាឡើយ អាស្រ័យហេតុនេះគឺ អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំក្នុងការខកខានមិនបានកាត់ក្ដីចុងបណ្ដឹងសាទុក្ខឱ្យមានទោស ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹង មនុស្សជាតិនៃការសម្លាប់រង្គាល។

*ង.២.២.៣ ឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ*

១៤៧- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការធ្វើឱ្យទៅជាទាសករ មានធាតុផ្សំពីរៈ ទី១) ការប្រើប្រាស់អំណាចណាមួយ ឬទាំងអស់ដែលមានជាប់មកជាមួយនឹងសិទ្ធិនៃភាពជាម្ចាស់លើជនណាម្នាក់*[268] *និងទី២) ចេតនាក្នុងការប្រើប្រាស់នៃអំណាចណាមួយ ឬទាំងអស់ដែលមានជាប់មកជាមួយនឹងសិទ្ធិនៃភាពជាម្ចាស់នេះ*[269] ។

១៤៨- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ មិនតម្រូវឱ្យមានភស្តុតាងបញ្ជាក់ថា ចារីបាន*ប្រើប្រាស់អំណាចណាមួយ ឬទាំងអស់ដែលមានជាប់មកជាមួយនឹងសិទ្ធិនៃភាពជាម្ចាស់ទៅលើជនណាម្នាក់*ឡើយ ។

១៤៩- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការធ្វើឱ្យទៅជាទាសករ* មិនតម្រូវឱ្យមានទាំងអំពើ ឬទាំងការខកខានក្នុងលក្ខណៈរើសអើងធំធេង និងទាំងចេតនាជាក់លាក់ណាមួយដើម្បីធ្វើការរើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាឡើយ ។

១៥០- ដោយហេតុថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការធ្វើឱ្យទៅជាទាសករ* និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយដែល ឧក្រិដ្ឋកម្មនីមួយៗសុទ្ធតែមានធាតុផ្សំខុសៗគ្នាយ៉ាងពិតប្រាកដ

---

[268] សាលក្រម, កថាខណ្ឌទី ៣៣៤២ ។

[269] សាលក្រម, កថាខណ្ឌទី ៣៤៥ ។

ដែលនៅក្នុងឧក្រិដ្ឋកម្មមួយផ្សេងទៀតមិនមានដូចនោះ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំ ក្នុងការខកខានមិនបានផ្តន្ទាទោសចុងបណ្តឹងសាទុក្ខដាច់ដោយឡែកពីគ្នាពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការធ្វើឱ្យទៅជាទាសករ* ។

*ង.២.២.៤ ឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ*

១៥១- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការដាក់ក្នុងមន្ទីរឃុំឃាំង មានធាតុផ្សំពីរៈ ទី១) ការដកហូតតាមទំនើងនូវសិទ្ធិសេរីភាពរបស់ជនណាម្នាក់ ដោយពុំបានដំណើរការនីតិវិធីត្រឹមត្រូវតាមច្បាប់*[270] *និងទី២) ចេតនាធ្វើឡើងដោយចារី ដើម្បីដកហូតនូវសិទ្ធិសេរីភាពរបស់បុគ្គលណាម្នាក់តាមទំនើងចិត្ត ឬអំពើណាមួយធ្វើឡើងដោយចារី ដែលបានដឹងដោយសមហេតុផលថា សកម្មភាពរបស់គាត់ទំនងជានឹង បង្កឱ្យមានការដកហូតនូវសិទ្ធិសេរីភាពជារូបវ័ន្ត*[271] ។

១៥២- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ មិនចាំបាច់តម្រូវឱ្យមានភស្តុតាងបញ្ជាក់ថា ចារីបាន*ដកហូតដោយចេតនា នូវសិទ្ធិសេរីភាពរបស់បុគ្គលណាម្នាក់តាមទំនើងចិត្ត ដោយពុំមានដំណើរនីតិវិធីត្រឹមត្រូវតាមនោះឡើយ* ។

១៥៣- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការដាក់ក្នុងមន្ទីរឃុំឃាំង* មិនចាំបាច់តម្រូវឱ្យមានទាំងអំពើ ឬការខកខានក្នុងលក្ខណៈរើសអើងធំធេង និងទាំងចេតនាជាក់លាក់ណាមួយដើម្បីធ្វើការរើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាឡើយ ។

១៥៤- ដោយហេតុថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការដាក់ក្នុងមន្ទីរឃុំឃាំង*និងការធ្វើទុក្ខបុកម្នេញ

---

[270] សាលក្រម, កថាខណ្ឌទី ៣៤៧ ។

[271] សាលក្រម, កថាខណ្ឌទី ៣៥០ ។

00613545



ដោយមូលហេតុនយោបាយ ដែលឧក្រិដ្ឋកម្មនីមួយៗសុទ្ធតែមានធាតុផ្សំខុសៗគ្នាយ៉ាងពិតប្រាកដ ដែលនៅក្នុងឧក្រិដ្ឋកម្មមួយផ្សេងទៀតមិនមានដូចនោះ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំ ក្នុងការខកខានមិនបានផ្តន្ទាទោសចុងបណ្តឹងសាទុក្ខ ដាច់ដោយឡែកពីគ្នាពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការដាក់ក្នុងមន្ទីរឃុំឃាំង*។

*ង.២.២.៥ ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ*

១៥៥- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការធ្វើទារុណកម្មក្នុង ឆ្នាំ១៩៧៥ មានធាតុផ្សំបួន៖ ទី១) ការបង្កតាមរយៈអំពើឬការខកខានណាមួយដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខធ្ងន់ធ្ងរ មិនថាលើរូបរាងកាយ ឬ ផ្លូវចិត្ត*[272] *ទី២) គោលដៅនៃការបង្កឱ្យមានការឈឺចាប់ ឬរងទុក្ខធ្ងន់ធ្ងរនោះគឺដើម្បីទទួលបានលទ្ធផល ឬគោលបំណងពិតប្រាកដណាមួយ*[273] *ទី៣) ការចូលរួមពាក់ព័ន្ធរបស់មន្ត្រីរដ្ឋណាម្នាក់នៅក្នុងការបង្កនោះ*[274] *និងទី៤)ចេតនាដើម្បីបង្កឱ្យមានការឈឺចាប់ ឬរងទុក្ខដែលស្មើនឹងការធ្វើទារុណកម្ម*[275] ។

១៥៦- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ មិនចាំបាច់តម្រូវ ឱ្យមានភស្តុតាងបញ្ជាក់ថាមន្ត្រីរដ្ឋណាម្នាក់ បានចូលរួមពាក់ព័ន្ធនៅក្នុងការបង្កដោយចេតនា*ឱ្យមានការឈឺចាប់ឬរងទុក្ខធ្ងន់ធ្ងរ ដើម្បីទទួលបានលទ្ធផល ឬគោលបំណងពិតប្រាកដណាមួយទេ* ។

---

272 សាលក្រម, កថាខណ្ឌទី ៣៥៤ ។

273 សាលក្រម, កថាខណ្ឌទី ៣៥៦ ។

274 សាលក្រម, កថាខណ្ឌទី ៣៥៧ ។

275 សាលក្រម, កថាខណ្ឌទី ៣៥៨ ។

១៥៧- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការធ្វើទារុណកម្ម* មិនចាំបាច់តម្រូវឱ្យមានទាំងអំពើ ឬ ការខកខានក្នុងលក្ខណៈរើសអើងធំធេង និងទាំងចេតនាជាក់លាក់ណាមួយដើម្បីធ្វើការរើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាឡើយ ។

១៥៨- ដោយហេតុថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការធ្វើទារុណកម្ម* និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលឧក្រិដ្ឋកម្មនីមួយៗសុទ្ធតែមានធាតុផ្សំខុសៗគ្នាយ៉ាងពិតប្រាកដ ដែលនៅក្នុងឧក្រិដ្ឋកម្មផ្សេងទៀតមិនមានដូចនោះ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំក្នុងការខកខានមិនបានផ្តន្ទាទោសចុងបណ្តឹងសាទុក្ខដាច់ដោយឡែកពីគ្នា ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការធ្វើទារុណកម្ម* ។

### *ង.២.២.៦ ឧក្រិដ្ឋកម្មនៃការរំលោភសេពសន្ថវៈ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ*

១៥៩- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការរំលោភសេពសន្ថវៈ មានធាតុផ្សំបី៖ ទី១)ការបញ្ចូលអង្គជាតិ*[276] *ទី២) ដោយពុំមានការយល់ព្រមពីជនរងគ្រោះ*[277] *និងទី៣) ចេតនាដើម្បីធ្វើឱ្យមានប្រសិទ្ធភាពនៃការបញ្ចូលអង្គជាតិ និងដោយបានដឹងថា វាបានកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ*[278] ។

១៦០- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ មិនតម្រូវឱ្យមានភស្តុតាងបញ្ជាក់អំពីការបញ្ចូលអង្គជាតិដោយចេតនាដោយចារីដឹងថា *វាបានកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះនោះទេ* ។

១៦១- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការរំលោភសេពសន្ថវៈ* មិនចាំបាច់តម្រូវឱ្យមានទាំងអំពើ ឬទាំងការខកខានក្នុងលក្ខណៈរើសអើងធំធេង និងទាំងចេតនាជាក់លាក់ណាមួយ ដើម្បីធ្វើការរើសអើង

---

[276] សាលក្រម, កថាខណ្ឌទី ៣៦២ ។

[277] សាលក្រម, កថាខណ្ឌទី ៣៦២ ។

[278] សាលក្រម, កថាខណ្ឌទី ៣៦៥ ។

ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាឡើយ ។

១៦២- ដោយហេតុថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការរំលោភសេពសន្ថវៈ* និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលឧក្រិដ្ឋកម្មនីមួយៗសុទ្ធតែមានធាតុផ្សំខុសៗគ្នាយ៉ាងពិតប្រាកដ ដែលនៅក្នុងឧក្រិដ្ឋកម្មមួយផ្សេងទៀតមិនមានដូចនោះ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំក្នុងការខកខានមិនបានផ្តន្ទាទោសចុងបណ្តឹងសាទុក្ខដាច់ដោយឡែកពីគ្នា ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*ការរំលោភសេពសន្ថវៈ*។

### *ង.២.២.៧ ឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ*

១៦៣- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*នៃអំពើអមនុស្សធម៌ផ្សេងៗទៀត មានធាតុផ្សំបី៖ ទី១)* អំពើ ឬការខកខានរបស់ចារី ដែលបានធ្វើឱ្យជនរងគ្រោះរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញា[279] ទី២) ភាពស្រដៀងគ្នាគ្រប់គ្រាន់រវាងភាពធ្ងន់ធ្ងរនៃអំពើ ឬការខកខានចំពោះឧក្រិដ្ឋកម្មដទៃទៀតដែលបានចែង[280] និងទី៣) ចេតនាធ្វើឡើងដោយចារី ក្នុងពេលមានអំពើ ឬ ការខកខាននោះ ដើម្បីបង្កឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រូបរាងកាយនិងផ្លូវចិត្ត ឬដើម្បីប្រព្រឹត្តការវាយប្រហារធ្ងន់ធ្ងរណាមួយទៅលើភាពថ្លៃថ្នូររបស់មនុស្សនៃជនរងគ្រោះ។ ការដឹងរបស់ចារីដែលថា អំពើ ឬការខកខាននោះទំនងជាបង្កឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រូបរាងកាយនិងផ្លូវចិត្ត ឬការវាយ ប្រហារធ្ងន់ធ្ងរណាមួយទៅលើភាពថ្លៃថ្នូររបស់មនុស្សមានលក្ខណៈគ្រប់គ្រាន់[281] ។

---

[279] សាលក្រម, កថាខណ្ឌទី ៣៦៨ ។

[280] សាលក្រម, កថាខណ្ឌទី ៣៦៧ ។

[281] សាលក្រម, កថាខណ្ឌទី ៣៧១ ។

១៦៤- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ មិនចាំបាច់តម្រូវឱ្យមានភស្តុតាងបញ្ជាក់អំពីអំពើ ឬការខកខានដែលមានភាពធ្ងន់ធ្ងរស្រដៀងគ្នាទៅនឹងបទឧក្រិដ្ឋដែលមានចែងដទៃទៀតបណ្តាលឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រូបរាងកាយ និងសតិបញ្ញាជនរងគ្រោះដែលបានប្រព្រឹត្តដោយចារី ក្នុងចេតនាបង្កឱ្យមានការរងទុក្ខវេទនាធ្ងន់ធ្ងរដល់រាងកាយ និងផ្លូវចិត្ត។

១៦៥- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*អំពើអមនុស្សធម៌ផ្សេងៗទៀត* មិនចាំបាច់តម្រូវឱ្យមានទាំងអំពើ ឬការខកខានក្នុងលក្ខណៈរើសអើងធំធេង និងទាំងចេតនាជាក់លាក់ណាមួយ ដើម្បីធ្វើការរើសអើង ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាឡើយ ។

១៦៦- ដោយហេតុថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*អំពើអមនុស្សធម៌ផ្សេងៗទៀត* និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឧក្រិដ្ឋកម្មនីមួយៗសុទ្ធតែមានធាតុផ្សំខុសៗគ្នាយ៉ាងពិតប្រាកដដែលនៅក្នុងឧក្រិដ្ឋកម្មផ្សេងទៀតមិនមានដូចនោះ អាស្រ័យហេតុនេះអង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំក្នុងការខកខានមិនបានផ្តន្ទាទោសចុងបណ្តឹងសាទុក្ខដាច់ដោយឡែកពីគ្នា ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ*អំពើអមនុស្សធម៌ផ្សេងៗទៀត* ។

## ង.២.៣ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានបំពេញគ្រប់ តាមគោលបំណងនៃការកាត់ទោសត្រួត

១៦៧- *អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ* ICTY នៅក្នុងរឿងក្តី *Kordic* បានធ្វើឱ្យកាន់តែច្បាស់ពីគោលដៅទាំងទ្វេ ក្នុងការសាកល្បងកាត់ទោសត្រួតនៃរឿងក្តី *Čelebici* ដោយហេតុថា ទី១) ធានាឱ្យប្រាកដថាការកាត់ទោស ត្រូវឆ្លុះបញ្ចាំងឱ្យបានពេញលេញពីឧក្រិដ្ឋភាពរបស់គាត់ និងទី២) ធានាថាការកាត់ទោសដែលបានចូលជាធរមាននោះ គឺឆ្លុះបញ្ចាំងទាំងស្រុងពីពិរុទ្ធភាពរបស់គាត់[282]។

[282] សាលដីកាបណ្តឹងឧទ្ធរណ៍ ក្នុងរឿងក្តី *Kordic* និង *Čerkez*, កថាខណ្ឌទី ១០៣៣ ។

*អង្គជំនុំជម្រះសាលាឧទ្ធរណ៍*ក្នុងរឿងក្តី *Kordic* ដោយប្រកាន់យ៉ាងខ្ជាប់ខ្ជួនទៅនឹងយុត្តិសាស្ត្រនៃ *អង្គជំនុំជម្រះសាលាឧទ្ធរណ៍* ក្នុងរឿងក្តី *Jelisic, KupreÈkic, Kunarac* និង *Musema*[283] នៅតែបញ្ជាក់ឡើងវិញជាថ្មីថា "នៅពេលអនុវត្តនូវការសាកល្បងនៃរឿងក្តី *Čelebici* អ្វីដែលត្រូវពិចារណានោះគឺធាតុផ្សំផ្នែកច្បាប់ នៃបទល្មើសនីមួយៗ មិនមែនអំពើ ឬការខកខានដែលនាំឱ្យមានការកើតឡើងនៃបទល្មើសនោះទេ[284] ។

១៦៨- គោលដៅទាំងទ្វេនៃការសាកល្បងអំពីការកាត់ទោសត្រួត ដូចបានថែងក្នុងរឿងក្តី *Čelebici* អាចនឹងត្រូវបានបំពេញ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលរកឃើញថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំដោយខកខានមិនបានផ្តន្ទាទោសចុងបណ្តឹងសាទុក្ខ ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នីមួយៗ ដូចដែលគាត់ត្រូវបានចោទប្រកាន់ឡើយ ។

១៦៩- ដូចបានរៀបរាប់ល្អិតល្អន់ក្នុងផ្នែកខាងលើស្រាប់ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនីមួយៗ ដូចដែលចុងបណ្តឹងសាទុក្ខត្រូវបានចោទប្រកាន់ គឺជាបទល្មើសដាច់ដោយឡែកពីគ្នា។ តាមរយៈការខកខានមិនបានផ្តន្ទាទោសចុងបណ្តឹងសាទុក្ខចំពោះបទល្មើសនីមួយៗទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើឱ្យខូចចំពោះធម្មានុរូប និងប្រសិទ្ធភាពនៃការសាកល្បងក្នុងការកាត់ទោសត្រួត។ ជាមួយគ្នានេះ តាមរយៈការស្រូបបញ្ចូលឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចំនួនប្រាំពីរខុសៗគ្នា ទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយតែមួយគត់ប៉ុណ្ណោះនោះ គឺអង្គជំនុំជម្រះសាលាដំបូងបានបន្ទាបដល់សសរទ្រូងទីពីរនៃការសាកល្បងនៃការកាត់ទោសត្រួតនោះ គឺការធានាឱ្យប្រាកដថា ការកាត់ទោស ត្រូវឆ្លុះបញ្ចាំងឱ្យបានពេញលេញទាំង

---

[283] សាលដីកាបណ្តឹងឧទ្ធរណ៍ ក្នុងរឿងក្តី *Kordić* និង *Čerkez,* កថាខណ្ឌទី ១០៤០ ។

[284] សាលដីកាបណ្តឹងឧទ្ធរណ៍ ក្នុងរឿងក្តី *Kordić* និង *Čerkez,* កថាខណ្ឌទី ១០៣៣ ។

00613550



ស្រុងពីឧក្រិដ្ឋភាពរបស់ជនជាប់ចោទ។ ការកាត់ទោសពីបទល្មើសតែមួយចំពោះអំពើ ឬការខកខាន ដែលមានលក្ខណៈរើសអើងក្នុងស្ថានភាពមួយ ដែលពាក់ព័ន្ធនឹងទម្រង់ផ្សេងៗនៃឧក្រិដ្ឋភាពដ៏ធំធេងមួយចំនួននោះ គឺមិនបានឆ្លុះបញ្ចាំងពីវិសាលភាពពេញលេញទាំងស្រុងនៃការចូលរួមរបស់ចុងបណ្តឹងសាទុក្ខ នៅក្នុងឧក្រិដ្ឋកម្មនានាដ៏គួរឱ្យរន្ធត់ឱ្យនៅមន្ទីរស-២១ នេះឡើយ។

### ង.២.៤ សនិទានភាពនៃការមិនអនុញ្ញាតឱ្យមានទោសត្រួត គឺមិនអាចយកមកអនុវត្តនៅទីនេះបានទេ

១៧០- លោកចៅក្រម Hunt និង Benouna បានពន្យល់នៅក្នុងយោបល់ជំទាស់របស់ខ្លួន នៅក្នុងសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍នៃករណីរឿក្តីរបស់ *Čelebici* ថា សនិទានភាពនៃការមិនអនុញ្ញាតឱ្យផ្តន្ទាទោសត្រួតគឺថា "វាធ្វើឱ្យខូចប្រយោជន៍របស់ជនជាប់ចោទ-ឬហានិភ័យដ៏ពិតប្រាកដនៃការធ្វើឱ្យខូចប្រយោជន៍នោះ-គឺវាស្ថិតនៅត្រង់ការអនុញ្ញាតឱ្យមានទោសត្រួតនេះតែម្តង"[285]។ ហានិភ័យដែលត្រូវបានយល់ឃើញថា ធ្វើឱ្យខូចប្រយោជន៍ដល់ជនត្រូវចោទនោះ គឺមិនត្រូវបានធ្វើយុត្តិកម្មទេ ពីព្រោះការព្រួយបារម្ភចំនួនពីរ ដែលជាមូលដ្ឋានគាំទ្រចំពោះសនិទានភាពនៃការមិនអនុញ្ញាតឱ្យមានទោសត្រួតនោះ មិនអាចយកមកអនុវត្តចំពោះករណីនេះបានឡើយ។

#### ង.២.៤.១ សិទ្ធិត្រូវបានទទួលការដោះលែងតាំងពីដំបូង គឺមិនមែនជាការព្រួយបារម្ភដែលមានសុពលភាពនោះទេ

១៧១- ការព្រួយបារម្ភមួយដែលជាមូលដ្ឋានគាំទ្រដល់សនិទានភាពនៃការមិនអនុញ្ញាតឱ្យផ្តន្ទាទោសទោសត្រួតគឺថា " តាមច្បាប់របស់រដ្ឋដែលជាអ្នកពង្រឹងការអនុវត្តន៍ការផ្តន្ទាទោស" ការមានសិទ្ធិត្រូវបានទទួលការដោះលែងតាំងពីដំបូងរបស់ទណ្ឌិតណាម្នាក់ គឺវាមិនអាស្រ័យទៅលើតែការផ្តន្ទាទោស

---

[285] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍លើករណីរឿងរបស់ *Čelebići* មតិជំទាស់ដោយឡែកពីគ្នារបស់លោកចៅក្រម Hunt និង Benouna, កថាខណ្ឌទី ២៣។

ដែលបានសម្រេចហើយតែប៉ុណ្ណោះនោះទេ ក៏ប៉ុន្តែវាអាស្រ័យទៅលើចំនួន និង/ឬ ប្រភេទនៃទោស ដែលត្រូវបានកាត់ឱ្យជាប់នោះផងដែរ"[286]។

១៧២- ការព្រួយបារម្ភដូចនេះមិនអាចយកមកអនុវត្តនៅក្នុងករណីរឿបច្ចុប្បន្ននេះបានឡើយ។ សហព្រះរាជអាជ្ញានៅតែរក្សាជំហរដដែលថា ចុងបណ្តឹងសាទុក្ខមិនមានសិទ្ធិត្រូវទទួលបាននូវការដោះលែងតាំងពីដំបូងទេ។ ដូចបានលើកឡើងពីខាងលើស្រាប់ហើយថា គឺមានតែតុលាការនេះតែមួយគត់ប៉ុណ្ណោះដែលជាអាជ្ញាធរមានសមត្ថកិច្ច ក្នុងការពង្រឹងការអនុវត្តទោសរបស់ចុងបណ្តឹងសាទុក្ខ។ ហេតុដូចនេះដោយសារតែតុលាការនេះគឺជាអ្នកដែលនឹងត្រូវពង្រឹងការអនុវត្តទោសរបស់ដើមបណ្តឹងសាទុក្ខនេះហើយ ហើយដោយសារចុងបណ្តឹងសាទុក្ខគ្មានសិទ្ធិត្រូវទទួលបានការដោះលែងក្រោមសមត្ថកិច្ចរបស់តុលាការនេះទេនោះ ទើបបានជាការព្រួយបារម្ភនេះមិនមែនជាកត្តាសម្រាប់កំណត់សម្រេចអំពី តើគួរ ឬមិនគួរអនុញ្ញាតឱ្យផ្តន្ទាទោសត្រួតទោសត្រួត។

### ង.២.៤.២ ការអនុវត្តនូវច្បាប់ "ស្តីពីជនល្មើសដែលប្រព្រឹត្តបទល្មើសជាទម្លាប់" គឺមិនមែនជាការព្រួបារម្ភនោះទេ

១៧៣- ការព្រួយបារម្ភទី២មួយទៀត ដែលជាមូលដ្ឋានគាំទ្រដល់សនិទានភាពនៃការមិនអនុញ្ញាតឱ្យមានទោសត្រួតគឺថា "ការផ្តន្ទាទោសត្រួតអាចនឹងដាក់ទណ្ឌិតឱ្យប្រឈមនឹងហានិភ័យនៃការកើនឡើងនូវរយៈពេលផ្តន្ទាទោសថែមទៀត និង/ឬការអនុវត្តនូវច្បាប់ស្តីពីជនប្រព្រឹត្តបទល្មើសជាទម្លាប់" ក្នុងករណីដែលមានការកាត់ឱ្យជាប់ទោសជាបន្តបន្ទាប់នៅក្នុងយុត្តាធិការណាមួយផ្សេងទៀត"[287]។

---

[286] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍លើករណីរឿងរបស់ *Čelebići* មតិជំទាស់ដោយឡែកពីគ្នារបស់លោកចៅក្រម Hunt និង Benouna, កថាខណ្ឌទី ២៣។

[287] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍លើករណីរឿងរបស់ *Čelebići* មតិជំទាស់ដោយឡែកពីគ្នារបស់លោកចៅក្រម Hunt និង Benouna, កថាខណ្ឌទី ២៣។

00613552



១៧៤- ការព្រួយបារម្ភនេះក៏មិនអាចយកមកអនុវត្តនៅក្នុងករណីរឿងបច្ចុប្បន្ននេះបានដែរ។ ចុងបណ្ដឹងសាទុក្ខកើតនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៤២ ដែលនឹងត្រូវមានអាយុយ៉ាងហោចក៏៨៩ឆ្នាំដែរនៅពេលដែលគាត់ត្រូវគេដោះលែងពីពន្ធនាគារ។ ភវនីយភាពដែលថា ចុងបណ្ដឹងសាទុក្ខនឹងត្រូវចាកចេញពីប្រទេសកម្ពុជា ទៅកាន់យុត្តាធិការណាមួយផ្សេងទៀតដែលនៅយុត្តាធិការផ្សេងដែលនឹងត្រូវកាត់ឱ្យជាប់ទោសតិចជាងនេះឆ្ងាយណាស់នោះ គឺប្រាកដជាមិនមានអត្ថិភាពទាល់តែសោះ ។

**ង.២.៥ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាពីផលប្រយោជន៍សង្គមក្នុងការផ្ដន្ទាទោសត្រួត**

ង.២.៥.១ ទិដ្ឋភាពរួម

១៧៥- នៅក្នុងករណីរឿងរបស់ *Akayesu* អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ជាការអាចឱ្យទទួលយកបានក្នុងការដែលកាត់ក្ដីជនជាប់ចោទឱ្យមានទោសលើបទល្មើសចំនួនពីរទាក់ទងទៅនឹងឈុតនៃអង្គហេតុតែមួយជាមួយគ្នាក្នុងកាលៈទេសៈដូចខាងក្រោមនេះ៖ ទី១) បើសិនជាបទល្មើសទាំងនោះមានធាតុផ្សំបទល្មើសផ្សេងពីគ្នា ទី២) បើសិនជាបទបញ្ញត្តិ ដែលបង្កើតនូវបទល្មើសទាំងនោះការពារឱ្យផលប្រយោជន៍ផ្សេងៗពីគ្នា ឬទី៣) បើសិនជាមានការចាំបាច់ត្រូវធ្វើជាកំណត់ហេតុអំពីការកាត់ឱ្យមានទោសពីបទល្មើសទាំងពីរដើម្បីឱ្យរៀបរាប់ឱ្យបានពេញលេញថាតើជនជាប់ចោទបានធ្វើអ្វីខ្លះ?[288]។

១៧៦- ទោះបីជាចាប់តាំងពីពេលនោះមកតុលាការអន្តរជាតិនានាបានអនុម័តយកតាម "ការពិសោធន៍សាកល្បងនៅក្នុងករណីរឿងរបស់ *Čelebici*" នោះក្ដី ក៏កត្តានានានៅក្នុងករណីរឿងក្ដីរបស់ *Akayesu* នៅតែមានការជាប់ជំពាក់ទាំងស្រុងទៅនឹងការចោទសួរអំពីភាពត្រឹមត្រូវនៃការផ្ដន្ទាទោសត្រួតដែរ។

---

[288] សាលក្រមអង្គជំនុំជម្រះសាលាដំបូងបណ្ដឹងឧទ្ធរណ៍លើករណីរឿងរបស់ *Akayesu* កថាខណ្ឌទី ៤៦៨។

### ង.២.៥.២ សាលក្រមគួរតែបានរៀបរាប់ឱ្យឃើញសព្វគ្រប់ទាំងអស់អំពីឧក្រិដ្ឋភាពរបស់ចុងបណ្តឹងសាទុក្ខ

១៧៧- មតិជំទាស់របស់លោកចៅក្រម Schomburg និងលោកចៅក្រម Güney ដែលអង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែកដើម្បីគាំទ្រដីកាសម្រេចផ្តន្ទាទោសរបស់ខ្លួន[289] នោះគឺការដែលគួរឱ្យកត់សំគាល់នោះគឺការទទួលស្គាល់ថា "ការកាត់ឱ្យជាប់ទោសពីបទល្មើសច្រើនមុខគឺជាការបំរើឱ្យការរៀបរាប់អំពីពិរុទ្ធភាពទាំងមូលទាំងស្រុងរបស់ជនជាប់ចោទដោយឡែកណាម្នាក់ ឬជាការផ្តល់នូវរូបភាពយ៉ាងពេញលេញទាំងស្រុងមួយស្តីពីការប្រព្រឹត្តិបទឧក្រិដ្ឋរបស់ជននោះ"[290]។

១៧៨- អង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី *Kordic* បានកត់សំគត់ថាឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិស្តីពីការធ្វើទុក្ខបុកម្នេញពុំដែលធ្លាប់មានការកំណត់និយមន័យយ៉ាងល្អិតល្អន់ទាល់តែសោះ[291]។

១៧៩- អាស្រ័យហេតុនេះ ការស្រូបទោសពីបទឧក្រិដ្ឋចំនួន៧ផ្សេងពីគ្នា ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបញ្ចូលគ្នាមកនៅត្រឹមបទធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតែមួយគត់នោះគឺវាទូលំទូលាយពេកហើយដែលមិនអាចអនុញ្ញាតអោយបានទេ និងជាការខកខានក្នុងការបង្ហាញឱ្យឃើញពីរូបភាពទាំងស្រុងនៃឧក្រិដ្ឋភាពរបស់ចុងបណ្តឹងសាទុក្ខទៀតផង ។

### ង.២.៥.៣ ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នីមួយៗសុទ្ធតែការពារនូវតម្លៃជាមូលដ្ឋានណាមួយ

---

[289] ករណីរឿងសាលក្រម, កថាខណ្ឌទី៥៦០, ៥៦៥។

[290] *ករណីរឿងរបស់ Kordić និង Čerkez*, សាលដីកាលើបណ្តឹងឧទ្ធរណ៍, មតិជំទាស់រួមរបស់លោកចៅក្រម Schomburg និងលោកចៅក្រម Güney ស្តីពីការផ្តន្ទាទោសត្រួត, កថាខណ្ឌទី២។ ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា ទល់នឹង Kunarac*, សាលដីកា,សំណុំរឿងលេខ IT-96-23 និង IT-96-23/I-A, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY, ចុះថ្ងៃទី១២ មិថុនា ២០០២, ("សាលដីកាលើបណ្តឹងលើទ្ធរណ៍ករណី *Kunarac*"), កថាខណ្ឌទី ១៦៩។

[291] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Kordić*, សាលក្រម, សំណុំរឿងលេខ IT-95-14/2-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី២៦ កុម្ភៈ ២០០១, ("សាលក្រមលើករណីរឿងរបស់ *Kordić* "), កថាខណ្ឌទី ១៩២។

១៨០- ការកំណត់ពីអត្តសញ្ញាណនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មជាដើមអាទិ៍ ដែលក្រោយមកការក្តីកាត់ឱ្យមានទោសពីបទធ្វើទុក្ខបុកម្នេញបានពឹងផ្អែកជាមូលដ្ឋាននេះ គឺមិនមានប្រសិទ្ធភាពឡើយ។ នោះគឺជាការទទួលស្គាល់ចំពោះការរំលោភបំពាន និងការពារចំពោះតម្លៃជាមូលដ្ឋាននីមួយៗដែលត្រូវបានរំលោភបំពានដែលបានស្តែងចេញតាមរូបភាពជាការផ្តន្ទាទោសទោសត្រួតនេះហើយ ដែលវាគ្រប់គ្រាន់បំផុតបង្ហាញពីការទទួលស្គាល់អំពីការខុសឆ្គង ។

១៨១- មតិជំទាស់ដោយផ្នែកៗរបស់លោកចៅក្រម Shahabuddeen នៅក្នុងករណីរឿងក្តីរបស់ *Jelisic* បានផ្តល់ការគាំទ្រយ៉ាងខ្លាំងដល់ការផ្តន្ទាទោសត្រួតនៅក្នុងករណីរឿងក្តីបច្ចុប្បន្ននេះ។ លោកថ្លែងថា

> "ក្រោយពីអ្វីមួយត្រូវបានយល់ព្រមថាជាធាតុផ្សំនៃបទល្មើសហើយនោះ [...] ធាតុផ្សំនោះតុលាការតោងតែមានភារកិច្ចយកចិត្តទុកដាក់ចំពោះធាតុផ្សំនោះ ក្នុងការធ្វើការប្រៀបធៀបណាមួយជាមួយធាតុផ្សំផ្សេងៗដើម្បីគោលបំណងធ្វើការកំណត់ថា តើការផ្តន្ទាទោសត្រួតអាចធ្វើបានទៅដែរឬទេ?។ គឺមានតែដំណើរការនីតិវិធីតាមបែបនេះតែប៉ុណ្ណោះទេទើបប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអាចយកចិត្តទុកដាក់ទៅលើរាល់ផលប្រយោជន៍សាធារណៈទាំងអស់ដែលមានគោលបំណងចង់ឱ្យការពារបាន។ ទោះបីជាការប្រព្រឹត្តិជាក់ស្តែងអាចតែមួយដូចគ្នាក៏ដោយ ក៏វាអាចធ្វើឱ្យខូចខាតដល់ផលប្រយោជន៍សាធារណៈដោយឡែកៗពីគ្នាបានដែរ។ អត្ថិភាពនៃភាពខុសគ្នានៃផលប្រយោជន៍សាធារណៈទាំងនេះអាចត្រូវបានផ្តល់ជាសញ្ញាឱ្យឃើញច្បាស់ដោយវត្តមាននៃធាតុផ្សំនានា ដែលមានលក្ខណៈពិសេសតែមួយគត់"[292]។

១៨២- ក្នុងករណីរឿងបច្ចុប្បន្ននេះ ឧក្រិដ្ឋកម្មនីមួយៗក្នុងចំណោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងប្រាំពីរ

---

[292] សាលដីកាបណ្តឹងឧទ្ធរណ៍លើករណីរឿងរបស់ *Jelick*, មតិជំទាស់ដោយដាច់ដោយឡែករបស់លោកចៅក្រម Shahabuddeen, កថាខណ្ឌទី៤១-៤២។

ដែលត្រូវបានស្រុបចូលគ្នាបានការពារនូវតម្លៃជាមូលដ្ឋានមួយដោយឡែកពីគេ ដែលត្រូវបានធ្វើឱ្យសឹករេចរិល (eroded by) ដោយការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងដែលមិនបានកាត់ក្តីឱ្យចុងបណ្តឹងសាទុក្ខមានទោសពីបទឧក្រិដ្ឋកម្មនីមួយៗក្នុងចំណោមឧក្រិដ្ឋកម្មទាំងឡាយដែលគាត់ត្រូវបានចោទប្រកាន់។

១៨៣- ការហាមឃាត់មិនឱ្យមានការធ្វើមនុស្សឃាត គឺជាការការពារនូវសិទ្ធិក្នុងការរស់រានមានជីវិត។ ដូចបានចែងនៅក្នុងមាត្រា៦ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”) មនុស្សគ្រប់ៗរូបគឺសុទ្ធតែមានសិទ្ធិរស់រានមានជីវិតជាប់មកជាមួយ។ សិទ្ធិនេះត្រូវបានការពារដោយច្បាប់។ គ្មានជនណាត្រូវបានគេដកហូតយកជីវិតរបស់ខ្លួនតាមទំនើងចិត្តឡើយ”[293]។

១៨៤- ការហាមឃាត់ មិនឱ្យមានការសម្លាប់រង្គាល បានការពារសិទ្ធិរស់រានមានជីវិតក៏ដូចជាសិទ្ធិរួចផុតពីលក្ខខណ្ឌនៃជីវិតដែលត្រូវបានបង្កើតឡើងដោយសិប្បនិម្មិតដែលមានភវនីយភាពក្នុងការបណ្តាលឱ្យស្លាប់[294]។ ការហាមឃាត់អំពើមនុស្សឃាតគឺមិនការពារផលប្រយោជន៍សាធារណៈរបស់សង្គមបន្ថែមនេះទេ[295] ។

១៨៥- ការហាមឃាត់មិនឱ្យមានការធ្វើឱ្យទៅជាទាសករ គឺការពារសិទ្ធដើម្បីឱ្យរួចផុតពីការធ្វើទាសកម្មជាបាវព្រាវ ឬពលកម្មដោយបង្ខំ។ មាត្រា៨ នៃ ICCPR ប្រកាសជាឧឡារិកថា: “គ្មានជនណាម្នាក់ត្រូវគេចាប់បង្ខំឱ្យធ្វើជាទាសករឡើយ គ្មានជនណាម្នាក់ត្រូវគេចាប់បង្ខំឱ្យធ្វើជាបាវព្រាវ គ្មានជនណាម្នាក់ត្រូវគេតម្រូវឱ្យធ្វើពលកម្មដោយបង្ខំ ឬដោយការចាប់បង្ខំឡើយ”[296] ។

---

293 ICCPR, មាត្រា៦។

294 សាលក្រម, កថាខណ្ឌទី ៣៣៨។

295 សាលក្រម, កថាខណ្ឌទី ៣៣១-៣៣៣។

296 ICCPR, មាត្រា៨។

00613556

E10



១៨៦- ការហាមឃាត់មិនឱ្យមានការដាក់នៅក្នុងមន្ទីរឃុំឃាំង គឺការពារសិទ្ធិដើម្បីឱ្យរួចផុតពីការដកហូតសេរីភាពតាមទំនើងចិត្តដោយមិនមានដំណើរការតាមនីតិវិធីត្រឹមត្រូវតាមច្បាប់។ តម្លៃជាមូលដ្ឋាននេះត្រូវបានចែងសង្ខេបនៅក្នុងICCPR ថា៖ "មនុស្សគ្រប់រូបមានសិទ្ធិត្រូវមានសេរីភាពនិងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវបានដាក់ឱ្យទទួលរងនូវការចាប់ខ្លួន ឬឃុំខ្លួនតាមទំនើងចិត្តឡើយ ។ គ្មានជនណាត្រូវគេដកហូតសេរីភាព លើកលែងតែក្នុងករណីដែលផ្អែកលើមូលហេតុ និងស្របតាមនីតិវិធីដែលត្រូវបានកំណត់ដោយច្បាប់"[297]។

១៨៧- ការហាមឃាត់មិនឱ្យមានការធ្វើទារុណកម្ម គឺការពារសិទ្ធិដើម្បីឱ្យរួចផុតពីការបង្កដោយចេតនាឱ្យមានការឈឺចាប់ ឬរងទុក្ខវេទនា។ តម្លៃជាមូលដ្ឋាននេះ ត្រូវបានចែងក្នុងមាត្រា៥ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងមាត្រា៧នៃ ICCPR ដែលទាំងពីរនេះបានចែងថា៖ "គ្មានជនណាត្រូវគេដាក់ឱ្យទទួលរងនូវការធ្វើទារុណកម្ម ឬប្រព្រឹត្តកម្មឃោរឃៅព្រៃផ្សៃ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្មឡើយ"[298]។

១៨៨- ការហាមឃាត់មិនឱ្យមានការរំលោភសេពសន្ថវៈ គឺការពារសិទ្ធិដើម្បីឱ្យបុគ្គលធ្វើការសម្រេចលើបញ្ហានានាទាក់ទងនឹងផ្លូវភេទរបស់ខ្លួន។ ការហាមឃាត់មិនឱ្យមានការរំលោភសេពសន្ថវៈក៏គឺជាការការពារនូវសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួនរបស់បុគ្គលដែរ[299]។ បើធ្វើឡើងសំដៅប្រឆាំងនឹងស្ត្រីភេទដូចជាក្នុងករណីរឿងបច្ចុប្បន្ននេះ គឺឧក្រិដ្ឋកម្មរំលោភសេពសន្ថវៈនោះវាល្មើសទៅនឹងអនុសញ្ញាស្តីពីការបំបាត់ចោលនូវរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ដែលការពារស្ត្រីប្រឆាំងនឹងអំពើ

---

[297] ICCPR, មាត្រា៩។

[298] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា៥, ICCPR មាត្រា៧។

[299] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Akayesu,* សាលក្រម, សំណុំរឿងលេខ ICTR-96-4-T, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២ កញ្ញា ១៩៩៨, ("សាលក្រមលើករណីរឿងរបស់ *Akayasu*"), កថាខណ្ឌទី៥៩៧។

ហិង្សាដោយសារមូលហេតុទាក់ទងនឹងភេទ[300]។

១៨៩- ការហាមឃាត់មិនអោយមានអំពោះអមនុស្សធម៌ផ្សេងៗទៀត គឺដើម្បីការពារសិទ្ធិក្នុងការមានបូរណភាពខាងរាងកាយ និងបញ្ញាស្មារតីខាងសុខភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស[301]។ ការរៀបរាប់តាម លំដាប់លំដោយនូវឧក្រិដ្ឋកម្មទាំងនេះនៅក្នុងធម្មនុញ្ញនៃតុលាការទីក្រុងនូរ៉ាំប៊ឺហ្គ[302] ក្នុងលក្ខន្តិកៈនៃតុលាការ ICTY[303] និងតុលាការ ICTR[304] ក៏ដូចជាក្នុងមាត្រា ៥ នៃច្បាប់ អវតក[305] គឺជាការឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់របស់សហគមន៍អន្តរជាតិ នៅក្នុងការការពារនូវសិទ្ធិជាមូលដ្ឋានទាំងនេះ ។

១៩០- ដូចដែលលោកចៅក្រម Shahabuddeen បានកត់សំគាល់នៅក្នុងមតិជំទាស់របស់គាត់នៅក្នុងករណីរឿងក្តីរបស់ *Jelisic* ថា៖"ការការពារឱ្យបានពេញលេញនូវផលប្រយោជន៍សង្គមដាច់ដោយឡែកពីគ្នាទាំងនេះ គឺចាំបាច់តម្រូវឱ្យមានការផ្តន្ទាទោសត្រួត"។ ដើម្បីកាត់ក្តីឱ្យជាប់ទោសពីបទឧក្រិដ្ឋតែមួយគត់ប៉ុណ្ណោះ គឺជាការទុកចោលដោយមិនបានឱ្យប្រាប់គេដឹងអំពីការខូចផលប្រយោជន៍ដទៃទៀតនៃសហគមន៍អន្តរជាតិ និងជាការខកខានមិនបានរៀបរាប់អំពីកំរិតពិតប្រាកដនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ"[306]។

---

300 *សូមអាន* អនុសាសន៍ទូទៅដែលធ្វើឡើងដោយគណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ, ដែលមានចំណងជើងថា អនុសាន៍ទូទៅ លេខ១៩។

301សៀវភៅរបាយការណ៍ប្រចាំរបស់គណៈកម្មការច្បាប់អន្តរជាតិ, ក្បាលទី II, ផ្នែកទី២, (របាយការណ៍របស់គណៈកម្មការជូនមហាសន្និបាត អសប ស្តីពីការងាររបស់ខ្លួនសម្រាប់សម័យប្រជុំលើកទី៤៨), មាត្រា១៨, កថាខណ្ឌទី១៧។

302ដំណើរការជំនុំជម្រះក្តីតុលាការទីក្រុងនូរ៉ាំប៊ឺហ្គ ធម្មនុញ្ញនៃតុលាការសឹកអន្តរជាតិ(ធម្មនុញ្ញនូរ៉ាំប៊ឺហ្គ),ចុះថ្ងៃទី៨ សីហា ១៩៤៥មាត្រា៦.គ។

303 លក្ខន្តិកៈតុលាការ ICTY, មាត្រា៥។

304 លក្ខន្តិកៈតុលាការ ICTY, មាត្រា៣។

305 ច្បាប់ អវតក, មាត្រា៥។

306 សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ករណីរឿងរបស់ *Jelicić*, មតិជំទាស់ដាច់ដោយឡែករបស់លោកចៅក្រម Shahabuddeen, កថាខណ្ឌទី ៤២។

## ង.២.៦ សេចក្ដីសន្និដ្ឋាន

១៩១- សហព្រះរាជអាជ្ញា សូមជូនជាសេចក្ដីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានមានការភាន់ច្រឡំ ដោយខកខានមិនបានកាត់ក្ដីឱ្យចុងបណ្ដឹងសាទុក្ខជាប់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនីមួយៗដែលជននេះត្រូវបានចោទប្រកាន់។ ហេតុដូចនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល ច្រានចោលនូវសាលក្រមដែលទាក់ទងទៅនឹងការផ្ដន្ទាទោសត្រួត ដោយសារមូលហេតុដូចតទៅនេះ៖ ទី១) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនីមួយៗដែលចុងបណ្ដឹងសាទុក្ខត្រូវបានចោទប្រកាន់ជាក់ស្ដែងគឺវាមានធាតុផ្សំបទល្មើសមួយខុសពីគេ ដែលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងទៀតមិនឃើញមានដូចនេះទេ ទី២) ការខកខាន របស់អង្គជំនុំជម្រះសាលាដំបូងដោយមិនបានកាត់ក្ដីឱ្យចុងបណ្ដឹងសាទុក្ខជាប់ទោសគ្រប់បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិទាំងអស់ដែលជននេះត្រូវបានចោទប្រកាន់ គឺជាការធ្វើឱ្យខូចដល់គោលដៅទាំងទ្វេរនៃការធ្វើល្បងពិសោធន៍ក្នុងការផ្ដន្ទាទោសត្រួត ទី៣) សនិទានភាព ដែលបានសំដែងនៅក្នុងមតិជំទាស់របស់លោកចៅក្រម Hunt និង Bennouna នៅក្នុងសាលដីកាសម្រេចលើបណ្ដឹងសាទុក្ខក្នុងករណីរឿងក្ដីរបស់ *Čelebići* ដែលមិនបានអនុញ្ញាតឱ្យផ្ដន្ទាទោសត្រួតដែលក្នុងករណីរឿងក្ដីនេះមិនអាចយកមកអនុវត្តបានឡើយ និងទី៤) អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិនិត្យឱ្យបានសព្វជ្រុងជ្រោយអំពីផលប្រយោជន៍សាធារណៈដែលត្រូវបានការពារដោយច្បាប់ប្រឆាំងនឹងឧក្រិដ្ឋកម្មនីមួយៗ ដូចដែលបានរៀបរាប់តាមលំដាប់លំដោយ និងថាតើចាំបាច់ត្រូវរៀបរាប់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្ម របស់ចុងបណ្ដឹងសាទុក្ខឱ្យបានពេញលេញជាងនេះដែរឬទេ? ដើម្បីជាប្រយោជន៍ដល់កូនចៅជំនាន់ក្រោយ និងឯកសារប្រវត្តិសាស្ត្ររបស់តុលាការនេះ ។

00613559



## ង.៣ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ប្រភេទបទល្មើសដោយមិនត្រឹមត្រូវចំពោះបទរំលោភសេពសន្ថវៈ ថាជាអំពើទារុណកម្ម ដែលមានក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

### ង.៣.១ សេចក្តីផ្តើម

១៩២- អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ចុងបណ្តឹងសាទុក្ខមានទោសពីបទធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ ដែលត្រូវបានស្រូបចូលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរំលោភសេពសន្ថវៈ[307]។ អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំផ្នែកអង្គច្បាប់ក្នុងការកំណត់បទចោទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរំលោភសេពសន្ថវៈ ថាជាបទការធ្វើទារុណកម្មទៅវិញ ហើយដោយខកខានមិនបានកាត់ក្តី ចុងបណ្តឹងសាទុក្ខមានទោសពីបទ រំលោភសេពសន្ថវៈដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយឡែកមួយផ្សេងនោះទេ ។

### ង.៣.២ ការរំលោភសេពសន្ថវៈ ថាជាការធ្វើទារុណកម្ម

១៩៣- តាមយុត្តិសាស្ត្រអន្តរជាតិ ការរំលោភសេពសន្ថវៈ អាចបង្កើតបានទៅជាទម្រង់មួយនៃការធ្វើទារុណកម្ម "ដូចគ្នានឹងការធ្វើទារុណកម្មដែរ ការរំលោភសេពសន្ថវៈត្រូវបានគេប្រើសម្រាប់គោលបំណងតួយ៉ាងដូចជា ការបំភិតបំភ័យ ការបន្ទាបបន្ថោក ការធ្វើឱ្យអាម៉ាសមុខ ការប្រកាន់រើសអើង ការដាក់ទណ្ឌកម្ម ការគ្រួតពិនិត្យ ឬបផ្លិចបំផ្លាញជនណាម្នាក់ ។ ដូចគ្នានឹងការធ្វើទារុណកម្មដែរ ការរំលោភសេពសន្ថវៈគឺជាការរំលោភបំពានទៅលើសេចក្តីថ្លៃថ្នូររបស់បុគ្គល ហើយតាមពិតការរំលោភសេពសន្ថវៈបង្កើតបានទៅជាការធ្វើទារុណកម្មនៅពេលដែលបង្កឡើងដោយ ឬតាមការញុះញង់ ឬដោយមានការយល់ព្រមឬដោយស្រុះស្រួលពីមន្ត្រីផ្លូវការសាធារណៈ ឬពីជនផ្សេងទៀត

[307] សាលក្រម, កថាខណ្ឌទី ២៤៦,៣៦៦, ៦៧៧។

ដែលធ្វើសកម្មភាពក្នុងតួនាទីជាផ្លូវការ"[308]។

១៩៤- នៅក្នុងករណីរឿងក្តីរបស់ *Delalic* តុលាការ ICTY បានចាត់ទុកថា "នៅពេលណាដែលការរំលោភសេពសន្ថវៈនិងទម្រង់ផ្សេងៗទៀត នៃអំពើហិង្សាផ្លូវភេទបំពេញបានគ្រប់គ្រាន់ទៅតាមលក្ខណៈវិនិច្ឆ័យដែលលើកឡើងពីខាងដើមហើយនោះ បន្ទាប់មកក៏បង្កើតបានទៅជាការធ្វើទារុណកម្មក្នុងរបៀបដូចគ្នានឹងអំពើណាមួយផ្សេងទៀត ដែលបំពេញគ្រប់តាមលក្ខណៈវិនិច្ឆ័យនេះដែរ"[309]។ នៅក្នុងករណីរឿងក្តីរបស់ *Furundžija,* តុលាការ ICTY បានសម្រេចថា "[ការធ្វើទារុណកម្ម] អាចកើតមានឡើងតាមរូបភាពផ្សេងៗជាច្រើន]" និងថា "ករណីយុត្តិសាស្ត្រ នៃតុលាការអន្តរជាតិ និងរបាយការណ៍នានា របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបង្ហាញឲ្យឃើញច្បាស់ពីកម្លាំងចលករមួយសំដៅទៅរកដោះស្រាយ តាមរយៈដំណើរការនីតិវិធីតាមផ្លូវតុលាការនូវការរំលោភសេពសន្ថវៈ ក្នុងអម្លុងពេលនៃការជាប់ឃុំឃាំង និងសួរចម្លើយធ្វើជាមធ្យោបាយមួយនៃការធ្វើទារុណកម្ម ដែលហេតុដូចនេះគឺជាការរំលោភបំពានលើច្បាប់អន្តរជាតិ"[310]។ តុលាការបានរកឃើញថា "ការរំលោភសេពសន្ថវៈអាចស្មើនឹងការធ្វើទារុណកម្ម និងដែលត្រូវបានរកឃើញដោយស្ថាប័នតុលាការអន្តរជាតិនានាថា គឺបង្កើតបានទៅជាការរំលោភមួយទៅលើបទដ្ឋានដែលហាមឃាត់ការធ្វើទារុណកម្មនេះ"[311]។ ក៏ប៉ុន្តែការពិនិត្យអំពីទំនាក់ទំនងរវាងការរំលោភសេពសន្ថវៈហើយការធ្វើទារុណកម្ម អង្គជំនុំជម្រះលើករណីរបស់ *Furundžija បានសន្និដ្ឋានថាៈ "អាស្រ័យ*

---

[308] សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើករណីរបស់ Akayesu, កថាខណ្ឌទី ៥៩៧, ៦៨៧។

[309] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Delalić,* សាលក្រម, សំណុំរឿងលេខ IT-96-21-T, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៦ វិច្ឆិកា ១៩៩៨, ("សាលក្រមលើករណីរឿងរបស់ *Delalić* "), កថាខណ្ឌទី ៤៩៦។

[310] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Furundžija,* សាលក្រម, សំណុំរឿងលេខ IT-95-17/1-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី១០ ធ្នូ ១៩៩៨, ("សាលក្រមលើករណីរឿងរបស់ *Furundžija* "), កថាខណ្ឌទី ១៦៣។

[311] សាលក្រមលើករណីរឿងរបស់ *Furundžija,* កថាខណ្ឌទី ១៦៣។

*ទៅលើកាលៈទេសៈនៅក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺការរំលោភសេពសន្ថវៈអាចនឹងទទួលបាននូវឋានៈជាឧក្រិដ្ឋកម្មមួយដែលផ្សេងដាច់ដោយឡែកពីការធ្វើទារុណកម្ម*”[312] ។

១៩៥- នៅក្នុងករណីរឿងក្តីរបស់ *Kvočka*, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានរកឃើញថា: “ករណីយុត្តិសាស្ត្រនៃតុលាការនានា ដែលស្របគ្នាជាមួយយុត្តិសាស្ត្ររបស់ស្ថាប័នសិទ្ធិមនុស្សផ្សេងៗ បានសម្រេចថា ការរំលោភសេពសន្ថវៈអាចបង្កើតបាននូវការឈឺចាប់និងរងទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរដែលស្មើនឹងការធ្វើទារុណកម្ម លុះត្រាតែធាតុផ្សំនៃបទល្មើសផ្សេងៗទៀតនៃការរំលោភសេពសន្ថវៈ ដូចជាគោលបំណងនៃការហាមឃាត់ណាមួយ ត្រូវបានបំពេញគ្រប់គ្រាន់”[313] ។ ស្រដៀងគ្នានេះដែរ នៅក្នុងករណីរឿងក្តីរបស់ *Kunarac* តុលាការជាន់ខ្ពស់នៃតុលាការ ICTY បានសម្រេចថា: “ការឈឺចាប់ខាងផ្លូវកាយ ការភ័យខ្លាច ការឈឺចុកចាប់ខាងផ្លូវអារម្មណ៍ ភាពមិនច្បាស់លាស់ និងការធ្វើឱ្យអាម៉ាស់ ដែលដើមបណ្តឹងសាទុក្ខបានដាក់ឱ្យជនរងគ្រោះ របស់ខ្លួនទទួលរងដដែលៗ ម្តងហើយម្តងទៀត នឹងតម្លើងនូវអំពើរបស់ពួកគេឱ្យស្មើនឹងអំពើនៃការធ្វើទារុណកម្ម”[314] ។

### ង.៣.៣ ការរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មដាច់ដោយឡែកពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

១៩៦- ថ្វីត្បិតតែយុត្តិសាស្ត្រដែលថា អំពើនៃការរំលោភសេពសន្ថវៈអាចស្មើនឹងឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្មនោះក្តី ក៏តុលាការអន្តរជាតិនានាកំណត់ប្រភេទបទល្មើសការរំលោភសេពសន្ថវៈដោយ ស្របគ្នាថាគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដែលផ្សេងដាច់ដោយឡែកពីការធ្វើទារុណកម្ម ទោះបីជា

---

312 សាលក្រមលើករណីរឿងរបស់ *Furundžija*, កថាខណ្ឌទី ១៦៤។

313 *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Kvočka*, សាលក្រម, សំណុំរឿងលេខ IT-98-30/1-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី២ វិច្ឆិកា ២០០១, កថាខណ្ឌទី ១៤៥។

314 សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់ *Kunarac*, កថាខណ្ឌទី ១៨៥ ។

អំពើឧក្រិដ្ឋកម្មដែលនេះ ស្មើគ្នាទៅនឹងទាំងការរំលោភសេពសន្ថវៈផង និងការធ្វើទារុណកម្មផងក៏ដោយ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ការរំលោភសេពសន្ថវៈបង្កើតបានទៅជាបទល្មើសដាច់ដោយឡែកនិងដែលត្រូវបានគេទទួលស្គាល់ទាំងនៅក្នុង អ.វ.ត.ក និងទាំងដោយច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[315] និងថា "ការរំលោភសេពសន្ថវៈត្រូវបានគេហាមឃាត់ តាំងពីយូរណាស់មកហើយនៅក្នុងច្បាប់ទម្លាប់អន្តរជាតិ និងដែលត្រូវបានគេពិពណ៌នាថា'គឺជាការឈឺចាប់ដ៏អាក្រក់ជាងគេបំផុតមួយក្នុងចំណោមការឈឺចាប់នានាដែលមនុស្សអាចបង្កទៅលើមនុស្សម្នាក់ផ្សេងទៀត"[316]។

១៩៧- ក្នុងករណីរឿងក្តីរបស់ *Akayesu* តុលាការ ICTR បានកាត់ក្តីជនជាប់ចោទពីឧក្រិដ្ឋកម្មល្មួចលាក់ប្រឆាំងនឹងមនុស្សជាតិរំលោភសេពសន្ថវៈ ដែលក្នុងនោះមានការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈជាច្រើនលើកក៏ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទការធ្វើទារុណកម្ម ព្រមទាំងអំពើអមនុស្សធម៌ផ្សេងទៀតនៅក្នុងការប្រព្រឹត្តិដទៃទៀត[317]។ មានករណីរឿងបន្តបន្ទាប់ជាច្រើនទៀតបានធ្វើតាមវិធីសាស្ត្រនេះ។ នៅក្នុងករណីរឿងរបស់ *Kunarac* អង្គជំនុំជម្រះសាលាដំបូងនៃ តុលាការ ICTY បានកាត់ក្តីឲ្យជនជាប់ចោទពីរក្នុងចំណោមបីនាក់មានទោសទាំងបទធ្វើទារុណកម្មផង និងពីរំលោភសេពសន្ថវៈផងដែលសុទ្ធតែជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការប្រព្រឹត្តិតែមួយជា

---

[315] សាលក្រម, កថាខណ្ឌទី ៣៦៦។

[316] សាលក្រម, កថាខណ្ឌទី៣៦១ (ដែលលើកសំអាងលើ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Kunarac,* សាលក្រម, សំណុំរឿងលេខ IT-95-23-T និង IT-96-23/1-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី២២ កុម្ភៈ ២០០១, ("សាលក្រមលើករណីរឿងរបស់ *Kunarac*"), កថាខណ្ឌទី ៦៥៥។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Sesay,* សាលក្រម, សំណុំរឿងលេខ SCSL-04-15-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ SCSL, ចុះថ្ងៃទី២ មីនា ២០០៩, ("សាលក្រមលើករណីរឿងរបស់ *Sesay* "), កថាខណ្ឌទី ១៤៤។ ក្រុមប្រឹក្សាត្រួតពិនិត្យ, ច្បាប់លេខ ១០, ស្តីពីការផ្តន្ទាទោសជនទាំងឡាយដែលមានទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ("ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ"), ឆ្នាំ១៩៤៥, មាត្រាII.១.គ ។ សណ្តាប់ធ្នាប់ទូទៅ ១០០៖ ក្រម Lieber, សេចក្តីណែនាំសម្រាប់ការគ្រប់គ្រងកងទ័ពនានានៃសហរដ្ឋអាមេរិកនៅក្នុងសមរភូមិ, ចុះថ្ងៃទី២៤ មេសា ១៨៦៣, មាត្រា៤៤។ អនុសញ្ញានៃទីក្រុងហ្សឺណែវ (ទី IV) ដែលទាក់ទងនឹងការការពារជនស៊ីវិលនៅក្នុងកាលៈទេសៈសង្គ្រាម, ចុះថ្ងៃទី១២ សីហា ១៩៤៩, មាត្រា២៧

[317] សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើករណីរបស់ *Akayesu*, កថាខណ្ឌទី ៦៩៦។

មួយគ្នា(នោះគឺជាអំពើរំលោភផ្លូវភេទ)[318]។ ជាងនេះទៅទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក្នុងករណីរឿងជាមួយគ្នាដដែលនេះបានសម្រេចថា ការចាត់ ទុករបស់ខ្លួននូវការរំលោភសេពសន្ថវៈ និងការធ្វើទារុណកម្មថាជាអំពើបំពារបំពានធ្ងន់ធ្ងរទៅលើ អនុសញ្ញានានានៃទីក្រុងហ្សឺណែវនោះក៏ត្រូវបានយកមកអនុវត្តចំពោះឧក្រិដ្ឋកម្មរំលោភសេពសន្ថវៈ និងធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ[319] ។ ស្រដៀងគ្នានេះដែរ ក្នុង ករណីរឿងក្តីរបស់ *Furundzija,* តុលាការICTY បានកាត់ក្តីឱ្យជនជាប់ចោទមានទោសទាំងបទ ការធ្វើទារុណកម្មផង និងការបំពានលើសេចក្តីថ្លៃថ្នូររបស់បុគ្គលផង ដែលរួមទាំងការរំលោភ សេពសន្ថវៈដែលជាអំពើបំពារបំពានទៅលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវក្នុងនោះផងទាក់ទង ទៅនឹងការប្រព្រឹត្តតែមួយដដែល(នោះគឺជាអំពើរំលោភសេពសន្ថវៈជាច្រើនលើក)[320]។ នៅក្នុងករណីរឿងក្តីរបស់*Semanza* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានកាត់ក្តីឱ្យជនជាប់ចោទមានទោសទាំងបទញុះញង់ឱ្យមានការរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងនិង ការញុះញង់ឱ្យមានការធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិផងទាក់ទងនឹងការប្រព្រឹត្តិតែមួយជាមួយគ្នា[321]។ ករណីរឿងទាំងនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ការអនុវត្តរបស់តុលាការអន្តរជាតិនានាគឺគេមិនបានស្រូបបញ្ចូលទោសនៃបទ ឧក្រិដ្ឋកម្មរំលោភសេពសន្ថវៈបញ្ចូលទៅក្នុងឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្មនោះឡើយ ក៏ប៉ុន្តែផ្ទុយទៅវិញ គឺគេបានកាត់ឱ្យជនជាប់ចោទឱ្យជាប់ទោសពីបទរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មលួចលាក់ ចំពោះការប្រព្រឹត្តដែលបង្កើតទៅជា

---

[318] សាលក្រមលើករណីរឿងរបស់ *Kunarac*", កថាខណ្ឌទី ៦៨៦-៦៨៧, ៧១៥, ៨២២។

[319] សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់ *Kunarac,* កថាខណ្ឌទី១៨៩ ។

[320] សាលក្រមលើករណីរឿងរបស់ *Furundžija,* កថាខណ្ឌទី ២៦៩, ២៧៥។

[321] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Semanza,* សាលក្រម និងការសំរេចផ្តន្ទាទោស, សំណុំរឿងលេខ ICTR-97-20-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR, ចុះថ្ងៃទី១៥ ឧសភា ២០០៣, កថាខណ្ឌទី ៤៧៥-៤៨៨, ៥៨៨។

ការរំលោភសេពសន្ថវៈដែលជាឧក្រិដ្ឋកម្មអន្តរជាតិទៅវិញ ដែលការធ្វើដូចនេះគឺជាការផ្ទុះបញ្ចាំងយ៉ាងពេញលេញទាំងស្រុងអំពីស្ថានទម្ងន់នៃការប្រព្រឹត្ត។

១៩៨- នៅក្នុងករណីរបស់ *Akayesu* តុលាការ ICTR បានចាត់ថ្នាក់នូវអំពើមួយដែលស្រដៀងគ្នាមែនទែនទៅនឹងអំពើដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការរំលោភសេពសន្ថវៈ "អំពើណាមួយដូចដែលបានរៀបរាប់ដោយសាក្សី KK នៅក្នុងសក្ខីកម្មរបស់គាត់-ពួកអោរវជន Interahamwes បានយកឈើបុកចូលទៅក្នុងប្រដាប់ភេទរបស់ស្ត្រីម្នាក់នៅពេលដែលនាងដួលដេករកកលនឹងស្លាប់-បង្កើតបានជាការរំលោភសេពសន្ថវៈនៅក្នុងទស្សនៈរបស់តុលាការ"[322]។ ចុងបណ្តឹងសាទុក្ខបានផ្តល់សក្ខីកម្មថា សមាជិកម្នាក់នៃមន្ទីរស-២១ បានយកឈើដាក់ចូលទៅក្នុងប្រដាប់ភេទរបស់អ្នកជាប់ឃុំឃាំងម្នាក់នៅក្នុងពេលសួរចម្លើយ[323] ។ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថាភស្តុតាងដែលបានគាំទ្រដល់បទចោទពីការរំលោភសេពសន្ថវៈនោះគឺគួរឱ្យជឿជាក់បាន[324] ហើយបានយល់ឃើញថា "ករណីរំលោភសេពសន្ថវៈនេះ បង្កើតឱ្យមាននូវភាពធ្ងន់ធ្ងរនៃការធ្វើទារុណកម្មរយៈពេលយូរ និងមានភាពព្រៃផ្សៃ [ទៅលើជនរងគ្រោះ...]"[325] ។ អាស្រ័យហេតុដូច្នេះ វាពុំមានមន្ទិលសង្ស័យអ្វីទៀតឡើយដែលថា យោងទៅតាមយុត្តិសាស្ត្រអន្តរជាតិដែលបានដោះស្រាយរួច ហើយនោះ អំពើនេះនៅក្នុងមន្ទីរស-២១ គួរតែត្រូវបានចាត់ទុកថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការរំលោភសេពសន្ថវៈដ៏អាថ៌កំបាំង ។

---

[322] សាលក្រមលើករណីរបស់ *Akayesu*, , កថាខណ្ឌទី ៦៨៦ ។

[323] គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសង, ថ្ងៃទី៣០ មករា ២០០៩, E5/11/6.1, កថាខណ្ឌ ២៣១។ ប្រតិចារឹក, កាំង ហ្គេកអ៊ាវ ហៅ ឌុច, ថ្ងៃទី២៣ មេសា ២០០៩, T.35 ។

[324] សាលក្រម, កថាខណ្ឌទី ៣៦៦ ។

[325] សាលក្រម, កថាខណ្ឌទី ៣៦៦ ។

១៩៩- អង្គជំនុំជម្រះសាលាដំបូង បានទទួលស្គាល់ថា "ករណីភាគច្រើននៃការរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានប្រព្រឹត្តឡើងដោយបង្ខំដែលផ្ទុយពីឆន្ទៈពិតប្រាកដរបស់ជនរងគ្រោះ"[326] ដូចដែលបានកើតឡើងនៅទីនេះ ខណៈដែលជនរងគ្រោះដែលជាប់ឃុំឃាំងត្រូវបានគេសួរចម្លើយនៅមន្ទីរស-២១ ។ អង្គជំនុំជម្រះសាលាដំបូង "យល់ឃើញថា អង្គហេតុនេះ មានភស្តុតាងបញ្ជាក់តាមបទដ្ឋានតម្រូវពិតប្រាកដមែន"[327] ហើយថាអំពើដែលបានលើកឡើងចោទប្រកាន់នោះ"បានបំពេញយ៉ាងច្បាស់លាស់នូវធាតុផ្សំផ្លូវច្បាប់ ទាំងបទល្មើសការរំលោភសេពសន្ថវៈ និងការធ្វើទារុណកម្ម"[328]។ បើតាមភាពសាហាវយង់ឃ្នង និងលក្ខណៈបង្ខិតបង្ខំនៃអំពើនេះ អង្គជំនុំជម្រះសាលាដំបូង មានកំហុសនៅក្នុងការដែលពុំបានធ្វើការវិនិច្ឆ័យសេចក្ដីទៅតាមការរកឃើញរបស់ខ្លួន និងពុំបានធ្វើការកាត់ទោសចុងបណ្ដឹងសាទុក្ខពីបទរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយដាច់ដោយឡែកទេ ។

## ង.៣.៤ សេចក្ដីសន្និដ្ឋាន

២០០- សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងផ្នែកច្បាប់ដោយធ្វើការស្រូបបទល្មើស នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្ដីពីការរំលោភសេពសន្ថវៈ ចូលទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្ដីពីការធ្វើទារុណកម្ម ហើយបានចាត់ទុក ការរំលោភសេពសន្ថវៈ ថាជាការធ្វើទារុណកម្ម ។ សហព្រះរាជអាជ្ញាសូមស្នើឲ្យ អង្គជំនុំជម្រះតុលាការកំពូលទទួលយកនូវទឡ្ហីករណ៍នេះ ហើយធ្វើការកាត់ទោសចុងបណ្ដឹងសាទុក្ខពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការរំលោភសេពសន្ថវៈដ៏អាថ៌កំបាំងនេះ ។

---

[326] សាលក្រម, កថាខណ្ឌទី ៣៦៣ ។

[327] សាលក្រម, កថាខណ្ឌទី ២៤៦ ។

[328] សាលក្រម, កថាខណ្ឌទី ៣៦៦ ។

## ច. ឧទ្ធរណ៍ទី៣៖ ចុងបណ្ដឹងសាទុក្ខគួរតែត្រូវបានផ្ដន្ទាទោសពីបទការធ្វើឲ្យទៅជាទាសករ លើអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១

### ច១. ទិដ្ឋភាពរួម

២០១- សាលក្រមបានរកឃើញថា ចុងបណ្ដឹងសាទុក្ខមានពិរុទ្ធភាពពីបទការធ្វើឲ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៅ "លើអ្នកជាប់ឃុំនៅស-២៤ និងក្រុមអ្នកជាប់ឃុំមួយចំនួនទៀត [ដែលត្រូវបានចាត់តាំងឲ្យទៅធ្វើការ]នៅក្នុងមន្ទីរស-២១"[329]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុស ខាងផ្នែកច្បាប់នៅក្នុងនិយមន័យរបស់ខ្លួនទៅលើពាក្យការធ្វើឲ្យទៅជាទាសករ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ការធ្វើឲ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានគេឲ្យនិយមន័យថាជា "ការអនុវត្តនូវអំណាចណាមួយ ឬទាំងអស់ ដែលភ្ជាប់ទៅនឹងសិទ្ធិលើកម្មសិទ្ធិទៅលើបុគ្គលណាមួយ"[330]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ខុសថាធាតុផ្សំនៃពលកម្មដោយបង្ខំចូលទៅក្នុងនិយមន័យនៃការធ្វើឲ្យទៅជាទាសករ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[331]។

### ច.២ អង្គជំនុំជម្រះសាលាដំបូង បានកំណត់ដោយខុសឆ្គងថា ពលកម្មដោយបង្ខំគឺជាធាតុផ្សំដ៏សំខាន់នៅក្នុងឧក្រិដ្ឋកម្មស្ដីពីការធ្វើឲ្យទៅជាទាសករ

២០២- អង្គជំនុំជម្រះសាលាដំបូងបានឲ្យនិយមន័យលើពាក្យការធ្វើឲ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តម្រូវឲ្យមានធាតុផ្សំមួយនៃពលកម្មដោយបង្ខំ[332] ។ សាលក្រមបានបញ្ជាក់ថា

---

[329] សាលក្រម, កថាខណ្ឌទី ៣៤៦, ៦៧៧ ។

[330] សាលក្រមលើករណីរបស់ *Kunarac*, កថាខណ្ឌទី ៥៣៩ ។

[331] សាលក្រម, កថាខណ្ឌទី ៣៤៦ ។

[332] សាលក្រម, កថាខណ្ឌទី ៣៤៦ ។

ការធ្វើឱ្យទៅជាទាសករតម្រូវឱ្យមាន "ពលកម្មដោយបង្ខំ ឬមិនមានការស្ម័គ្រចិត្ត ដែលបូករួមជាមួយនឹងការឃុំខ្លួន[...]"[333] ។ យ៉ាងដូច្នេះហើយបានជាគេរកឃើញថា ការធ្វើឱ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ ត្រូវបានបង្កើតឡើងដោយសារតែមាន "អ្នកជាប់ឃុំនៅស-២៤ និងក្រុមអ្នកជាប់ឃុំមួយចំនួនទៀត[ដែលត្រូវបានចាត់តាំងឱ្យទៅធ្វើការ]នៅក្នុងមន្ទីរស-២១""[334] ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានមានកំហុសខាងផ្នែកច្បាប់នៅក្នុងការប្រើប្រាស់ និយមន័យដែលមានកំរិតចង្អៀតលើពាក្យការធ្វើឱ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

២០៣- និយមន័យនៃពាក្យការធ្វើឱ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានមូលដ្ឋាននៅលើនិយមន័យនៃពាក្យ ទាសភាពក្នុងអនុសញ្ញាស្តីពីទាសភាពឆ្នាំ១៩២៦[335]។ និយមន័យនេះ ត្រូវបានបញ្ជាក់អះអាងឡើងវិញនៅក្នុងអនុសញ្ញាបន្ថែមស្តីពីទាសភាពឆ្នាំ១៩៥៦[336]។ ការធ្វើឱ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានដាក់បញ្ចូលទៅក្នុងធម្មនុញ្ញនូរឹមប៊ែរ (Nuremberg Charter)[337] និងធម្មនុញ្ញទីក្រុងតូក្យូ (Tokyo Charter)[338] ក៏ដូចជានៅក្នុងច្បាប់ស្តីពី

---

[333] សាលក្រម, កថាខណ្ឌទី ៣៤៦ ។

[334] សាលក្រម, កថាខណ្ឌទី ៣៤៦ ។

[335] អនុសញ្ញាស្តីពីទាសភាព, ថ្ងៃទី២៥ កញ្ញា ១៩២៦, មាត្រា ១.១ (ដែលផ្តល់និយមន័យដល់ ទាសភាព ថាជា: "ស្ថានភាព ឬលក្ខខណ្ឌរបស់បុគ្គល ម្នាក់ដែលអំណាចណាមួយ ឬគ្រប់អំណាចទាំងអស់ភ្ជាប់ទៅនឹងសិទ្ធិលើកម្មសិទ្ធិ ត្រូវបានអនុវត្តទៅលើគាត់") ។

[336] អនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ទាសភាព, ការជួញដូរទាសករ ហើយនិង ស្ថាប័ននិងការអនុវត្តដែលស្រដៀងគ្នាទៅនឹងទាសភាព, ថ្ងៃទី៣០ មេសា ១៩៥៧, មាត្រា ៧.ក (ដែលបានយោងទៅដល់និយមន័យនៃពាក្យ ទាសភាព នៅក្នុងអនុសញ្ញាស្តីពីទាសភាព និងបានផ្តល់និយមន័យដល់ពាក្យ "ទាសករ" ថាជា: បុគ្គលម្នាក់ដែលឋិតនៅក្នុងស្ថានភាព ឬលក្ខខណ្ឌបែបដូច្នោះ ដែលគ្រប់អំណាចភ្ជាប់ ទៅនឹងសិទ្ធិលើកម្មសិទ្ធិនានា ត្រូវបានអនុវត្តទៅលើគាត់") ។

[337] ធម្មនុញ្ញនូរឹមប៊ែរ, មាត្រា ៦.គ ("ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ: មានជាអាទិ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលត្រូវបានប្រព្រឹត្តទៅលើជនស៊ីវិលណាក៏ដោយ [...]") ។

[338] ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ាប្រទេស, ថ្ងៃទី១៩ មករា ១៩៤៦ ("ធម្មនុញ្ញទីក្រុងតូក្យូ"), មាត្រា ៥.គ (ឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ: មានជាអាទិ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗ ទៀត ដែលត្រូវបានប្រព្រឹត្តទៅលើជនស៊ីវិលណាក៏ដោយ [...]") ។

ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០[339]។ និយមន័យនៃពាក្យការធ្វើឱ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានវិវត្តឡើងគួរឱ្យកត់សម្គាល់នៅក្នុងករណីនានារបស់ *Milch* និង *Pohl*[340] នៅតុលាការនូរ៉ឹមប៊ែរ និងនៅក្នុងករណីរបស់ *Kunarac* នៅតុលាការ ICTY[341]។ យុត្តិសាស្ត្រអន្តរជាតិធ្លាប់បានបញ្ជាក់ថា ឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករបង្កើតបានជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិ[342] (customary international law)។ វាក៏ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមផងដែរ[343] ។

២០៤- តាមច្បាប់អន្តរជាតិ ការធ្វើឱ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបាន គេឱ្យនិយមន័យថាជា "ការអនុវត្តនូវអំណាចណាមួយ ឬទាំងអស់ ដែលភ្ជាប់ទៅនឹងសិទ្ធិលើកម្មសិទ្ធិទៅលើបុគ្គលណាមួយ"[344]។ តុលាការ ICTY បានរៀបរាប់ពីកត្តាមួយចំនួនដែលត្រូវពិចារណានៅក្នុងការសម្រេចថាតើអំពើរំលោភនោះបង្កើតបានជាការធ្វើឱ្យទៅជាទាសករពី "ការត្រួតត្រាលើចលនារបស់បុគ្គលណាម្នាក់, ការត្រួតត្រាលើបរិយាកាសរូបវ័ន្ត, ការត្រួតត្រាតាមផ្លូវចិត្ត, វិធានការនានា

---

[339] ច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យ, លេខ១០, មាត្រា II.១.គ ("ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ: អំពើសាហាវយង់ឃ្នង និងបទល្មើសនានា រួមមានក៏ប៉ុន្តែមិនកំណត់ត្រឹមតែ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ឬអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលត្រូវបានប្រព្រឹត្តទៅលើជនស៊ីវិលណាក៏ដោយ ឬការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ទោះបីជាមាន ឬពុំមានការរំលោភទៅលើច្បាប់ក្នុងប្រទេសដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបាន ប្រព្រឹត្តក៏ដោយ") ។

[340] *សហរដ្ឋអាមេរិក ទល់នឹង Milch,* សាលក្រម, ករណីលេខ ២, តុលាការយោធានូរ៉ឹមប៊ែរលើករណីរបស់សហរដ្ឋអាមេរិក, ថ្ងៃទី១៧ មេសា ១៩៤៧ ។ *សហរដ្ឋអាមេរិក ទល់នឹង Pohl,* សាលក្រម, ករណីលេខ ៤, តុលាការយោធានូរ៉ឹមប៊ែរលើករណីរបស់សហរដ្ឋអាមេរិក, ថ្ងៃទី៣ វិច្ឆិកា ១៩៤៧ (តុលាការបានយល់ឃើញថា ទាសភាព គឺជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ), ទំព័រទី ១៣-១៤, ៣៥-៣៨ ។

[341] *សូមមើល* សាលក្រមលើករណីរបស់ *Kunarac* ។ សាលដីកានៃសាលាឧទ្ធរណ៍លើករណីរបស់ *Kunarac* ។

[342] សាលដីកានៃសាលាឧទ្ធរណ៍លើករណីរបស់ *Kunarac,* កថាខណ្ឌទី ១២៤ ។ *រដ្ឋអាជ្ញា ទល់នឹង Krnojelac,* សាលក្រម, IT-97-25-T, អង្គជំនុំជម្រះតុលាការ ICTY, ថ្ងៃទី១៥ មីនា ២០០២, កថាខណ្ឌទី ៣៥៣, ៣៥៥ ។ សាលក្រមលើករណីរបស់ *Sesay* កថាខណ្ឌទី ១៩៦ ។

[343] ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម, មាត្រា ៧.២.គ ។

[344] សាលក្រមលើករណីរបស់ *Kunarac,* កថាខណ្ឌទី ៥៣៩ ។

ដែលបានចាត់ឡើងដើម្បីទប់ស្កាត់ ឬធ្វើឱ្យញញើតកុំឱ្យមានការរត់គេច, ហិង្សា, ការគំរាមកំហែងដោយប្រើហិង្សា ឬការបង្ខិតបង្ខំ, រយៈពេល, ការជំនះប្រើភាពផ្ដាច់មុខ, ការឋិតនៅក្រោមការគ្រប់គ្រង និងការបំពានដ៏សាហាវ, ការត្រួតពិនិត្យលើរឿងផ្លូវភេទ និងពលកម្មដោយបង្ខំ"[345]។ *បំណងឧក្រិដ្ឋ (mens rea)* នៃឧក្រិដ្ឋកម្ម គឺជាការអនុវត្តដោយ ចេតនានូវអំណាចទាំងឡាយនេះ[346] ។

២០៥- អាស្រ័យហេតុដូច្នេះ ការតម្រូវឱ្យមានធាតុផ្សំពលកម្មដោយបង្ខំ នឹងកាត់បន្ថយនូវវិសាលភាពនៃនិយមន័យនៃពាក្យ ការធ្វើឱ្យទៅជាទាសករដែលត្រូវបានទទួលស្គាល់ទៅតាមអនុសញ្ញា និងច្បាប់ទម្លាប់អន្តរជាតិ ។ តុលាការ ICTY បានរកឃើញថា "ការជាន់ឈ្លីលើពលកម្ម ឬសេវាដោយបង្ខំ ឬដែលត្រូវតែធ្វើខានមិនបាន ហើយមានការពាក់ព័ន្ធទៅនឹងភាពលំបាកខាងរាងកាយ ទោះបីជាមិនចាំបាច់ក៏ដោយ" បង្កើតបានជាការចង្អុលបង្ហាញពីលក្ខណៈមួយ ក្នុងចំណោមការចង្អុលបង្ហាញពីលក្ខណៈនានាស្ដីពីការធ្វើឱ្យទៅជាទាសករ ក៏ប៉ុន្តែវាមិនបង្កើតបានជាផ្នែកមួយនៃនិយមន័យស្ដីពីការធ្វើឱ្យទៅជាទាសករទេ[347]។ តុលាការ SCSL ក៏បានកត់សម្គាល់ផងដែរអំពីសញ្ញាចង្អុលបង្ហាញទាំងនេះអំពីការធ្វើឱ្យទៅជាទាសករនៅក្នុងករណីរបស់ *Sesay*[348] ។

២០៦- សហព្រះរាជអាជ្ញាសន្និដ្ឋានថា និយមន័យនៃពាក្យការធ្វើឱ្យទៅជាទាសកររបស់អង្គជំនុំជម្រះសាលាដំបូង ដែលតម្រូវឱ្យមានធាតុផ្សំមួយស្ដីពីពលកម្មដោយបង្ខំគឺមិនត្រូវគ្នាទៅនឹងយុត្តិសាស្ត្រ

---

[345] សាលក្រមលើករណីរបស់ *Kunarac*, កថាខណ្ឌទី ៥៤៣ ។

[346] សាលក្រមលើករណីរបស់ *Kunarac*, កថាខណ្ឌទី ៥៤០ ។

[347] សាលក្រមលើករណីរបស់ *Kunarac*, កថាខណ្ឌទី ៥៤២ ("ការចង្អុលបង្ហាញពីការធ្វើឱ្យទៅជាទាសករ ដោយរាប់បញ្ចូលទាំងការកេងប្រវ័ញ្ច, ការរំលោភបំពានលើពលកម្ម ឬលើសេវា ដោយបង្ខំ ឬដែលត្រូវតែធ្វើខានមិនបាន ជាញឹកញាប់ដោយគ្មានលាភការ ហើយជាញឹកញយ បើទុកណាជាពុំមានការចាំបាច់ក៏ដោយ មានការពាក់ព័ន្ធទៅនឹងភាពលំបាកខាងរាងកាយ ផ្លូវភេទ ពេស្យាចារ និងការជួញដូរមនុស្ស")។ សាលដីកាលើករណី របស់ *Kunarac* កថាខណ្ឌទី ១១៩ (បានបញ្ជាក់អះអាងពីនិយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងលើពាក្យ ការធ្វើឱ្យ ទៅជាទាសករ និងអំពី សញ្ញាចង្អុលបង្ហាញនានាពី ការធ្វើឱ្យទៅជាទាសករ) ។

[348] សាលក្រមលើករណីរបស់ *Sesay* កថាខណ្ឌទី ១៩៨-១៩៩ ។

00613570



អន្តរជាតិទេ។ ដោយការយកលក្ខខណ្ឌតម្រូវនេះមកអនុវត្តតាមអង្គជំនុំជម្រះសាលាដំបូងខកខានពុំបានផ្តន្ទាទោសចុងបណ្តឹងសាទុក្ខ ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការធ្វើឱ្យទៅជាទាសករទៅលើពួកអ្នកជាប់ឃុំឃាំងភាគច្រើននៅមន្ទីរស-២១ ដែលពុំបានថិតនៅក្រោមពលកម្មដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត ។

២០៧- នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថាអំពើភាគច្រើនដែលបង្កើតបានជាការធ្វើឱ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានគេផ្តល់សក្ខីកម្ម។ ក្នុងចំណោមនោះ ការត្រួតត្រាលើចលនារបស់ពួកអ្នកជាប់ឃុំឃាំង[349], ការត្រួតត្រាលើបរិយាកាសជារូបវន្ត[350] ការត្រួតត្រាតាមផ្លូវចិត្ត[351] វិធានការនានាដែលបានចាត់ឡើងដើម្បីទប់ស្កាត់ ឬធ្វើឱ្យញញើតកុំឱ្យមានការរត់គេច[352] ការគំរាមកំហែងដោយប្រើហិង្សា ឬការបង្ខិតបង្ខំ[353] ការថិតនៅក្រោមការគ្រប់គ្រង និងការបំពានដីសាហារ[354]។ លើសពីនេះទៀត ចុងបណ្តឹងសាទុក្ខខ្លួនគាត់ផ្ទាល់បានទទួលស្គាល់ថា គាត់បានប្រើប្រាស់នូវការត្រួតពិនិត្យទៅលើជីវិត និងការស្លាប់របស់ពួកអ្នកជាប់ឃុំឃាំងនៅមន្ទីរស-២១[355]។

---

[349] សាលក្រម, កថាខណ្ឌទី ២៦០, ២៦៣ ។

[350] សាលក្រម, កថាខណ្ឌទី ២៦០, ២៦៨, ២៧០, ២៧២ ។

[351] សាលក្រម, កថាខណ្ឌទី ២៥៨ (ដោយបានរកឃើញថា "ជនជាប់ចោទបានយល់ស្របថា ស្ថានភាពរស់នៅដែលរួមបញ្ចូលទាំងការឃុំខ្លួន ការសួរចម្លើយ និងការបាត់ខ្លួនអ្នកជាប់ឃុំ បានធ្វើឱ្យចុះខ្សោយដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តអ្នកជាប់ឃុំ ហើយថាពួកគេទាំងអស់នោះបានរស់ នៅក្នុងស្ថានភាពភ័យខ្លាចជានិច្ច") ។ *សូមមើលផងដែរ* សាលក្រម កថាខណ្ឌទី ២៦១-២៦៥។

[352] សាលក្រម, កថាខណ្ឌទី ២៦០ ។

[353] សាលក្រម, កថាខណ្ឌទី ១៦៤ ។

[354] សាលក្រម, កថាខណ្ឌទី ២៦៤ ។

[355] សាលក្រម, កថាខណ្ឌ២៥៩ (ដោយបានរកឃើញថា "ជនជាប់ចោទបានបញ្ជាក់ថា ដោយសារតែអ្នកទាំងនោះត្រូវបានគេកំណត់សម្លាប់ចោល ដូច្នេះមិនចាំបាច់ប្រព្រឹត្តអំពើអមនុស្សធម៌ចំពោះអ្នកជាប់ឃុំទាំងនោះទេ")។

២០៨- អាស្រ័យហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថាអំណាចនានាដែលបានភ្ជាប់ទៅនឹងសិទ្ធិលើកម្មសិទ្ធិត្រូវបានអនុវត្តនៅមន្ទីរស-២១ ដែលជាការបំពេញនូវលក្ខខណ្ឌតម្រូវបន្ថែមសម្រាប់ការធ្វើឱ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[356]។ លើសពីនេះអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើងដោយមានចេតនា[357] និងដោយមានគោលបំណងនៅក្នុងការអនុវត្តនូវកម្មសិទ្ធិទៅលើពួកអ្នកជាប់ឃុំឃាំងទាំងនោះ[358]។

## ច.៣ សេចក្តីសន្និដ្ឋាន

២០៩- សហព្រះរាជអាជ្ញា សូមស្នើអង្គជំនុំជម្រះតុលាការកំពូលទទួលយកនូវទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះ ហើយសូមឱ្យធ្វើសេចក្តីសម្រេចថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងផ្នែកច្បាប់ទៅលើនិយមន័យរបស់ខ្លួន ស្តីពីការធ្វើឱ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយ និងសូមឱ្យធ្វើសេចក្តីសម្រេចបន្ថែមទៀតថា ការធ្វើឱ្យទៅជាទាសករ ពុំតម្រូវឱ្យមានធាតុផ្សំពលកម្មដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្តនោះឡើយ។ យោងទៅតាមសេចក្តីនេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល ធ្វើការផ្តន្ទាទោសចុងបណ្តឹងសាទុក្ខ ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការធ្វើឱ្យទៅជាទាសករ ទៅលើពួកអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១ ដែលពួកទាំងនោះ ពុំចាំបាច់ត្រូវបានបិតនៅក្រោមពលកម្មដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត ។

---

[356] សាលក្រមលើករណីរបស់ *Kunarac,* កថាខណ្ឌទី ៥៣៩ ។

[357] សាលក្រម, កថាខណ្ឌទី ២៥២ (ដោយបានរកឃើញថា "យោងតាមសម្តីរបស់ជនជាប់ចោទ គោលបំណងនៃការធ្វើទារុណកម្មនៅមន្ទីស-២១គឺ៖ "នេះពិតជាការធ្វើទុក្ខធ្វើបាបបន្ថែមទៅលើជនរងគ្រោះបង្ខំឱ្យឆ្លើយសារភាព"") (ដោយបានលើកឡើងពី ប្រតិចារឹកសវនាការ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី១៦ មិថុនា ២០០៩ T.51) ។ សាលក្រម, កថាខណ្ឌទី ២៥៩ (ដោយកត់សម្គាល់ថា "[ចុងបណ្តឹងសាទុក្ខ] បានបញ្ជាក់ថា ដោយសារតែ អ្នកទាំងនោះត្រូវបានគេកំណត់សម្លាប់ចោល ដូច្នេះមិនចាំបាច់ប្រព្រឹត្តអំពើអមនុស្សធម៌ចំពោះអ្នកជាប់ឃុំទាំងនោះទេ")។

[358]សាលក្រមលើករណីរបស់ *Kunarac,* កថាខណ្ឌទី ៥៣៩, ៥៤៣ ។ សាលដីកានៃសាលាឧទ្ធរណ៍លើករណីរបស់ *Kunarac,* កថាខណ្ឌទី១១៩ (ដោយបានរក ឃើញថា ការធ្វើឱ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងនោះមានការអនុវត្តនូវអំណាចណាមួយ ឬទាំងអស់ដែលភ្ជាប់ ទៅនឹងសិទ្ធិលើកម្មសិទ្ធិ ទៅលើបុគ្គលណាម្នាក់ ) ។

# ៩. សេចក្ដីសន្និដ្ឋានចុងក្រោយ

២១០- នេះគឺដល់ចំណុចមួយ ដែលឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្ត គឺមានលក្ខណៈធ្ងន់ធ្ងរយ៉ាងគ្រប់គ្រាន់ ហើយអ្នកប្រព្រឹត្តបទល្មើសរូបនេះត្រូវគេដឹងឮគ្រប់គ្នាយ៉ាងគ្រប់គ្រាន់ ឬដែលឋិតនៅក្នុងតំណែង និងសិទ្ធិអំណាចបែបដូច្នេះ គេត្រូវតែធ្វើការផ្ដន្ទាទោសឲ្យបានធ្ងន់បំផុត។ ចំណុចនោះត្រូវបានគេរកឃើញ និងបានសម្រេចនៅទីនេះ។ នៅក្នុងករណីនេះមានកម្មាភិបាលជាន់ខ្ពស់ ដែលជាអ្នកទទួលខុសត្រូវមួយរូបនៃ បកក បានធ្វើជាអធិបតីក្នុងទីកន្លែងសំលាប់មនុស្ស ដ៏ធំដែលមានការរៀបចំ។ ទីកន្លែងនោះនោះគឺ មន្ទីរស-២១។ គោលការណ៍នៃការធ្វើឲ្យខ្លាចញញើត និងការផ្ដន្ទាទោសសងសឹក អាចនឹងត្រូវបានគេពេញចិត្តយ៉ាងខ្លាំងតាមរយៈ ការធ្វើការផ្ដន្ទាទោសដ៏ធ្ងន់បំផុត។

២១១- អង្គហេតុនានា គឺរឹងមាំ។ វានឹងមិនរលាយបាត់ទៅណាឡើយ។ ចុងបណ្ដឹងសាទុក្ខត្រូវបានរកឃើញថាត្រូវទទួលខុសត្រូវចំពោះគ្រប់ឧក្រិដ្ឋកម្មអន្តរជាតិទាំងអស់ ដែលបានចោទប្រកាន់ទៅលើរូបគាត់។ សញ្ញាសម្គាល់គុណភាពខាងផ្លូវច្បាប់ (legal hallmarks) នៃឧក្រិដ្ឋកម្មទាំងនេះត្រូវបានបូករួមបញ្ចូលគ្នា (were compounded) ដោយកាលៈទេសៈធ្ងន់ធ្ងរដែលជាស្ថានទម្ងន់ នានាមួយចំនួន៖

ក) ការរំលោភបំពានលើសិទ្ធិអំណាចពីសំណាក់ចុងបណ្ដឹងសាទុក្ខ និងចេតនារបស់គាត់ នៅក្នុងការរើសអើងប្រឆាំងនឹងពួកដែលគេបានមើលឃើញថាប្រឆាំងនឹងបក្ស ពួកល្មើយសឹក និងពួកជនស៊ីវិលវៀតណាម។

ខ) ភាពសាហាវឃោរឃៅជាក់ស្ដែងនៃឧក្រិដ្ឋកម្មនានា ដែលត្រូវបានលើកជាឧទាហរណ៍យ៉ាងច្បាស់ដោយការប្រើប្រាស់ជាប្រព័ន្ធនូវការធ្វើទារុណកម្មលើរាងកាយ និងតាមផ្លូវចិត្ត ការ

ប្រមាថមើលងាយ ការគ្រប់គ្រងតាមបែបអមនុស្សធម៌ និងការសម្លាប់ដោយឈាមត្រជាក់ ។

គ) ភាពគ្មានការការពារខ្លួន និងភាពងាយរងគ្រោះរបស់ពួកជនរងគ្រោះដោយរាប់បញ្ចូលទាំងកុមារ និងស្ត្រី ដែលត្រូវបានជាប់ដោយក្តីគ្មានមេត្តារបស់ចុងបណ្តឹងសាទុក្ខ និងពួកថ្នាក់ក្រោមរបស់គាត់ ។

ឃ) ការបដិសេធលើរាល់ភាពថ្លៃថ្នូរ និងភាពជាមនុស្សគ្រប់បែបយ៉ាងរបស់ជនរងគ្រោះ ហើយការបន្ទាបបន្ថោកស្ថានភាពរបស់ពួកគេឱ្យដូចជាសត្វធាតុ ក្នុងគោលបំណងដើម្បីធ្វើឱ្យមានភាពងាយស្រួលសម្រាប់ពួកអ្នកសួរចម្លើយ និងពួកអ្នកយាមក្នុងបំណងធ្វើទារុណកម្ម និងសម្លាប់ពួកគេចោល ។

២១២- វាជាការពិតហើយដែលថា ចុងបណ្តឹងសាទុក្ខមិនបានប្រព្រឹត្តដោយផ្ទាល់ខ្លួននូវភាគច្រើននៃអំពើដែលបានលើកឡើងចោទប្រកាន់ ក៏ប៉ុន្តែសេចក្តីសង្កេតរបស់តុលាការក្នុងស្រុកនៅហ្សេរូសាឡឹមនៅក្នុងករណីរបស់ *Eichmann* ដែលគួរតែត្រូវបានរំលឹកឡើងវិញថា៖ "ជាទូទៅកម្រិតនៃការទទួលខុសត្រូវបានកើនឡើង ខណៈដែលយើងបានទាញឱ្យឆ្ងាយថែមទៀត ចេញពីជនដែលបានប្រើឧបករណ៍សម្លាប់ដោយផ្ទាល់ដៃរបស់ខ្លួន ហើយបានឈានឡើងដល់លំដាប់ខ្ពស់ជាងមុននៅក្នុងខ្សែបញ្ជា"[359]។ ចុងបណ្តឹងសាទុក្ខ គឺជាមនុស្សបែបដូច្នោះដែលមានការទទួលខុសត្រូវចេះតែកើនឡើង។ ចៅក្រមអន្តរជាតិដ៏ល្បីឈ្មោះមួយរូបបានពោលថា "សង្គ្រាមពុំមែនជាលក្ខខណ្ឌមួយនៃ

[359] សាលដីកានៃសាលាឧទ្ធរណ៍លើករណីរបស់ *Galić* ។ ទស្សនៈដោយឡែករបស់ចៅក្រម Shahabuddeen, កថាខណ្ឌទី ៤១ (ដោយបានលើកឡើងពី *អគ្គរដ្ឋអាជ្ញា នៃរដ្ឋាភិបាលអ៊ីស្រាអែល ទល់នឹង Adolf Eichmann*, សាលដីកា, តុលាការក្នុងស្រុកនៅហ្សេរូសាឡឹម, 36 ILR 18, ឆ្នាំ១៩៦១) ។

ភាពអនាធិបតេយ្យ ឬភាពគ្មានច្បាប់ទេ"[360]។ អ្វីដែលបានកើតឡើងនៅមន្ទីរស-២១ គឺពុំមែនជាភាពអនាធិបតេយ្យទេ។ វាមានលក្ខណៈដូចជាត្រូវបានគេរៀបចំ ដ៏ឃោរឃៅ និងដ៏គួរឱ្យរន្ធត់។ មនុស្សជាតិទាំងឡាយមានអ្នកដែលងាយរងគ្រោះ ក្មេងៗ អ្នកគ្មានកំហុស សុទ្ធតែត្រូវបានគេប្លន់យកអស់នូវរាល់ភាពជាមនុស្សទាំងអស់របស់ពួកគាត់។ ពួកគាត់ត្រូវបានគេធ្វើទារុណកម្ម ចាប់រំលោភសេពសន្ថវៈ និង សម្លាប់ចោល។ តែឥឡូវនេះ ចុងបណ្ដឹងសាទុក្ខបែរជាអង្វរសុំឱ្យរួចទោសទៅវិញ។ ជនម្នាក់នេះហើយដែលបាន បញ្ជានៅកន្លែងមរណៈ និងកន្លែងដ៏ឃោរឃៅនេះ។

២១៣- លើកលែងតែការពិចារណាពីការឃុំខ្លួនដោយខុសនីតិវិធីច្បាប់ ពីសំណាក់អាជ្ញាធរយោធាកម្ពុជា នៅក្នុងការកាត់បន្ថយទោសរបស់ចុងបណ្ដឹងសាទុក្ខចេញតែប៉ុណ្ណោះ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្ត ដោយខុសឆ្គងនូវឆន្ទានុសិទ្ធិរបស់ខ្លួនដោយការរកឃើញពីកត្តានានាដ៏ជាក់លាក់មួយចំនួន៖ ទី១ ស្ថានសម្រាលនានាដ៏ "សំខាន់" និងទី២ ដោយការផ្ដល់ស្ថានសម្រាលហួសហេតុ។

២១៤- ខណៈដែលរាល់ការអត់អោនបញ្ជាក់ឱ្យឃើញពីកំហុសឆ្គង កំហុសឆ្គងនោះមានវត្តមាននៅពេលដែលតុលាការសាលាឧទ្ធរណ៍មួយយល់ឃើញថា ការអត់អោនទោសនោះ បានហៀរកន្លងភាពត្រឹមត្រូវនៃការផ្ដន្ទាទោស។ នៅពេលដែលអង្គជំនុះជម្រះសាលាដំបូងសម្រេចយកការផ្ដន្ទាទោសមួយពុំសមហេតុផលណាមួយ ខណៈដែលមានការអត់អោនដូចដែលបានសម្រេចរួចមកហើយនេះ នោះអង្គជំនុំជម្រះតុលាការកំពូល ត្រូវតែធ្វើការអន្តរាគមន៍នៅក្នុងការរក្សានូវបេសកកម្មរបស់ខ្លួន។ បញ្ហាគឺមិនមែននៅត្រង់តែតួលេខដែលបានសំរេចផ្ដន្ទាទោសនោះទេ។ ដូច្នេះ បើពិនិត្យមើលការផ្ដន្ទាទោសមួយដែលមានរយៈពេលជាប់ពន្ធនាគារចំនួនសាមសិបប្រាំ(៣៥)ឆ្នាំ នោះអាចនឹងមាន

---

360 សាលដីកាលើករណីរបស់ *Galic* ។ ទស្សនៈដោយឡែករបស់ចៅក្រម Shahabuddeen, កថាខណ្ឌទី ៤១ (ដោយបានលើកឡើងពីលោក Hersch Lauterpacht) ។

ការលេចឡើងថាវាមានទម្ងន់ច្រើនហើយ។ ប៉ុន្តែបញ្ហា គឺនៅត្រង់ថា តើការផ្តន្ទាទោសដែលបានដាក់រួចហើយនោះ មានលេចឡើងយ៉ាងដូចម្តេចពាក់ព័ន្ធទៅនឹងការផ្តន្ទាទោសដែលត្រូវបានវិនិច្ឆ័យយ៉ាងសមហេតុផល ដើម្បីឲ្យភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនានារបស់ចុងបណ្តឹងសាទុក្ខ សមនឹងទទួលបាន។ ដោយការក្រឡេកមើលពីភាពធ្ងន់ធ្ងរ នៃឧក្រិដ្ឋកម្មនានារបស់ចុងបណ្តឹងសាទុក្ខ គឺពុំមានហេតុផលណាមួយ ដែលអង្គជំនុំជម្រះសាលាដំបូង អាចនឹងសម្រេចយកការផ្តន្ទាទោសមួយដែលមានកម្រិតទាបស្មើនឹងការដាក់ពន្ធនាគារចំនួនសាមសិបប្រាំ(៣៥)ឆ្នាំ នោះឡើយ។

២១៥- ស្ថានភាពទាំងឡាយនៃករណីនេះ អាចនឹងចេញជាលទ្ធផលនៅក្នុងការសម្រេចយកនូវការផ្តន្ទាទោសតែមួយគត់គឺ៖ ការជាប់ពន្ធនាគារអស់មួយជីវិត ដោយមានការកាត់បន្ថយមួយដើម្បីទូទាត់ចំពោះរយៈពេលនៃការឃុំខ្លួនដោយខុសនីតិវិធីច្បាប់ ហើយស្ថានសម្រាលដ៏តិចតួចនានា។

## ៥. ដំណោះស្រាយដែលស្នើសុំ

២១៦- អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល ទុកដោយឡែកនូវសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ហើយស្នើសុំ៖

ក) **ផ្តន្ទាទោសត្រួត** ទៅលើចុងបណ្តឹងសាទុក្ខចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការសម្លាប់រង្គាល (ស្រូបចូលទៅក្នុងការធ្វើមនុស្សឃាត) ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

ខ) **ផ្តន្ទាទោស** ចុងបណ្តឹងសាទុក្ខចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការធ្វើឲ្យ

ទៅជាទាសករ ទៅលើពួកអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១ ក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

គ) **ពិនិត្យសារឡើងវិញ** នូវការផ្តន្ទាទោសដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចឲ្យបានដល់កំរិតជាប់ពន្ធនាគារអស់មួយជីវិត ។

ឃ) **បង្គាប់ថា** ការផ្តន្ទាទោសជាប់ពន្ធនាគារអស់មួយជីវិតនេះ ត្រូវកាត់បន្ថយមកនៅត្រឹមរយៈពេលសែសិបប្រាំ(៤៥)ឆ្នាំ ជាដំណោះស្រាយមួយដ៏សមស្របសម្រាប់ការឃុំខ្លួនចុងបណ្តឹងសាទុក្ខដោយខុសនីតិវិធីច្បាប់ នៅមុនពេលមានការឃុំខ្លួននៅ អ.វ.ត.ក។

ង) **បង្គាប់ថា** ការកាត់បន្ថយជាបន្តបន្ទាប់ទៀតត្រូវធ្វើឡើងឲ្យបានសមស្រប ចំពោះគ្រប់ស្ថានសម្រាលដែលមានកំរិតនីមួយៗ ដែលត្រូវទទួលបាននៅក្នុងកាលៈទេសៈនៃករណីនេះ។

ច) **សម្រេចថា** ចុងបណ្តឹងសាទុក្ខនឹងត្រូវទទួលការអនុវត្តទោសតាមការសម្រេចផ្តន្ទាទោសដោយគ្មានការដោះលែង ឬបន្ធូរបន្ថយទោស (parole) ណាមួយឡើយ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |